**សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Science Economiques**

**Royal University of Law and Economics**

---*---

## សារណាបញ្ចប់ការសិក្សា

# កំណែទម្រង់យុត្តិធម៌ និងការការពារសិទ្ធិមនុស្សនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **គីម សាម៉ីឌី**

សាស្ត្រាចារ្យណែនាំ

លោក **ខឿក ពិដោរ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៧

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

---*---

ខ្ញុំបាទ **គីម សាម៉ុឌី** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញនីតិសាស្រ្តដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច សូមសម្តែងនូវកតញ្ញូតាធម៌ និងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ៖

- **លោកឪពុក-អ្នកម្តាយ** ដែលបានផ្តល់កំណើត ចិញ្ចឹមថ្នាក់ថ្នមបីបាច់ថែរក្សា ផ្តល់នូវសេចក្តីស្រឡាញ់ប្រកបដោយព្រហ្មវិហារធម៌ អប់រំទូន្មាន ប្រៀនប្រដៅ និងទំនុកបម្រុងគ្រប់បែបយ៉ាងទាំងសម្ភារ ទាំងស្មារតី និងថវិកាឲ្យកូនបានសិក្សារៀនសូត្ររហូតដល់បច្ចុប្បន្ននេះ។

- ឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចដែលបានអនុញ្ញាតឲ្យខ្ញុំបានចូលសិក្សានៅសាកលវិទ្យាល័យនេះ និងបង្ករលក្ខណៈងាយស្រួលដល់ការសិក្សារបស់ខ្ញុំ។

- លោកសាស្រ្តាចារ្យ **ឡើក ពិដោរ** ជាសាស្រ្តាចារ្យណែនាំ ដែលបានឆ្លៀតឱកាសដ៏មានតម្លៃ និងដ៏មមាញឹកក្នុងការបង្ហាត់បង្រៀន ផ្តល់ការណែនាំថែមទាំងបានផ្តល់គន្លឹះមួយចំនួនដល់ខ្ញុំ ដើម្បីរៀបចំសរសេរសារណាបញ្ចប់ការសិក្សានេះឡើង។

- ថ្នាក់ដឹកនាំ បុគ្គលិកសិក្សា នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចទាំងអស់ដែលបានបង្ករលក្ខណៈងាយស្រួលដល់ការសិក្សារបស់ខ្ញុំ។

- សូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅថែមទៀត ចំពោះអ្នកនិពន្ធ និងអ្នកប្រាជ្ញ ព្រមទាំងទស្សនៈវិទូល្បីៗក្នុងលោក ដែលយើងខ្ញុំបានសិក្សាស្រាវជ្រាវពីស្នាដៃរបស់លោកក្នុងការបំពេញកិច្ចការស្រាវជ្រាវនៅពេលកន្លងមក។

សូមមេត្តាទទួលនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុត និងមិនអាចបំភ្លេចបានចំពោះឧបការគុណដ៏ធំធេងអំពីខ្ញុំ។

ជាទីបញ្ចប់នេះ ខ្ញុំសូមប្រសិទ្ធពរជ័យសិរីបវរជូនដល់លោកអ្នកមានគុណ ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្រ្តាចារ្យទាំងអស់ សូមបានប្រកបតែជោគជ័យគ្រប់ភារកិច្ច និងសូមទទួលបាននូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

ជាបឋម ខ្ញុំបាទ **គីម សាម៉ុឌី** សូមស្វាគមន៍ដល់មិត្តអ្នកអានគ្រប់រូប ជាពិសេសសិស្ស-និស្សិត ជាទីរាប់អាន ព្រមទាំងសាស្ត្រាចារ្យជាទីគោរព។

ក្នុងនាមជានិស្សិតដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុងរាជធានីភ្នំពេញ ខ្ញុំបាទបានរៀបចំនូវសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ក្រោមប្រធានបទស្តីពី "**កំណែទម្រង់យុត្តិធម៌ និងការការពារសិទ្ធិមនុស្សនៅកម្ពុជា**"។ សារណានេះធ្វើឡើងដោយទទួលបានការគាំទ្រ និងការជួយលើកទឹកចិត្ត បង្ហាត់បង្ហាញ កែតម្រូវយ៉ាងពេញទំហឹងពីសំណាក់លោកសាស្ត្រាចារ្យដែលជាសាស្ត្រាចារ្យផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ខ្ញុំបាទសង្ឃឹមយ៉ាងមុតមាំថា សារណានេះនឹងចូលរួមជាវិភាគទានដ៏សំខាន់នៅក្នុងដំណើរការកំណែទម្រង់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជាបច្ចុប្បន្ន ហើយក៏ជាឯកសារស្រាវជ្រាវបែបវិទ្យាសាស្ត្រមួយថ្មីថែមទៀត ដែលបំពេញឲ្យសេចក្តីត្រូវការជាចាំបាច់ដល់មជ្ឈដ្ឋានអ្នកសិក្សាស្រាវជ្រាវដែលបាននឹងកំពុងជួបប្រទះនូវកង្វះខាតនាពេលបច្ចុប្បន្ននេះ។

ម្យ៉ាងវិញទៀត ខ្ញុំបាទសូមអភ័យទោសចំពោះចំណុចខ្វះខាតដែលកើតមានឡើងនៅក្នុងសារណានេះ។ ខ្ញុំបាទរង់ចាំទទួលយកនូវការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់មិត្តអ្នកអានទាំងអស់គ្នា ដើម្បីធ្វើការកែលម្អសារណានេះឲ្យកាន់តែប្រសើរឡើង ។

ជាទីបញ្ចប់នេះ សូមជូនពរដល់អ្នកអានគ្រប់រូបឲ្យជួបប្រទះតែនឹងភាពសុខដុមរមនា រុងរឿង ថ្កុំថ្កើង និងមានសុភមង្គលជានិរន្តន៍កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម**.....០១

**ជំពូកទី១ មូលដ្ឋានគ្រឹះនៃឯករាជភាពនៃយុត្តិធម៌**.....០៣

**ផ្នែកទី១ ការប្រមើលមើលការវិវត្តនៃយុត្តិធម៌នៅកម្ពុជា**.....០៣

កថាខណ្ឌទី១ យុត្តិធម៌មុនសម័យអាណានិគម.....០៣

កថាខណ្ឌទី២ យុត្តិធម៌សម័យអាណានិគម.....០៤

ក. យុត្តិធម៌នៃច្បាប់មូលដ្ឋាន.....០៤

ខ. យុត្តិធម៌នៃច្បាប់បារាំង.....០៥

កថាខណ្ឌទី៣ យុត្តិធម៌ក្រោយសម័យអាណានិគម.....០៥

**ជំពូកទី២ គោលការណ៍ដែលធានាឯករាជភាពរបស់យុត្តិធម៌**.....០៧

**ផ្នែកទី១ សមភាពនៅចំពោះមុខយុត្តិធម៌**.....០៧

ក. ប្រភពដើមនៃគោលការណ៍.....០៨

ខ. ការទទួលយកនៃគោលការណ៍ដោយច្បាប់ខ្មែរ.....០៨

១. មជ្ឈការ.....០៨

២. យុត្តិធម៌ក្រោមគំនាប.....០៩

ក. ទំនាក់ទំនងនៃយុត្តិធម៌ជាមួយនឹងរដ្ឋបាលផ្សេងទៀត.....០៩

ខ. នយោបាយភាវូបនីយកម្មនៃយុត្តិធម៌.....០៩

គ. គំនាបនៃទឹកប្រាក់.....១០

៣. ភាពមិនមានជាក់ស្តែងនៃស្ថាប័ន.....១០

**ផ្នែកទី២ ការធានាលក្ខន្តិកៈគតិយុត្តនៃឯករាជភាព: ការការពារចៅក្រមប្រឆាំងនឹងរាល់ទម្រង់នៃគំនាប**..........១០

កថាខណ្ឌទី១ ភាពមិនអាចផ្លាស់ប្តូរបាននៃចៅក្រមអាសនៈ..........១០

កថាខណ្ឌទី២ វិធានការទាក់ទងការតែងតាំង ការដាក់ពិន្ទុ ការវាយតម្លៃ និងការដំឡើងថ្នាក់ចៅក្រម..........១០

**ផ្នែកទី៣ អត្ថបទ និងនីតិវិធី**..........១៣

កថាខណ្ឌទី១ ការសើរើនៃអត្ថបទ និងនីតិវិធី..........១៣

១. លក្ខន្តិកៈចៅក្រម..........១៣

២. ការសើរើក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ..........១៥

កថាខណ្ឌទី២ សនិទានកម្មនៃការរៀបចំតុលាការ..........១៥

**ជំពូកទី៣ កត្តាដែលធានាឯករាជភាពនៃយុត្តិធម៌**..........១៧

**ផ្នែកទី១ អង្គការដែលធានាឯករាជភាពនៃយុត្តិធម៌**..........១៧

កថាខណ្ឌទី១ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម..........១៧

កថាខណ្ឌទី២ តួនាទីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម..........១៩

១. សមត្ថកិច្ចទូទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម..........១៩

២. សមត្ថកិច្ចក្នុងមុខការដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា..........១៩

កថាខណ្ឌទី៣ តុលាការកំពូល..........២១

ក. នាយកដ្ឋានស៊ើបអង្កេត និងការត្រួតពិនិត្យការស៊ើបអង្កេត..........២៣

ខ. នាយកដ្ឋានព្រហ្មទណ្ឌ..........២៣

គ. នាយកដ្ឋានរដ្ឋប្បវេណី..........២៣

កថាខណ្ឌទី៤ អាគ្គាធិការនៃរដ្ឋបាលយុត្តិធម៌ និងពន្ធនាគារ..........២៤

ក. អង្គភាពរដ្ឋបាលតុលាការ....................................................................................២៤

ខ. អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ............................................................២៤

**ផ្នែកទី២ ការលើកកម្ពស់សិទ្ធិមនុស្ស**.......................................................................២៥

កថាខណ្ឌទី១ ការធានាបណ្ដឹងមួយប្រកបដោយសមធម៌ និងការគោរពសិទ្ធិការពារខ្លួន..២៥

កថាខណ្ឌទី២ រដ្ឋបាលពន្ធនាគារ.........................................................................................២៦

ក. ភារកិច្ចនាយកដ្ឋានពន្ធនាគារ......................................................................................២៦

ខ. ភារកិច្ចរបស់ពន្ធនាគារ...................................................................................................២៧

កថាខណ្ឌទី៣ ការចូលទៅប្រើសិទ្ធិ និងយុត្តិធម៌................................................................២៧

**ជំពូកទី៤ ឆ្ពោះទៅរកទំនើបកម្មនៃប្រព័ន្ធតុលាការ**...................................................................២៩

**ផ្នែកទី១  ទំនើបកម្មនៃរចនាសម័ន្ធ និងរបៀបនៃដំណោះស្រាយជម្លោះ**..................២៩

កថាខណ្ឌ១ ហេដ្ឋារចនាសម័ន្ធ និងការបំពាក់គ្រឿងសម្ភារ..........................................២៩

ក. អាគារ និងសំណង់.......................................................................................................២៩

ខ. ការធ្វើទំនើបកម្ម...............................................................................................................៣០

**ផ្នែកទី២ ទំនើបកម្មនៃយុត្តិធម៌ និងការជម្រុញរបៀបផ្លាស់ភ្លានៃដំណោះស្រាយជម្លោះ**.....៣១

កថាខណ្ឌទី១ ការអភិវឌ្ឍន៍នៃវិធីបច្ចេកទេសទំនើបកម្មនៃសេវាសាធារណៈ...................៣១

ក. ស្ថានភាពបច្ចុប្បន្ន...........................................................................................................៣១

ខ. សំណើ..............................................................................................................................៣២

កថាខណ្ឌទី២ ការលើកកម្ពស់វិធីឆ្លាស់គ្នានៃដំណោះស្រាយជម្លោះ.............................៣២

ក. ស្ថានភាពបច្ចុប្បន្ន.............................................................................................................៣២

ខ. សំណើ.................................................................................................................................៣២

**ជំពូកទី៥ ធនធានមនុស្ស និងជំនួយការតុលាការ**..........ពពព

**ផ្នែកទី១ ការគ្រប់គ្រងធនធានមនុស្ស**..........៣៣

កថាខណ្ឌទី១ ស្ថានភាពបច្ចុប្បន្ននៃចៅក្រម និងព្រះរាជអាជ្ញា..........៣៣

កថាខណ្ឌទី២ ការបញ្ជាក់មូលហេតុនៃបុគ្គលិករបស់តុលាការ..........៣៣

**ផ្នែកទី២ ជំនួយការតុលាការផ្សាភ្ជាប់ទៅនឹងលក្ខន្តិកៈសេរី**..........៣៤

កថាខណ្ឌទី១ មេធាវី..........៣៤

កថាខណ្ឌទី២ សារការី..........៣៦

**សេចក្តីសន្និដ្ឋាន**..........៣៧

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ការរៀបចំតុលាការនៅកម្ពុជា សម្គាល់បានចាប់តាំងពីការទទួលបានឯករាជ្យដំបូងដោយមានសាលាដំបូងនៅឧទ្ធរណ៍ និងតុលាការកំពូល ។

កំណែទម្រង់ជាច្រើនត្រូវបានធ្វើ ដោយពុំអាចធ្វើឲ្យយុត្តិធម៌ចេញពីវដ្តសង្សារដែលនៅក្នុងវាស្ថិតនៅ។ ដំបូងរងគ្រោះពីឧបករណ៍ល្បួបណីកម្មនយោបាយ បន្ទាប់មកទៀតវិបត្តិដែលមានទម្រង់ចម្រុះ (វិបត្តិនៃទំនុកចិត្ត វិបត្តិនៃអំណាច វិបត្តិនៃភាពជឿជាក់បាន វិបត្តិមធ្យោបាយ និងវិបត្តិសមត្ថកិច្ច...)។ ច្បាប់ទាំងនេះនឹងចេញផុតក្រោមទិដ្ឋភាពបីគឺ សេដ្ឋកិច្ច នយោបាយ និងសង្គម។

ការផ្លាស់ប្តូរធ្វើឡើងដោយយុទ្ធសាស្ត្រត្រីកោណ និងជាពិសេសចតុកោណ សព្វថ្ងៃផ្តល់ឱកាសឲ្យតួអង្គទាំងអស់ក្នុងការរករោគសញ្ញានៃប្រព័ន្ធតុលាការ និងស្នើឡើងនូវវិធានការនានា (ជាបន្ទាន់សម្រាប់រយៈពេលមធ្យម និងរយៈពេលវែង) ដាក់បង្ខំឲ្យទទួលយកដើម្បីជំនួសយុត្តិធម៌នៅក្នុងក្របខណ្ឌរដ្ឋធម្មនុញ្ញ និងស្ថាប័ន។ អក្សរសំខាន់ដែលតាមរយៈនេះ អន្តរាគមន៍ដ៏ឆាប់រហ័សត្រូវបានស្នើឡើងនោះ គឺការអះអាងនៃឯករាជភាពនៃយុត្តិធម៌ និងកំណែទម្រង់ច្បាប់ខ្មែរ។ ការពង្រឹងសមត្ថកិច្ចនៃធនធានមនុស្ស និងការបណ្តុះបណ្តាល ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងទំនើបកម្មនៃយុត្តិធម៌។ ជាដំបូង ត្រូវពង្រឹងឯករាជភាពរបស់តុលាការតាមរយៈការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលនៅមានជាធរមានសម្រាប់វិស័យតុលាការដែលជាអំណាចមួយក្នុងចំណោមអំណាចទាំងបីរបស់រដ្ឋ។ ការអនុវត្តនេះអាចធ្វើទៅបានតាមរយៈការផ្តល់នីតិសម្បទាដល់អំណាចតុលាការនៅក្នុងរង្វង់ស្ថាប័នរដ្ឋដែលត្រូវរៀបចំឡើងវិញឲ្យកាន់តែប្រសើរនូវស្ថាប័ន និងសមាសភាពនានាដែលជំនួយដល់ឯករាជភាពនៃអំណាចតុលាការ។ ការអះអាងចំពោះឯករាជភាពនៃអំណាចតុលាការអាចធ្វើទៅបានតាមរយៈការសើរើលក្ខន្តិកៈ និងសមាសភាពនៃការប្រព្រឹត្តទៅនៃស្ថាប័នមួយចំនួន ជាពិសេសឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងតុលាការកំពូលបច្ចុប្បន្នគឺតាមរយៈច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ។

ឯករាជ្យរបស់តុលាការក៏ត្រូវធានាផងដែរ តាមការដាក់ឲ្យអនុវត្តដ៏ម៉ឺងម៉ាត់នៃគោលការណ៍មិនអាចផ្លាស់ប្តូរនៃចៅក្រមអភ័យឯកសិទ្ធិ និងអព្យាក្រិតភាពរបស់ចៅក្រម។ ការធានាលក្ខន្តិកៈនៃឯករាជភាពនេះ គួរដឹងអំពីការអនុវត្តដ៏ម៉ត់ចត់ និងគួរគោរពតួនាទីនៃលក្ខន្តិកៈរបស់ចៅក្រម បន្ទាប់មកទៀត ក្រសួងយុត្តិធម៌គួរមានធនធានមនុស្សចាំបាច់ដើម្បីសម្រេចបេសកកម្មរបស់ខ្លួន។ រឿងនេះទាមទារចាំបាច់នូវការអនុម័តនយោបាយគ្រប់គ្រងបង្ការនៃបុគ្គលិក ដោយឈរលើការវិភាគមួយដែលមានលក្ខណៈជាទស្សនទានមួយនៃអ្វីដែលមាន ការគ្រប់គ្រងនេះសំដៅបំពេញបំណងតាមរយៈផែនការជ្រើសរើស និងបណ្តុះបណ្តាលដោយបញ្ចូលតម្រូវការចាំបាច់នៃគោលបំណងបុគ្គលិក ព្រមទាំង

តាមរយៈផែនការត្រួតពិនិត្យ និងសកម្មភាពវិន័យផងដែរ។ ដើម្បីបំពេញបន្ថែម គណៈវិនិច្ឆ័យនៃវិធានការនេះ ត្រូវធ្វើឲ្យកាន់តែប្រសើរឡើងនៃលក្ខន្តិកៈវិជ្ជាជីវៈតុលាការសេរី (សារការី មេធាវី...) ត្រូវស្នើឲ្យមាន។

កំណែទម្រង់យុត្តិធម៌មិនអាចសម្រេចបានទេ បើគ្មានការធ្វើឲ្យប្រសើរឡើងនូវបរិស្ថាន និងលក្ខខណ្ឌដែលក្នុងនោះកំណែទម្រង់ត្រូវសម្រេចធ្វើឡើង។ ដូច្នេះ អាទិភាពនៃហេដ្ឋារចនាសម្ព័ន្ធប្រតិបត្តិការ សម្របតម្រូវមួយ និងគ្រឿងឧបករណ៍ដែលអាចឲ្យប្រព័ន្ធតុលាការដើរតួនាទីរបស់ខ្លួនក្នុងលក្ខខណ្ឌដ៏ប្រសើរ គឺជាគោលដៅមិនអាចខ្វះបាន។ ក្នុងក្របខណ្ឌនេះ ត្រូវសង្កត់ធ្ងន់ជាពិសេសលើភាពចាំបាច់ក្នុងការផ្តល់នីតិសម្បទាទៅឲ្យអគារដែលមានស្រាប់ បង្ហោយការងារសាងសង់ដែលកំពុងធ្វើ និងកសាងនូវអាគារថ្មីៗមួយចំនួនទៀតដើម្បីទទួលតុលាការ និងពន្ធនាគារដែលបន្តធ្វើជាជម្រកក្នុងកម្មសិទ្ធិឯកជនដែលបានជាប់កិច្ចសន្យាដោយរដ្ឋ។

ដើម្បីធានាប្រសិទ្ធិភាពដ៏ធំធេងនេះចំពោះអ្វីដែលបានស្នើឡើង របាយការណ៍ដែលតាក់តែងដោយគណៈកម្មការស្នើឲ្យធ្វើទំនើបកម្មនៃវិស័យនេះ តាមរយៈការលើកកម្ពស់នៃការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មានវិទ្យា និងការទំនាក់ទំនង ការធ្វើឲ្យកាន់ប្រសើរឡើងនៃតាវកាលិកនៃសេវាសាធារណៈ តាមរយៈការទទួលជាបុគ្គលនៃអ្នកប្រើប្រាស់ជារូបវន្តក្តី និងតាមទូរស័ព្ទ និងប្រព្រឹត្តកម្មដ៏លឿនរហ័សនឹងប្រកបដោយប្រសិទ្ធិភាពនៃលិខិតឆ្លងឆ្លើយ។ លំហាសម្រាប់ការទទួលភ្ញៀវ ការផ្តល់ព័ត៌មាន ការទុកដាក់ឯកសារត្រូវបានលើកយកមកគិតគូនៅក្នុងគំនិតនៃអាគ្គារយុត្តិធម៌ ។

ការសម្រាលបន្ទុកកិច្ចការដែលត្រូវពិនិត្យនៅចំពោះមុខតុលាការ គឺជាគោលដៅមួយដែលអាចបានត្រឹមតែពង្រឹងយុត្តិធម៌ប៉ុណ្ណោះទេ ការសម្រាលបន្ទុកនេះត្រូវធានាដោយវិធីផ្លាស់គ្នាមួយចំនួននៃដំណោះស្រាយជម្លោះដែលត្រូវលើកកម្ពស់ និងពង្រឹងរចនាសម្ព័ន្ធដែលទទួលបន្ទុក។ របៀបផ្លាស់គ្នា ទាំងនេះគឺជាការបំពេញចាំបាច់មួយសម្រាប់ការប្រព្រឹត្តទៅដ៏ល្អនៃវិស័យតុលាការ ហើយផ្តល់នូវភ័ព្វសំណាងមួយទៅឲ្យអ្នកប្តឹងផ្តល់គ្នាដើម្បីបញ្ចៀសនីតិវិធីតុលាការ តាមធម្មតាដែលមានលក្ខណៈយូរ និងចំណាយច្រើន។

ការសិក្សារបស់យើងនៅក្នុងសារណានេះនឹងត្រូវពិនិត្យឲ្យឃើញថា តើឯករាជ្យរបស់តុលាការត្រូវផ្អែកលើអ្វី ( ជំពូក២) ដែលចង់ងាកទៅរកការធ្វើទំនើបកម្មមួយ ( ជំពូក៤) ។

# ជំពូកទី១

# មូលដ្ឋានគ្រឹះនៃឯករាជភាពនៃយុត្តិធម៌

ជំពូកបឋម ការយល់ឃើញត្រួសៗលើការវិវត្តនៃយុត្តិធម៌នៅកម្ពុជា កម្ពុជាត្រូវបានបារាំងដាក់អាណានិគមជិត ១សតវត្ស (១៨៦៣-១៩៥៣)។ ប៉ុន្តែបារាំងមិនបានជំនួសតុលាការខ្មែរដោយតុលាការអាណានិគមនៅឡើយទេ (១៨៦៣-១៨៨៤៖ លក្ខន្តិកៈអាណាព្យាបាល)។ ប៉ុន្តែចាប់ពីឆ្នាំ ១៨៨៤ ពោលគឺចាប់ពីសន្ធិសញ្ញា Thom Son[1] កម្ពុជាស្ថិតនៅក្រោមអាណានិគមបារាំងដែលបញ្ជាក់បានថាអំណាចរបស់រដ្ឋទាំងអស់ត្រូវជំនួសដោយអំណាចរបស់បារាំងក្នុងនោះមានប្រព័ន្ធយុត្តិធម៌ផងដែរ។

នៅកម្ពុជា យុត្តិធម៌ចែកចេញជា៣ ដំណាក់កាលផ្សេងគ្នាដែលក្នុងរយៈពេលនោះយុត្តិធម៌បានរុញច្រានការកាច់កុងនៃកម្លាំងដែលកំពុងកាន់អំណាច។ ជាអាទិ៍ គឺយុត្តិធម៌មុនអាណានិគមដែលមានលក្ខណៈជាយុត្តិធម៌បុរាណ (កថាខណ្ឌទី១) យុត្តិធម៌អាណានិគមដែលបានបង្កើតឡើងដោយអាជ្ញាធរបារាំងក្នុងអំឡុងពេលនៃការដាក់អាណានិគម (កថាខណ្ឌទី២) និងយុត្តិធម៌ក្រោយអាណានិគមដែលបង្កើតឡើងដោយអាជ្ញាធរសាធារណៈខ្មែរចាប់ពីពេលកម្ពុជាទទួលបានឯករាជភាពរហូតមកដល់សព្វថ្ងៃជាមួយនឹងការផ្លាស់ប្តូរផ្សេងៗគ្នាដែលយុត្តិធម៌នៅកម្ពុជាបានជួបប្រទះ (កថាខណ្ឌទី៣)។

## ផ្នែកទី១ ការប្រមើលមើលការវិវត្តនៃយុត្តិធម៌នៅកម្ពុជា

### កថាខណ្ឌទី១ យុត្តិធម៌មុនសម័យអាណានិគម

យុត្តិធម៌មុនសម័យអាណានិគមនៅប្រទេសកម្ពុជា មិនមានលក្ខណៈដូចការរៀបចំប្រព័ន្ធតុលាការសម័យទំនើបទេ។ តុលាការស្ថិតនៅក្នុងព្រះហស្តតែអង្គឯងរបស់ព្រះមហាក្សត្រ។

តុលាការមុនសម័យអាណានិគម បុគ្គលដែលទទួលបន្ទុកជម្រះរឿងក្តីគឺមាន៣ ប្រភេទ៖

១.សភា: សភាត្រូវមានសំដីងាយយល់ ហើយចេះនិយាយឲ្យបានច្បាស់លាស់ប្រាប់គេ ដើម្បីឲ្យភាគីពាក់ព័ន្ធទាំងពីរអាចយល់បានយ៉ាងងាយនូវអ្វីដែលគេនិយាយទៅកាន់ខ្លួន។

២.ចៅក្រម: ចៅក្រមត្រូវធ្វើការសិក្សារឿងក្តីដោយយកចិត្តទុកដាក់ ពិនិត្យមើលអង្គហេតុធំៗ ហើយផ្តល់ដំបូន្មានឲ្យភាគីទាំងពីរសម្រុះសម្រួលគ្នា ដូច្នេះចៅក្រមត្រូវគិតពីការផ្សះផ្សាភាគីសិន។

---

[1] Charles Anthoine Francois Thomson, ជាអភិបាលកូសាំងស៊ីន

៣.តុលាការ: តុលាការត្រូវចេះទប់កំហឹងភាគីដែលស្ថិតនៅក្នុងបញ្ហាអនុវត្តច្បាប់ដោយយុត្តិធម៌ និងតាមដានមើលឲ្យបានច្បាស់ចំពោះភាគីទាំងពីរត្រូវចេះថ្លឹងថ្លែង[2]។

ប្រសិនបើមន្ត្រីទាំងបីប្រភេទនេះ មានតួនាទីយ៉ាងដូច្នេះ ពួកគេអាចការពារប្រជាជនក៏អាចការពារអ្នកកាន់សាសនា និងមហាក្សត្រដែលជាព្រះមហាក្សត្រ។ ផលវិបាកនៃប្រព័ន្ធបំព្រួញទាំងនេះអាចពន្យល់បានតាមភាពមិនសុក្រិតនៃការប្រព្រឹត្តទៅរបស់វា ដែលអ្នកក្រប៉ះពាល់ខ្លាំងជាងគេ[3]។

### កថាខណ្ឌទី២ យុត្តិធម៌សម័យអាណានិគម

នៅឆ្នាំ១៨៦៣ បារាំងបានចាប់ផ្ដើមដាក់នឹមអាណានិគមលើប្រទេសកម្ពុជា។ តាំងពីពេលនោះមក ច្បាប់នៅប្រទេសកម្ពុជាមានការប្រែប្រួលជាខ្លាំង។ ក្នុងឆ្នាំ១៨៨១ នៃរជ្ជកាលព្រះបាទ **នរោត្តម** បារាំងបានយកក្រមមួយចំនួនដែលអតីតព្រះមហាក្សត្រខ្មែរបានរៀបចំមកធ្វើការបោះពុម្ព និងប្រកាសផ្សាយឲ្យអនុវត្តបានចំនួន៣៩ ក្នុងចំណោម ៥២ក្រម ដោយមិនទាន់មានការកែសម្រួល ឬបញ្ចូលខ្លឹមសារថ្មីទេ។

នៅឆ្នាំ១៩១១ (ដោយសារតែមានសន្ធិសញ្ញាកម្ពុជា-បារាំង) បារាំងបានចាប់ផ្ដើមបញ្ចូលសញ្ញាណនៃច្បាប់បារាំងមកក្នុងច្បាប់របស់ប្រទេសកម្ពុជា។ ដំបូងគឺ "ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ និងការរៀបចំតុលាការ"។ ក្រោយពីបារាំងបានបញ្ចូលច្បាប់បារាំងក្នុងក្រមទាំងពីរនេះរួចហើយ ព្រះបាទ **នរោត្តម** ក៏ឡាយព្រះហស្តលេខាប្រកាសឲ្យប្រើជាផ្លូវការតាមរយៈព្រះរាជបញ្ញត្តិចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩១២ ពោលគឺជាថ្ងៃដែលប្រទេសកម្ពុជាទទួលយកឥទ្ធិពលពីប្រព័ន្ធ Civil Law រួចជាស្រេច គឺ "ក្រមរដ្ឋប្បវេណី" និង "ក្រមនីតិវិធីរដ្ឋប្បវេណី និងការរៀបចំសាលាជម្រះក្តីរដ្ឋប្បវេណី" ត្រូវបានប្រកាសឲ្យប្រើជាផ្លូវការ ដោយព្រះរាជប្បញ្ញត្តិចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩២០។

## ក. យុត្តិធម៌នៃច្បាប់មូលដ្ឋាន

ចាប់ពីឆ្នាំ ១៩១១មក ដំណើរទំនើបកម្មប្រព័ន្ធច្បាប់កម្ពុជាបានចាប់ផ្ដើមដោយដាក់ចេញនូវក្រមសារវន្តចំនួន៣ ដើម្បីអនុវត្ត។ ក្រមទាំងនោះមានដូចជា ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមស្តីពីការរៀបចំតុលាការដែលបានប្រកាសឲ្យអនុវត្តថ្ងៃទី០១ មករាឆ្នាំ១៩១២។ វាជាចំណុចចាប់ផ្ដើមមួយដែលអ្នកច្បាប់យល់ឃើញថាជាសករាជនៃច្បាប់ស៊ីវិលនៅកម្ពុជាបានចាប់បដិសន្ធិឡើង។

[2] ADHEMARD LECLERE Resident de france au cambodge 1898

[3] Institution Constitutionnelles et Politiques du cambodge 1965

## ខ. យុត្តិធម៌នៃច្បាប់បារាំង

កុងសីដេតា គឺជាស្ថាប័នកំពូលរបស់ប្រទេសបារាំងដែលជាបេះដូងនៃវិស័យយុត្តិធម៌ដែលបានបង្កើតឡើងនៅឆ្នាំ ១៧៩៩ ដោយស្តេចណាប៉ូឡេអុង។ កុងសីដេតាមានតួនាទីសំខាន់ក្នុងការត្រួតពិនិត្យមើលលើអត្ថបទច្បាប់ និងដោះស្រាយទំនាស់រវាងរដ្ឋបាលជាមួយនឹងប្រជាពលរដ្ឋ។ រហូតមកដល់បច្ចុប្បន្ននេះ កុងសីដេតានៅតែដើរតួនាទីយ៉ាងសំខាន់នៅក្នុងបេសកកម្មទាំងពីរខាងលើនេះ។ ក្នុងនោះកុងសីដេតាបានផ្តល់ជាអនុសាសន៍ជាច្រើនចំពោះអត្ថបទច្បាប់ដូចជា ច្បាប់ស្តីពីការរៀបការជាមួយភេទដូចគ្នាជាដើម។

ចំពោះតួនាទីក្នុងការដោះស្រាយវិវាទ កុងសីដេតាដើរតួនាទីជាតុលាការរដ្ឋបាលកំពូល។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កុងសីដេតាបានបង្ហាញពីសក្តានុពលរបស់ខ្លួនយ៉ាងខ្លាំងជាក់ស្តែងនៅក្នុងឆ្នាំ ២០១២ កុងសីដេតាបានដោះស្រាយបញ្ហាជាង ៩០០០ករណី ដែលគេសង្កេតឃើញថាវាជាចំនួនមួយច្រើន បើប្រៀបធៀបទៅនឹងទសវត្សទី៩០ ដែលដោះស្រាយបានត្រឹមតែ៤ទៅ៥ពាន់ករណីតែប៉ុណ្ណោះ[4]។

### កថាខណ្ឌទី៣ យុត្តិធម៌ក្រោយសម័យអាណានិគម

ក្រោមព្រះបញ្ញាញាណដឹកនាំដ៏ឈ្លាសវៃ ព្រះហឫទ័យតស៊ូរើបម្រាស់របស់ព្រះករុណាព្រះបាទសម្តេច ព្រះ **នរោត្តម សីហនុ** (អតីតព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា) បានទាមទារឯករាជ្យពីអាណានិគមបារាំង រហូតធ្វើឲ្យប្រទេសកម្ពុជាទទួលបាននូវឯករាជ្យពេញបរិបូរណ៍ក្នុងឆ្នាំ ១៩៥៣។ ចាប់តាំងពីពេលនេះហើយដែលបណ្តាអ្នកច្បាប់ខ្មែរបានធ្វើជាម្ចាស់ការនៃការតាក់តែងច្បាប់របស់ខ្លួនឲ្យស្របទៅតាមស្ថានភាពសង្គម និងទំនៀមទម្លាប់ប្រពៃណីខ្មែរ ដោយបន្តមរតកពីច្បាប់បារាំងបានបន្សល់ទុកឲ្យ[5]។

ក្រោយទទួលបានឯករាជ្យ មរតកច្បាប់នៃប្រទេសបារាំងនៅតែបន្សល់ទុកសម្រាប់ប្រទេសកម្ពុជា លក្ខណៈមួយនៃផ្នត់គំនិតនៃនីតិសាធារណៈដែលនៅតែអនុវត្តនៅដល់សម័យសង្គមរាស្ត្រនិយម គឺការជ្រើសរើសមន្ត្រីរាជការស៊ីវិលនៅតែអនុវត្តតាមប្រព័ន្ធចាស់ដដែល។ ក្នុងនោះមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសតាមរយៈការប្រកួតប្រជែងដែលមាន ៤កម្រិត ទី១ ក្រមការ ទី២ អនុមន្ត្រី ទី៣ វរៈមន្ត្រី ទី៤ ឧត្តមមន្ត្រី។

ចំពោះមរតកមួយទៀតរបស់អាណានិគម គឺសាលាក្រុមវិវាទដែលបានបង្កើតឡើងក្នុងឆ្នាំ ១៩៣៣។ សាលាក្រុមវិវាទ គឺជាស្ថាប័នតុលាការដែលមានសមត្ថកិច្ចដោះស្រាយវិវាទរវាងមន្ត្រីរាជការ

[4] ASPECTS OF ADMINISTRATIVE LAW IN FRANCE, Jean-Luc GREGORCZYK, 2014

[5] មូលដ្ឋានគ្រឹះនៃការសិក្សាស្វែងយល់អំពីច្បាប់ ដោយសាស្ត្រាចារ្យ ហេង សិក្សា

ស៊ីវិល ការបង់ពន្ធដា ការបោះឆ្នោត និងបណ្តឹងទាមទារសំណងពីរដ្ឋជាដើម។ សម័យសង្គមរាស្ត្រនិយមបានបន្ត មរតកនេះដោយបានបង្កើតសាលាឧទ្ធរណ៍រដ្ឋបាលក្នុងឆ្នាំ១៩៥៣ និងកុងសីដេតាក្នុងឆ្នាំ១៩៥៧[6]។

[6] HISTORICAL DEVELOPMENT OF ADMINISTRATIVE LAW IN CAMBODIA, Yan VANDELUXE, 2014

# ជំពូកទី ២

# គោលការណ៍ដែលធានាឯករាជភាពរបស់យុត្តិធម៌

ក្នុងឋានៈជាសេវាសាធារណៈយុត្តិធម៌ត្រូវគ្រប់គ្រងឲ្យបានល្អ ដោយតាមរយៈការទាមទារនៃយុត្តិធម៌ដ៏ល្អមួយដើម្បីបំពេញបំណងនៃតម្រូវការនៃផលប្រយោជន៍ទូទៅ សកម្មភាពនៃសេវាសាធារណៈ យុត្តិធម៌ត្រូវគ្រប់គ្រងដោយគោលការណ៍ជាមូលដ្ឋានស្រដៀងគ្នានឹងគោលការណ៍ដែលទាមទារសម្រាប់ការគ្រប់គ្រងនៃគ្រប់រដ្ឋបាលផ្សេងៗទៀតដែរ។

លើសពីនេះទៅទៀត គោលការណ៍និរន្តរភាពនៃសេវាសាធារណៈយុត្តិធម៌ គោលការណ៍ផ្សេងទៀតក៏សំខាន់ដែរសម្រាប់ការគ្រប់គ្រងសកម្មភាពតុលាការ សមភាពនៅចំពោះមុខតុលាការ (ផ្នែក១) ការធានាលក្ខន្តិកៈគតិយុត្តនៃឯករាជភាពរបស់ចៅក្រម (ផ្នែក២) និងការសេរីរើជាអចិន្ត្រៃយ៍នៃអគ្គបទ (ផ្នែក៣)។

## ផ្នែកទី១ សមភាពនៅចំពោះមុខយុត្តិធម៌

ក្នុងនាមជារដ្ឋអធិបតេយ្យ យុត្តិធម៌នៃសេវាសាធារណៈគឺជាសេវាសាធារណៈពិសេសជាងគេបង្អស់នៃជនគ្រប់រូបដែលត្រូវគ្រប់គ្រងដោយក្រសួងមួយហៅថា ក្រសួងយុត្តិធម៌។ គ្រប់សេវាសាធារណៈទាំងអស់ យុត្តិធម៌ត្រូវគ្រប់គ្រងដោយផ្អែកលើ «គោលការណ៍សមភាព» មានន័យថា ជនគ្រប់រូបមានឧបនិស្ស័យត្រូវជម្រះក្តីដោយតុលាការតែមួយទៅតាមវិធានដូចគ្នា ដោយពុំមានការរើសអើងណាមួយឡើយ។ ម្យ៉ាងទៀត បណ្តឹងដែលស្ថិតក្នុងស្ថានភាពដូចគ្នា ត្រូវជម្រះក្តីដោយតុលាការតាមវិធាននីតិវិធី និងវិធានគ្រឹះតែមួយដូចគ្នា។ ដូច្នេះមិនត្រូវមានយុត្តិធម៌សម្រាប់អ្នកខ្ពង់ខ្ពស់ ហើយមួយទៀតសម្រាប់អ្នកក្រ និងមួយទៀតសម្រាប់អ្នកមាននោះទេ។ ដូចនេះយុត្តិធម៌មិនត្រូវធ្វើការបែងចែករវាងអ្នកប្តឹងផ្តល់ទៅតាមសញ្ជាតិពួកគេទេ។ គោលការណ៍នេះហាក់បីដូចជាធម្មតាទៅហើយនៅសម័យកាលយើង ប៉ុន្តែមិនមានការអះអាងបញ្ជាក់ជាលាយលក្ខណ៍អក្សរច្បាស់លាស់ទេ (កថាខណ្ឌ១) ក៏ប៉ុន្តែនេះជាគោលការណ៍មួយក្នុងចំណោមគោលការណ៍ជាមូលដ្ឋាននៃប្រសិទ្ធិផលនៃយុត្តិធម៌ ទោះបីជាមានអត្ថិភាពនៃព្រំដែនកំណត់ជាក់លាក់ក៏ដោយ។

គោលការណ៍សមភាពនៅចំពោះមុខយុត្តិធម៌មានន័យថា "ជនគ្រប់រូបមានឧបនិស្ស័យស្មើៗគ្នាក្នុងការជម្រះក្តីដោយតុលាការតែមួយ និងទៅតាមវិធាននីតិវិធីតែមួយដោយពុំមានការរើសអើងណាមួយឡើយ"។ គោលការណ៍នេះបញ្ជាក់ថា ម្នាក់ៗអាចមានលទ្ធភាពក្នុងការប្តឹងទៅតុលាការដើម្បីបញ្ជាក់ពីការប្រើប្រាស់សិទ្ធិរបស់ខ្លួន វាទាញប្រភពដើមរបស់វា (ក) ចេញដោយផ្ទាល់ពីគោលការណ៍ដែលតាមនេះយុត្តិធម៌គឺជាភាពផ្តាច់មុខរបស់រដ្ឋ។ យុត្តិធម៌គឺជាសេវាសាធារណៈមួយដែលក្នុងឋានៈនេះការចូលទៅប្រើប្រាស់មានលក្ខណៈសេរីហើយមិនត្រូវសន្មតក្នុងគ្រប់ករណីទាំងអស់ពីអាទិភាព

ក៏ដូចជាការរើសអើងនោះទេ។ ជាប្រការដែលមានន័យថាជាការទទួលយកនៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា (ខ)។

## ក. ប្រភពដើមនៃគោលការណ៍

គោលការណ៍សមភាពនៅចំពោះមុខយុត្តិធម៌ដែលហាក់បីដូចជាគោលការណ៍ធម្មជាតិអាចយល់បានប្រសើរតាមរយៈការយោងទៅនឹងស្ថានភាពដែលមាននៅក្នុងច្បាប់ខ្មែរមុនអាណានិគមបារាំង។ ក្រោមរបបរាជានិយមមុនៗ មានឯកសិទ្ធិនៃតុលាការទៅតាមវណ្ណៈសង្គមដែលអ្នកការពារស្ថិតនៅអ្នកការពារក្តីត្រូវបានជម្រះក្តីដោយតុលាការផ្សេងៗ។ គឺការរើសអើងនេះហើយដែលអាណានិគមបារាំងបានលុបបំបាត់ចោលមែនឬ?

មាត្រា៣៩ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ អះអាងបញ្ជាក់ពីគោលការណ៍នេះពង្រឹងដោយសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សឆ្នាំ១៩៤៨ ដូចចែងក្នុងមាត្រា៣១ នៃរដ្ឋធម្មនុញ្ញ។[7]

## ខ. ការទទួលយកនៃគោលការណ៍ដោយច្បាប់ខ្មែរ

ឧបសគ្គដែលធ្វើឲ្យចុះខ្សោយសមភាពនៃសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការរត់ទៅរកចៅក្រមគឺជាអំពើនៃអំណាចសាធារណៈនៅព្រះរាជាណាចក្រកម្ពុជាដែលក្នុងនោះប្រព័ន្ធនយោបាយបញ្ជាក់លក្ខណៈ ដោយមជ្ឈការ (១) គំនាបលើតុលាការ (២) ភាពមិនមានជាក់ស្តែងនៃស្ថាប័ន។

### ១. មជ្ឈការ

ប្រព័ន្ធនយោបាយខ្មែរ គឺជាប្រព័ន្ធដែលមានការ "វិវត្តន៍" នឹងមជ្ឈការ ប្រព័ន្ធនេះកសាងឡើងដោយឈរលើគំនិតចម្បងមួយដែលបញ្ជាក់ថាឯកភាព និងការកសាងជាតិដាក់បង្ខំអោយទទួលយកនូវអំណាចមួយខ្លាំងហើយផ្តាច់ការ ដែលតែងតែប្រកាន់យកដោយអង្គការនីតិប្រតិបត្តិដែលហាក់បីដូចជាមិនទទួលយកការបែងចែកនៃអំណាច ហើយទោះជាបទបញ្ញត្តិរដ្ឋធម្មនុញ្ញបែងចែកអំពីការងារនេះក៏ដោយ។[8] ចំពោះអ្នកប្តឹងផ្តល់គេខ្លាចមានការសងសឹកវិញដែលធ្វើឲ្យពួកគេមិនហ៊ានប្តឹងអាជ្ញាធររដ្ឋបាលទៅកាន់តុលាការ ហើយសុខចិត្តស្វែងរកផ្លូវចចារសម្រាប់ដំណោះស្រាយជម្លោះដែលធ្វើឲ្យប៉ះពាល់ដល់គោលការណ៍សមភាពនៅចំពោះមុខយុត្តិធម៌ ការខ្លាចក្រែងនៃការសងសឹក វាចេញមកពីមតិដែលជាទូទៅរីកសាយខ្លាំងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ហើយជាពិសេសនៅក្នុងប្រទេសកម្ពុជា តាមការខ្លាចក្រែងនេះហ៊ានប្តឹងជំទាស់នឹងរដ្ឋបាលអាចមានផលវិបាកធ្ងន់ធ្ងរវិញនៅពេលក្រោយ។ ជាការពិតការភ័យខ្លាចនេះហើយដែលពន្យល់ពីភាពកម្រនៃបណ្តឹងបែបនេះនៅព្រះរាជាណាចក្រកម្ពុជាយើង។ ជានិច្ចជាកាលប្រជាពលរដ្ឋខ្មែរស្វែងរកផ្លូវចចារ

---

[7] មាត្រា ៣១,៣៩ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣

[8] មាត្រា ៥១ នៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣

ដើម្បីដោះស្រាយជម្លោះ។ កិច្ចការមួយចំនួនដែលមិនអាចដោះស្រាយដោយអាជ្ញាធររដ្ឋបាលថ្នាក់ក្រោម (មាន មេឃុំ ចៅ សង្កាត់ អភិបាលក្រុង ស្រុក ខណ្ឌ អភិបាលរាជធានី-ខេត្ត នៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងរដ្ឋមន្ត្រីនៅរដ្ឋបាលថ្នាក់ជាតិ) ប្រជាពលរដ្ឋសុខចិត្តលើកបដាមកសុំអន្តរាគមន៍ពីនាយករដ្ឋមន្ត្រី ហើយដែលនាយករដ្ឋមន្ត្រីផ្ទាល់ពិនិត្យ និងស្តាប់បុព្វហេតុនៃបណ្តឹងដោយផ្អែកលើយុត្តិធម៌ និងសមធម៌ ហើយមិនមែនផ្អែកលើភាពតឹងរឹងនៃអត្ថបទទេ។ ការរត់ទៅរកមជ្ឈកម្មរបស់នាយករដ្ឋមន្ត្រីក្តី ព្រះមហាក្សត្រក្តី ត្រូវបញ្ជាក់ដោយតួនាទីជាប្រមុខរដ្ឋបាលកំពូលរបស់នាយករដ្ឋមន្ត្រី និងប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមរបស់ព្រះមហាក្សត្រ។ សមភាពនៅចំពោះមុខយុត្តិធម៌ត្រូវបានប៉ះពាល់នៅឡើយដោយគំនាបលើយុត្តិធម៌។

## ២. យុត្តិធម៌ក្រោមគំនាប

យុត្តិធម៌ហាក់បីដូចជាបាត់នូវរាល់ជំនឿចំពោះក្រសែភ្នែករបស់ប្រជាពលរដ្ឋខ្មែរដោយសារតែភាពលំអៀងរបស់ខ្លួន និងដោយសារដំណើរការមិនល្អរបស់ខ្លួន។ យុត្តិធម៌ស្ថិតនៅក្រោមគំនាបគ្រប់បែបយ៉ាង ជាពិសេសគំនាបពីរដ្ឋបាលផ្សេងៗទៀតពីនយោបាយ និងទឹកប្រាក់។

### ក.ទំនាក់ទំនងនៃយុត្តិធម៌ជាមួយនឹងរដ្ឋបាលផ្សេងទៀត

ជម្លោះជាច្រើនប្រឈមដាក់គ្នារវាងអ្នកមានអំណាចជាមួយចៅក្រម ជាពិសេសជាមួយព្រះរាជអាជ្ញា ជម្លោះទាំងនេះកើតនៅពេលបំពេញមុខងាររបស់ខ្លួន ឬមួយតាមរយៈការមិនគោរពច្បាប់ដែលកំណត់អំពីបុព្វសិទ្ធរបស់ខ្លួន ឬមួយតាមរយៈការបកស្រាយដោយរំលោភនៃបុព្វសិទ្ធិរបស់ខ្លួនញឹកញាប់ណាស់ដើម្បីបញ្ជាក់ថាខ្លួនត្រឹមត្រូវ។ ពួកគេលើកពីវិធានច្បាប់ដែលកំណត់ និងបញ្ជាក់អំពីសមត្ថកិច្ចរបស់ពួកគេ ស្ថានភាពនេះគឺកាន់តែធ្វើឲ្យអង្គការរបស់រដ្ឋចុះខ្សោយ។ មានគោលការណ៍ថេរដែលទទួលស្គាល់ឯករាជភាពនៃយុត្តិធម៌ និងការបែងចែកមុខងាររបស់រដ្ឋដែលទាញចេញពីរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ការយល់ដឹងដ៏ល្អនៃគោលការណ៍ទាំងនេះនឹងពិតជាអាចឲ្យជៀសផុតពីឧប្បត្តិហេតុរំខានដល់ការប្រព្រឹត្តទៅដ៏ល្អនៃរដ្ឋបាល។

### ខ.នយោបាយភាវូបនីយកម្មនៃយុត្តិធម៌

នៅក្នុងការប្រព្រឹត្តទៅនៃយុត្តិធម៌ អំណាចនយោបាយអាចផ្តល់មធ្យោបាយក្នុងការពិនិត្យមើលរឿងក្តីមួយចំនួនស្មុគស្មាញក្នុងការត្រួតពិនិត្យការប្រព្រឹត្តទៅ ព្រមទាំងដំណោះស្រាយនៃបណ្តឹងអាស្រ័យហេតុនេះហើយគេទទួលយក "យុត្តិធម៌មិនដែលត្រឹមត្រូវទាល់តែសោះ កាលណាចៅក្រមកាត់រឿងនយោបាយ"។ នយោបាយភាវូបនីយកម្មនៃយុត្តិធម៌កើតចេញពីការឡូកឡំគ្នាទាំងស្រុងនៃអំណាច ដូច្នេះទោះបីជាមានធម្មនុញ្ញភាវូបនីយកម្មនៃឯករាជភាពនៃអំណាចតុលាការក៏ដោយក៏យុត្តិធម៌តាមការអនុវត្តជាក់ស្តែងអាស្រ័យយ៉ាងខ្លាំងទៅនឹងអំណាចនីតិប្រតិបត្តិ។

គ.គំនាបនៃទឹកប្រាក់

គំនាបនៃទឹកប្រាក់មានលក្ខណៈខ្លាំងក្លា មានលក្ខណៈទូទៅប៉ះពាល់ដោយសមភាពនៅចំពោះមុខយុត្តិធម៌ធម្មតាផ្ទុយនឹងយុត្តិធម៌នយោបាយ វាស្ថិតក្នុងបរិបទរួមនៃអំពើពុករលួយទូទៅដែលមាននៅក្នុងរដ្ឋបាលខ្មែរ។

**៣.ភាពមិនមានជាក់ស្តែងនៃស្ថាប័ន**

សមភាពនៅចំពោះមុខយុត្តិធម៌ ត្រូវបានធ្វើឲ្យស្មុគស្មាញដោយភាពមិនជាក់ស្តែងនៃស្ថាប័នដែលបានបញ្ជាក់លក្ខណៈអំពីរបបនយោបាយខុសៗគ្នានៃប្រទេសកម្ពុជា។ រដ្ឋប្រហារលន់ ណល់ របបខ្មែរក្រហមដែលជាឧទាហរណ៍ដ៏ល្អ។

## ផ្នែកទី២ ការធានាលក្ខន្តិកៈគតិយុត្តនៃឯករាជភាពៈ ការការពារចៅក្រមប្រឆាំងនឹងរាល់ទម្រង់នៃគំនាប

ប្រសិទ្ធភាពនៃឯករាជភាពនៃយុត្តិធម៌តាមទ្រឹស្តីអាស្រ័យលើទំនាក់ទំនងនៃចៅក្រមជាមួយនឹងអំណាចនយោបាយតាមទស្សនៈនៃទម្លាប់ដើម្បីធានាឯករាជភាពនេះ គេបានគិតថាកាលណាតែងតាំងហើយ ចៅក្រមត្រូវទទួលបាននូវសិទ្ធិមិនអាចផ្លាស់ប្តូរបានក៏ដូចជាទទួលបាននូវវិធានទាំងអស់ដែលទាក់ទងទៅនឹងការតែងតាំង ការដាក់ពិន្ទុ ការវាយតម្លៃ និងការតម្លើងថ្នាក់។

**កថាខណ្ឌទី១ ភាពមិនអាចផ្លាស់ប្តូរបាននៃចៅក្រមអាសនៈ**

ការមិនអាចផ្លាស់ប្តូរបាន គឺជាការធានាជាធម្មតាដែលត្រូវប្រកាន់យកសម្រាប់ឯករាជភាពនៃយុត្តិធម៌។ គឺជាវិធានមួយដែលគិតពីរឿងលុបចោលរាល់ការប៉ុនប៉ងនៃគំនាបទៅលើចៅក្រមតាមរយៈការផ្លាស់ប្តូរទីកន្លែងការងារជាបន្ទាន់។ វិធាននេះត្រូវចាត់ទុកថាជាព្រំដែនផ្ទុយទៅនឹងការបញ្ចូលនៃទំនើងចិត្តទៅក្នុងរដ្ឋបាលនៃយុត្តិធម៌។ គោលបំណងរបស់វាគឺធានាចៅក្រមប្រឆាំងនឹងការបំពានដោយថាហេតុនៃអំណាចនីតិប្រតិបត្តិ វាត្រូវបានអនុម័តសម្រាប់ថ្លឹងថ្លែង ឬដើម្បីទប់ល់នឹងអំណាចតែងតាំងចៅក្រម និងការគ្រប់គ្រងអាជីពរបស់ចៅក្រមដែលស្ថិតនៅក្នុងអំណាចនីតិប្រតិបត្តិ។ ភាពមិនអាចផ្លាស់ប្តូរបានផ្តល់ទៅឲ្យចៅក្រមដែលត្រូវបានតែងតាំងឲ្យកាន់តំណែងនៅបុព្វសិទ្ធិពីរ។ ជាបឋមវាការពារចៅក្រមប្រឆាំងនឹងរាល់ការបញ្ឈប់ពីតំណែងតាមអំពើចិត្ត ប៉ុន្តែវាមិនផាត់ចេញទេទណ្ឌកម្មខាងវិន័យ។

**កថាខណ្ឌទី២ វិធានការទាក់ទងការតែងតាំង ការដាក់ពិន្ទុ ការវាយតម្លៃ និងការដំឡើងថ្នាក់ចៅក្រម**

មាត្រា១៣៤ ថ្មីនៃរដ្ឋធម្មនុញ្ញត្រង់កថាខណ្ឌទី៣ បានបញ្ជាក់ច្បាស់ថារាល់ការតែងតាំង

ចៅក្រម ព្រះរាជអាជ្ញា គឺឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាអ្នកសម្រេច និងលើកសេចក្ដីស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំងចៅក្រម ព្រះរាជអាជ្ញាអមសាលាជម្រះក្ដីទាំងអស់។[9] ចៅក្រម និងព្រះរាជអាជ្ញា ត្រូវមានបរិញ្ញាបត្រនីតិសាស្ត្រឡើងទៅ និងត្រូវឆ្លងកាត់ការប្រឡងប្រជែងដើម្បីចូលរៀននៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ដោយទទួលការបណ្ដុះបណ្ដាលរយៈពេល ២ឆ្នាំជាមុនសិនទើបទទួលបានការតែងតាំងឲ្យធ្វើជាចៅក្រម ឬព្រះរាជអាជ្ញា។ មាត្រា៨នៃច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញាចែងថា "បុគ្គលដែលត្រូវជ្រើសរើសសម្រាប់ឲ្យបំពេញមុខងារជាចៅក្រម ឬព្រះរាជអាជ្ញាត្រូវតែជាអ្នកមានសមត្ថភាព និងជាអ្នកសុចរិតមានសីលធម៌ស្អាតស្អំ"។[10] សិស្សចៅក្រមដែលបានបញ្ចប់វគ្គបណ្ដុះបណ្ដាលវិជ្ជាជីវៈដោយជោគជ័យ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យជាចៅក្រមកម្មសិក្សាក្នុងឋានន្តរស័ក្ដិជាអនុចៅក្រមថ្នាក់ដំបូងគេ ឬជាអនុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ។ ចៅក្រមកម្មសិក្សាត្រូវធ្វើកម្មសិក្សារយៈពេល១ (មួយ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការតែងតាំង។ រាល់បែបបទនៃការធ្វើកម្មសិក្សា និងសិទ្ធិអំណាចរបស់ចៅក្រមកម្មសិក្សាត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។[11] ចៅក្រមដែលបំពេញកម្មសិក្សាចប់ដោយជោគជ័យត្រូវតាំងស៊ប់ក្នុងក្របខណ្ឌចៅក្រម និងមានឋានន្តរស័ក្ដិជាអនុចៅក្រមថ្នាក់ដំបូងគេ ឬអនុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ។ ក្នុងករណីដែលពុំទទួលបានជោគជ័យក្នុងការធ្វើកម្មសិក្សា ឬអាក់ខានមិនបានបំពេញកម្មសិក្សាលើសរយៈពេល ៣០ថ្ងៃឡើងទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាចសម្រេចឲ្យចៅក្រមកម្មសិក្សាបន្តធ្វើកម្មសិក្សា ០១ (មួយ) ឆ្នាំបន្ថែមទៀត។[12]

ដូច្នេះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមលើកសេចក្ដីស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំងចៅក្រម និងព្រះរាជអាជ្ញាអមសាលាជម្រះក្ដីទាំងអស់។

យោងតាមមាត្រា ៣១ នៃច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញាចែងថារៀងរាល់សប្ដាហ៍ទី១ នៃខែមករា ចៅក្រមម្នាក់ៗត្រូវបានទទួលនូវព្រឹត្តិបត្រឯកត្តជនដែលចៅក្រមនោះ ត្រូវបំពេញតាមចំណុចសំណួរទាំងឡាយ។ ព្រឹត្តិបត្រនេះ ត្រូវដាក់ពិន្ទុដោយមានបញ្ជាក់យោបល់ និងមូលហេតុច្បាស់លាស់ដូចការអនុវត្តខាងក្រោម៖

---

[9] មាត្រា ១៣៤ ថ្មី នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣

[10] មាត្រា ៨ នៃច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា

[11] មាត្រា ២៤ នៃច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៣ ខែ ឧសភា ឆ្នាំ២០១៤

[12] មាត្រា ២៥ នៃច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤

- ចៅក្រម និងអនុប្រធានសាលាដំបូង ត្រូវដាក់ពិន្ទុដោយប្រធានសាលាដំបូង។
- ចៅក្រម និងអនុប្រធាននៃសាលាឧទ្ធរណ៍ ត្រូវដាក់ពិន្ទុដោយប្រធានសាលាឧទ្ធរណ៍។
- ប្រធានសាលាដំបូង ប្រធានសាលាឧទ្ធរណ៍ អនុប្រធាននៃតុលាការកំពូល និងចៅក្រមនៃតុលាការកំពូល ត្រូវដាក់ពិន្ទុដោយប្រធានតុលាការកំពូល។
- ចំពោះចៅក្រមដែលត្រូវបានផ្លាស់ឲ្យទៅបំពេញនៅស្ថាប័នផ្សេងៗ ត្រូវដាក់ពិន្ទុដោយប្រធានស្ថាប័ននោះ។[13]

ដូចគ្នានឹងចៅក្រមដែរ រៀងរាល់ឆ្នាំនៅសប្តាហ៍ទី១ នៃខែមករា ព្រះរាជអាជ្ញាម្នាក់ៗត្រូវទទួលបានព្រឹត្តិបត្រឯកត្តជនដែលព្រះរាជអាជ្ញានោះ ត្រូវបំពេញតាមចំណុចសំណួរទាំងឡាយ។ ព្រឹត្តិបត្រនេះត្រូវដាក់ពិន្ទុដោយមានបញ្ជាក់យោបល់ និងមូលហេតុច្បាស់លាស់ ដូចការអនុវត្តខាងក្រោមៈ

- ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូង ត្រូវដាក់ពិន្ទុដោយព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង។
- ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ ត្រូវដាក់ពិន្ទុដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។
- ព្រះរាជអាជ្ញាអមសាលាដំបូង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល ត្រូវដាក់ពិន្ទុដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។
- ចំពោះព្រះរាជអាជ្ញាដែលបានផ្លាស់ឲ្យទៅបំពេញនៅស្ថាប័នផ្សេងៗ ត្រូវដាក់ពិន្ទុដោយប្រធានស្ថាប័ននោះ។[14]

ការដំឡើងថ្នាក់នៅក្នុងមាត្រា១៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមចែងថា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមផ្តល់យោបល់ចំពោះការដំឡើងថ្នាក់ និងឋានន្តរស័ក្តិឲ្យចៅក្រម និងព្រះរាជអាជ្ញាទាំងអស់តាមបែបបទ និងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា។

---

[13] មាត្រា ៣១ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤

[14] មាត្រា ៨៧ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញាដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤

## ផ្នែកទី៣ អត្ថបទ និងនីតិវិធី

កំណែទម្រង់យុត្តិធម៌ទាមទារនូវការខិតខំប្រឹងប្រែងក្នុងការធ្វើទំនើបកម្មនៃច្បាប់ និងដាក់ឲ្យមានសង្គតិភាពនៃអត្ថបទផ្សេងៗដែលត្រូវអនុវត្ត រឿងនេះប្រព្រឹត្តទៅតាមការអនុម័តការសើរើ និងការធ្វើបច្ចុប្បន្នភាពឡើងវិញនៃអត្ថបទមួយចំនួនក៏ដូចជាការធ្វើឲ្យងាយយល់ និងការចងក្រងជាបទដ្ឋានគតិយុត្ត គឺក្នុងក្របខណ្ឌនេះហើយដែលឯករាជភាពនៃយុត្តិធម៌នៅកម្ពុជាបានឃើញនូវការរីកចម្រើនដ៏សំបើមតាមរយៈការសើរើឡើងវិញនៃអត្ថបទ និងនីតិវិធី (កថាខណ្ឌទី១) ក៏ដូចជាការធ្វើសនិទានកម្មនៃអង្គការតុលាការ (កថាខណ្ឌទី២)។

### កថាខណ្ឌទី១ ការសើរើនៃអត្ថបទ និងនីតិវិធី

ប្លុកនៃបទដ្ឋានដែលចែងអំពីវិស័យយុត្តិធម៌តំណាងនៅភាពខ្វះចន្លោះមួយចំនួនធ្វើឲ្យការប្រព្រឹត្តទៅនៃយុត្តិធម៌នេះមិនបានល្អ។ អត្ថបទមួយចំនួនទុកចោលលែងយកមកសិក្សាមានគម្លាតគ្នាបើប្រៀបធៀបទៅនឹងការវិវត្តនៃវិស័យក៏ដូចជាអត្ថបទខ្លះទៀតចាំបាច់ត្រូវធ្វើការសើរើឡើងវិញដើម្បីធានាឯករាជភាពនៃយុត្តិធម៌។

### ១. លក្ខន្តិកៈចៅក្រម

បុគ្គលដែលត្រូវបានជ្រើសរើសសម្រាប់ឲ្យបំពេញមុខងារជាចៅក្រម ត្រូវតែជាអ្នកដែលមានសមត្ថភាព និងជាអ្នកសុចរិតមានសីលធម៌ស្អាតស្អំ។

យោងតាមច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា បុគ្គលដែលត្រូវបានអនុញ្ញាតប្រលងជ្រើសរើសជាសិស្សចៅក្រម ចាំបាច់ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១. ត្រូវមានសញ្ជាតិខ្មែរពីកំណើត

២. មានអាយុ ៣៥ឆ្នាំយ៉ាងច្រើន ចំពោះបេក្ខជនជានិស្សិត និងមានអាយុ ៤០ឆ្នាំយ៉ាងច្រើន ចំពោះបេក្ខជនជាមន្ត្រីរាជការ គិតមកដល់ថ្ងៃប្រឡង

៣. ត្រូវមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រច្បាប់ឡើងទៅ

៤. មិនដែលមានទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ

៥. ត្រូវមានកាយសម្បទាគ្រប់គ្រាន់អាចបំពេញការងារបាន។[15]

[15] មាត្រា ១៩ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០១៤

ការជ្រើសរើសដើម្បីបញ្ចូលក្នុងក្របខណ្ឌចៅក្រម អាចធ្វើបានតាមរយៈការប្រឡងប្រជែងផ្ទៃក្នុង ក្នុងចំណោមមន្ត្រីរាជការ និងក្រឡាបញ្ជីត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១. មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើងទៅ

២. មានបទពិសោធន៍ក្នុងវិស័យច្បាប់ ឬយុត្តិធម៌យ៉ាងតិច ៥ឆ្នាំ

៣. មានអាយុមិនឲ្យលើសពី ៤៥ឆ្នាំគិតមកដល់ថ្ងៃប្រឡង។

ចំពោះមេធាវី ក៏អាចប្រឡងក្នុងក្របខណ្ឌនេះបានដែរ ដោយត្រូវគោរពនូវលក្ខខណ្ឌខាងលើនេះដែរ។[16]

## ២. ការសើរើក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ

ដើម្បីឆ្លើយតបនឹងតម្រូវការដែលប្រទេសកម្ពុជាយើងចង់បានក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌពេញលេញ និងច្បាស់លាស់ដើម្បីអនុវត្ត។ ចាប់តាំងពីឆ្នាំ១៩៩៤ ក្រសួងយុត្តិធម៌ដោយមានជំនួយបច្ចេកទេសសំខាន់របស់សហប្រតិបត្តិការបារាំង បានរៀបចំតាក់តែងក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌថ្មីមួយឡើង[17]ដើម្បីកែសម្រួលនីតិវិធីដែលមានស្រាប់ ជាពិសេសច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌដែលបានប្រកាសឲ្យប្រើនៅថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៣។ ក្នុងនោះក្រមទាំងពីរនេះ គឺជាឧបករណ៍ដ៏សំខាន់សម្រាប់ជាមធ្យោបាយនៃដំណើរការរបស់តុលាការផ្នែកព្រហ្មទណ្ឌ ហើយក៏ជាអត្ថបទ និងជាក្រមមូលដ្ឋាននៃការកសាងនីតិរដ្ឋនៅកម្ពុជាផងដែរ[18]។ លក្ខណៈពិសេសនៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺត្រូវបានរៀបចំឡើងដោយធានានិរន្តរភាពនៃស្ថាប័ន ក៏ដូចជារក្សានូវប្រពៃណីច្បាប់របស់ប្រទេសកម្ពុជាយើង។ ទាក់ទងនឹងគោលការណ៍នេះដែរ គឺយើងបានរៀបចំក្រមនេះឡើងដោយគោរពនូវគោលការណ៍ជាសំខាន់ជាសារវន្តដែលកំណត់នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាព្រមទាំងអនុសញ្ញា និងកតិកាសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាយើងជាភាគី ជាពិសេសសេចក្តីថ្លែងការណ៍សកលស្តីពី សិទ្ធិមនុស្សឆ្នាំ១៩៤៨ កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ១៩៦៦ ដែលទទួលស្គាល់ផងដែរដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[16] មាត្រា ២៣ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០១៤

[17] ក្រមនីតិវិធីព្រហ្មទណ្ឌបានចូលជាធរមាននៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។ ក្រមព្រហ្មទណ្ឌសព្វថ្ងៃនេះត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[18] យោងតាមប្រសាសន៍របស់ឯកឧត្តម ផូវ សំភី ក្នុងកិច្ចសម្ភាសន៍ផ្សព្វផ្សាយអំពីក្រមនីតិវិធីព្រហ្មទណ្ឌ

ជាលទ្ធផលការងារអស់រយៈពេលជាង១០ឆ្នាំ របស់ក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា ក្នុងក្របខណ្ឌនៃការចូលរួមការអនុវត្តគោលនយោបាយកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌របស់រាជរដ្ឋាភិបាលកម្ពុជា។

## កថាខណ្ឌទី២ សនិទានកម្មនៃការរៀបចំតុលាការ

សនិទានកម្មនៃអង្គការតុលាការសំដៅបង្ខិតជិតគ្នាយុត្តិធម៌របស់អ្នកប្តឹងផ្តល់ក្នុងការបង្កើតនូវសកម្មភាពតុលាការមួយ និងការពង្រាយនៃធនធានមនុស្សសម្របទៅនឹងភាពរប៉ាត់រប៉ាយនៅក្នុងទំហំនៃវិវាទរវាងអ្នកមានអំណាច និងអ្នកគ្មានអំណាច។

ត្រូវបានទទួលស្គាល់ដោយក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីដែលសំដៅទប់លំនឹងនៃភាពខ្វះខាតដែលមាននៅក្នុងក្របខណ្ឌនៃអង្គការតុលាការ ហើយដែលសម្គាល់បានដោយកង្វល់នៃការធ្វើសនិទានកម្មនៃមធ្យោបាយនៃវិស័យអត្ថបទទាំងនេះ ដោយទទួលស្គាល់គោលការណ៍ឯកទេសកម្មនៃតុលាការ និងការពង្រឹងការធានានៃនីតិវិធីចំពោះអ្នកប្តឹងផ្តល់។ ចំពោះទង្វើនេះ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការបានបញ្ចូលនូវមុខងារអគ្គលេខាធិការដ្ឋានរបស់តុលាការកំពូល និងសាលាឧទ្ធរណ៍ដែលទទួលបន្ទុកគ្រប់គ្រងហិរញ្ញវត្ថុ និងរដ្ឋបាលរបស់តុលាការសម្រាលបន្ទុកចៅក្រមចេញពីភារកិច្ចដដែលៗ ដែលជួនកាលរារាំងចៅក្រមទាំងអស់នោះក្នុងការទុកពេលការពារសេរីភាពបុគ្គល ចំពោះរឿងនេះមុខងារបង្ខិតយុត្តិធម៌របស់អ្នកប្តឹងផ្តល់សម្រួល នីតិវិធី និងបញ្ចូលនូវភាពល្បីល្បាញជាប្រយោជន៍ដល់អ្នកប្រើប្រាស់នៃសាធារណៈយុត្តិធម៌ ។

នៅក្នុងទស្សននេះ អត្រានៃសមត្ថកិច្ចរបស់តុលាការមួយចំនួនត្រូវបានពង្រីកដើម្បីអាចធានាបាននូវសិទ្ធិសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋដោយកាត់ក្តីជម្លោះទាំងឡាយដែលជាសមត្ថកិច្ចរបស់ខ្លួន ជាអ្វីដែលពន្យល់បានពីការបង្កើតនូវតុលាការពាណិជ្ជកម្មជាជំនួបតុលាការទូទៅ។ កង្វល់ដូចគ្នានៃការការពារសេរីភាពសាធារណៈក៏បានយកចិត្តទុកដាក់ផងដែរដោយអ្នកធ្វើច្បាប់ កាលណាគេបានបញ្ចូលក្រុមជំនុំជម្រះចម្រុះជាក់ស្តែងដោយផ្តើមពីតុលាការកម្រិតទី២ និងការធ្វើឲ្យជាក់ស្តែងឡើងនៃឧទ្ធរណ៍ក្នុងរឿងឧក្រិដ្ឋកម្ម ក៏ដូចជាការធ្វើស្ថាប័នភាវូបនីយកម្មនៃសភាស៊ើបសួរនៃចៅក្រមទទួលបន្ទុកតាមដានការស៊ើបសួរនៃរឿងក្តី និងចៅក្រមនៃការអនុវត្តទោស។

នៅក្នុងចំណោមអត្ថបទទាំងអស់មានអត្ថបទមួយចំនួនត្រូវបានអនុម័ត ហើយសកម្មភាពមួយចំនួនត្រូវបានសម្រេចឡើងដើម្បីការពារសេរីភាពសាធារណៈជាអាទិ៍ មានច្បាប់ស្តីពីការការពារអនីតិជន, ច្បាប់ស្តីពីការផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងអំពើពុករលួយ, ច្បាប់ស្តីពីជំនួយការផ្នែកច្បាប់ , ច្បាប់ស្តីពីសេរីភាពសារព័ត៌មាន , ច្បាប់ស្តីពីការគ្រប់គ្រងពន្ធនាគារ, ច្បាប់ស្តីពីអធិការកិច្ចតុលាការ, ព្រះរាជក្រមស្តីពីការបង្កើតក្រសួងយុត្តិធម៌ ។

បន្ទាប់ពីការសិក្សាលម្អិតនៃគោលការណ៍ធានាឯករាជភាពនៃយុត្តិធម៌ទាំងនេះ យើងត្រូវបញ្ជាក់ថា តើឯករាជភាពនេះត្រូវរៀបចំយ៉ាងដូចម្តេច? ពោលគឺអង្គការ និងមធ្យោបាយដែលរៀបចំបង្កើតឡើង និយាយរួមគឺកត្តាដែលធានាឯករាជភាពនេះ។

# ជំពូកទី៣

# កត្តាដែលធានាឯករាជភាពនៃយុត្តិធម៌

ឧត្តមគតិនៃយុត្តិធម៌មួយរឹងមាំ ហើយអាចជឿទុកចិត្តបានមិនអាចសម្រេចបានទេដោយគ្មានការរៀបចំបង្កើតនូវអង្គការដែលកំណត់ក្របខណ្ឌពីការប្រព្រឹត្តទៅរបស់វា គឺអង្គការដែលមានបំណងពិតប្រាកដក្នុងការលើកកម្ពស់សិទ្ធិបុគ្គលជាមនុស្ស។

នៅទីនេះយើងនឹងសិក្សាជាបន្តបន្ទាប់ អង្គការដែលធានាឯករាជភាពនៃយុត្តិធម៌ (ផ្នែក១) បន្ទាប់មកទៀតការធានាទាំងឡាយដើម្បីលើកកម្ពស់សិទ្ធិមនុស្ស (ផ្នែក២)។

## ផ្នែកទី១ អង្គការដែលធានាឯករាជភាពនៃយុត្តិធម៌

ការប្រកាសគោលការណ៍ឯករាជភាពនៃយុត្តិធម៌ និងការរៀបចំនៃកិច្ចធានារៀបចំលក្ខន្តិកៈរបស់ចៅក្រមនឹងមិនអាចសម្រេចបាននូវយុត្តិធម៌អព្យាក្រិតមួយហើយឯករាជ្យបានទេ បើគ្មានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (កថាខណ្ឌ១) តុលាការកំពូល (កថាខណ្ឌ៣) អាគ្គាធិការដ្ឋាននៃរដ្ឋបាលតុលាការ និងពន្ធនាគារ (៣)។

### កថាខណ្ឌទី១ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គឺជាស្ថាប័នមួយដែលជួយព្រះមហាក្សត្រក្នុងការធានាឯករាជភាពនៃអំណាចតុលាការស្របទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។[19] ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមស្ថិតក្រោមព្រះរាជធិបតីភាពនៃព្រះមហាក្សត្រ ដែលរួមមានសមាសភាពដូចខាងក្រោម[20]៖

១- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាសមាជិក
២- ប្រធានតុលាការកំពូល ជាសមាជិក
៣- អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ជាសមាជិក
៤- សមាជិក ០១ (មួយ) រូប ជ្រើសតាំងដោយព្រឹទ្ធសភា តាមមតិភាគច្រើនដាច់ខាតនៃសមាជិកព្រឹទ្ធសភាទាំងមូល ក្នុងចំណោមឥស្សរជនជាអតីតចៅក្រម ឬអតីតព្រះរាជអាជ្ញា ឬឥស្សរជនដែលមានបទពិសោធន៍ការងារ យ៉ាងតិច ១៥ ឆ្នាំ ឡើងទៅ ក្នុងវិស័យច្បាប់ ឬតុលាការ

[19] មាត្រា ១ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៤

[20] មាត្រា ៤ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៤

៥- សមាជិក ០១ (មួយ) រូប ជ្រើសតាំងដោយរដ្ឋសភា តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ក្នុងចំណោមឥស្សរជនជាអតីតចៅក្រម ឬអតីតព្រះរាជអាជ្ញា ឬឥស្សរជនដែលមានបទពិសោធន៍ការងារ យ៉ាងតិច ១៥ ឆ្នាំ ឡើងទៅក្នុងវិស័យច្បាប់ ឬតុលាការ

៦- សមាជិក ០១ (មួយ) រូប ជ្រើសតាំងដោយក្រុមប្រឹក្សាធម្មនុញ្ញ តាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ក្នុងចំណោមឥស្សរជនជាអតីតចៅក្រម ឬអតីតព្រះរាជអាជ្ញា ឬឥស្សរជនដែលមានបទពិសោធន៍ការងារយ៉ាងតិច ១៥ ឆ្នាំ ឡើងទៅ ក្នុងវិស័យច្បាប់ ឬតុលាការ

៧- សមាជិក ០១ (មួយ) រូប ជ្រើសតាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្នុងចំណោមព្រះរាជអាជ្ញាពេញសិទ្ធិទាំងអស់

៨- សមាជិក ០១ (មួយ) រូប ជាចៅក្រមនៃសាលាជម្រះក្តីជាន់ខ្ពស់ ជ្រើសតាំងតាមការបោះឆ្នោតដោយចៅក្រមនៃសាលាជម្រះក្តីជាន់ខ្ពស់

៩- សមាជិក ០១ (មួយ) រូប ជាព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាជម្រះក្តីជាន់ខ្ពស់ ឬព្រះរាជអាជ្ញាបម្រើការងារនៅក្រសួងយុត្តិធម៌ ជ្រើសតាំងតាមការបោះឆ្នោតដោយព្រះរាជអាជ្ញាបម្រើការងារនៅមហាអយ្យការអមសាលាជម្រះក្តីជាន់ខ្ពស់ និងនៅក្រសួងយុត្តិធម៌

១០- សមាជិក ០១ (មួយ) រូប ជាចៅក្រមពេញសិទ្ធិនៃសាលាដំបូង ជ្រើសតាំងតាមការបោះឆ្នោតដោយចៅក្រមពេញសិទ្ធិនៃសាលាដំបូងទូទាំងប្រទេស

១១- សមាជិក ០១ (មួយ) រូប ជាព្រះរាជអាជ្ញាពេញសិទ្ធិនៃអយ្យការអមសាលាដំបូងជ្រើសតាំងតាមការបោះឆ្នោតដោយព្រះរាជអាជ្ញាពេញសិទ្ធិនៃអយ្យការអមសាលាដំបូងទូទាំងប្រទេស។

សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទាំងអស់ខាងលើ ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌លើកសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រចំពោះកិច្ចការនេះ។

បែបបទ និងនីតិវិធីនៃការបោះឆ្នោតជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដូចមានក្នុងចំណុចទី៨ ដល់ចំណុចទី១១ នៃមាត្រានេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីទទួលបានការឯកភាពពីសមាជិកភាគច្រើននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

អាណត្តិរបស់សមាជិកជ្រើសតាំងថ្មីនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានចំនួន ០៥ (ប្រាំ) ឆ្នាំ ហើយដែលត្រូវបានបញ្ចប់នៅពេលសមាជិកជ្រើសតាំងថ្មីត្រូវបានតែងតាំង។ សមាជិកដែលត្រូវបានជ្រើសតាំងនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចឈរឈ្មោះជាថ្មីសម្រាប់អាណត្តិបន្តទៀតបាន។

សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចសម្រេចដកដំណែងសមាជិកជ្រើសតាំងណាម្នាក់បានដោយមូលហេតុនៃការរំលោភបំពានធ្ងន់ធ្ងរលើបទបញ្ញាផ្ទៃក្នុងរបស់ខ្លួន ឬធ្វើឲ្យមានការ

ប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ការសម្រេចដកតំណែងនេះត្រូវមានការយល់ព្រមពីសមាជិកយ៉ាងតិចចំនួន០៨ (ប្រាំបី) រូប នៃសមាជិកទាំងមូល។[21]

## កថាខណ្ឌទី ២ តួនាទីរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

### ១. សមត្ថកិច្ចទូទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាអ្នកសម្រេច និងលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំង ផ្លាស់ប្តូរ ផ្អាច់ពីមុខងារ ដាក់ឲ្យនៅក្រៅក្របខណ្ឌ ដាក់ឲ្យនៅទំនេរ និងការលុបឈ្មោះចៅក្រមទាំងអស់។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំង ការផ្លាស់ប្តូរ ការផ្អាច់ពីមុខងារ ការដាក់ឲ្យនៅទំនេរ ការដាក់ឲ្យនៅក្រៅក្របខណ្ឌ និងការលុបឈ្មោះព្រះរាជអាជ្ញាទាំងអស់ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវបានពិគ្រោះយោបល់ជាចាំបាច់ចំពោះសំណើខាងលើនេះ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមផ្តល់យោបល់ចំពោះការដំឡើងថ្នាក់ និងការដំឡើងឋានន្តរស័ក្តិឲ្យចៅក្រម និងព្រះរាជអាជ្ញាទាំងអស់ តាមបែបបទ និងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា។[22]

### ២. សមត្ថកិច្ចក្នុងមុខការដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា

ក្នុងមុខការដាក់វិន័យចំពោះចៅក្រម ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវប្រជុំក្រោមរូបភាពជាក្រុមប្រឹក្សាវិន័យក្រោមអធិបតីភាពនៃប្រធានតុលាការកំពូល។ ក្នុងមុខការដាក់វិន័យ ចំពោះព្រះរាជអាជ្ញា ត្រូវប្រជុំក្រោមរូបភាពជាក្រុមប្រឹក្សាវិន័យក្រោមអធិបតីភាពនៃអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។ ក្នុងករណីទាំងនេះ ព្រះមហាក្សត្រ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មិនចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាវិន័យនេះទេ។

ក្នុងករណីដែលសំណុំរឿងវិន័យទាក់ទងនឹងប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល គឺត្រូវប្រជុំក្រុមប្រឹក្សាវិន័យក្រោមអធិបតីភាពនៃព្រះមហាក្សត្រ ឬព្រះរាជតំណាង។[23]

---

[21] មាត្រា ៥ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៤

[22]មាត្រា១៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤

[23]មាត្រា ២០ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤

ចំពោះចៅក្រម ឬព្រះរាជអាជ្ញាដែលជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលកំពុងមានរឿងវិន័យពាក់ព័ន្ធនឹងខ្លួនមិនអាចចូលរួមប្រជុំក្នុងឋានៈជាក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបានឡើយ។

ត្រូវបង្កើតឲ្យមានក្រុមអធិការកិច្ចដើម្បីជួយការងាររបស់ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមក្នុងការស៊ើបអង្កេត និងស្រាវជ្រាវសំណុំរឿងវិន័យ។ សមាសភាពនៃក្រុមអធិការកិច្ចនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវតែងតាំងដោយព្រះរាជក្រឹត្យ បន្ទាប់ពីទទួលបានការសម្រេចតាមមតិភាគច្រើននៃសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ក្រុមអធិការកិច្ចនេះដឹកនាំដោយសហប្រធានដែលសហប្រធាន០១ (មួយ) រូប ត្រូវជ្រើសតាំងក្នុងចំណោមចៅក្រមដែលមានឋានន្តរស័ក្តិជាឧត្តមចៅក្រម និងសហប្រធាន ០១ (មួយ) រូបទៀត ត្រូវជ្រើសតាំងក្នុងចំណោមព្រះរាជអាជ្ញាដែលមានឋានន្តរស័ក្តិជាឧត្តមព្រះរាជអាជ្ញា។

មុខងារលម្អិតនៃការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមអធិការកិច្ចនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវកំណត់ដោយក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។[24]

ក្រុមអធិការកិច្ចបំពេញការងារតាមការចាត់តាំងរបស់ប្រធានក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ក្នុងក្របខណ្ឌនៃការបំពេញការងាររបស់ខ្លួន ក្រុមអធិការកិច្ចអាចស្នើសុំពិនិត្យសំណុំរឿងនានាដែលមានការពាក់ព័ន្ធនឹងសំណុំរឿងវិន័យ ឬមានប្រយោជន៍ដល់សំណុំរឿងវិន័យ។ ក្នុងករណីចាំបាច់ ក្រុមអធិការកិច្ចអាចស្នើសុំការបំភ្លឺពីគ្រប់បុគ្គលនានាបាន។ ចៅក្រម និងព្រះរាជអាជ្ញាដែលមិនផ្តល់កិច្ចសហការតាមការស្នើសុំរបស់ក្រុមអធិការកិច្ច ត្រូវចាត់ទុកជាកំហុសវិន័យដែលត្រូវកត់ត្រាចូលក្នុងកំណត់ហេតុអធិការកិច្ច។[25]

ចំពោះពាក្យបណ្តឹងអំពីវិន័យទាក់ទងនឹងចៅក្រម និងព្រះរាជអាជ្ញា ត្រូវដាក់នៅអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬនៅក្រសួងយុត្តិធម៌។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវចាត់ឲ្យពិនិត្យ និងស្រាវជ្រាវជាបឋមលើពាក្យបណ្តឹងទាំងនេះ ដើម្បីកសាងសំណុំរឿងវិន័យ មុននឹងសម្រេចបញ្ជូនសំណុំរឿងនេះទៅក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីចាត់នីតិវិធីបន្ត។[26]

[24] មាត្រា ២១ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៤

[25] មាត្រា ២២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៤

[26] មាត្រា ២៣ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៤

ប្រធានក្រុមប្រឹក្សាវិន័យ កោះប្រជុំក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ សំណុំរឿងវិន័យ ព្រមទាំងសំណុំឯកសារពាក់ព័ន្ធនឹងវិន័យរបស់ចៅក្រម និងព្រះរាជអាជ្ញា ត្រូវផ្ញើជូនទៅសមាជិកទាំងអស់នៃក្រុមប្រឹក្សាវិន័យយ៉ាងតិច ១០ (ដប់) ថ្ងៃ មុនថ្ងៃប្រជុំ។ ចៅក្រម ឬព្រះរាជអាជ្ញាដែលជាប់ពាក់ព័ន្ធក្នុងសំណុំរឿងវិន័យនេះ មានសិទ្ធិដឹងអំពីបទវិន័យដែលចោទប្រកាន់លើខ្លួន និងមានសិទ្ធិការពារខ្លួនដោយខ្លួនឯង ឬដោយមានជំនួយពីមេធាវីនៅចំពោះមុខក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

ការប្រជុំរបស់ក្រុមប្រឹក្សាវិន័យត្រូវធ្វើជាអសាធារណៈ។ ប្រធានក្រុមប្រឹក្សាវិន័យអាចអញ្ជើញបុគ្គលពាក់ព័ន្ធនានាឲ្យចូលរួមក្នុងការប្រជុំរបស់ខ្លួនបាន បើយល់ឃើញថាជាការចាំបាច់។ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រមទាំងបុគ្គលដែលចូលរួមប្រជុំក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវរក្សាការសម្ងាត់នៃអង្គប្រជុំ។

កូរ៉ុមប្រជុំរបស់ក្រុមប្រឹក្សាវិន័យ ត្រូវអនុវត្តដូចគ្នានឹងកូរ៉ុមប្រជុំរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដូចមានចែងក្នុងមាត្រា ១១ នៃច្បាប់នេះ។

នីតិវិធីលម្អិតសម្រាប់កិច្ចដំណើរការនៃក្រុមប្រឹក្សាវិន័យ ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។[27]

ក្នុងករណីរកឃើញកំហុស ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសម្រេចដាក់ទណ្ឌកម្មវិន័យ ដូចមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យត្រូវមានសំអាងហេតុ និងសំអាងច្បាប់។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យ ត្រូវដាក់ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដើម្បីពិនិត្យនិងសម្រេច។ សេចក្តីសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។[28]

### កថាខណ្ឌទី៣ តុលាការកំពូល

តុលាការកំពូលជាស្ថាប័នជម្រះក្តីជាន់ខ្ពស់បំផុត ហើយមានសមត្ថកិច្ចគ្របដណ្តប់លើដែនដីទាំងមូលនៃព្រះរាជាណាចក្រកម្ពុជា។ បច្ចុប្បន្ននេះ តុលាការកំពូលដឹកនាំដោយប្រធានមួយរូប និងនៅក្រោមនោះមានសភាពីរ គឺសភារដ្ឋប្បវេណី និងសង្គមកិច្ច និងសភាព្រហ្មទណ្ឌ ហើយនិងនាយកដ្ឋានបូកសរុប និងត្រួតពិនិត្យ។

[27] មាត្រា ២៥ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៤

[28] មាត្រា ២៦ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៤

តុលាការកំពូលកម្ពុជាគ្មានសិទ្ធិសើរើច្បាប់របស់អំណាចនីតិប្រតិបត្តិ ឬអំណាចនីតិបញ្ញត្តិឡើយ មានន័យថា មានសិទ្ធិត្រឹមតែអនុវត្តច្បាប់ដែលអនុម័តដោយអំណាចទាំងនេះតែប៉ុណ្ណោះ។

អមតុលាការកំពូលមានស្ថាប័នមហាអយ្យការមួយ។

ទោះបីជាតុលាការកំពូលបានបង្កើតឡើងតាំងពីខែកក្កដា ឆ្នាំ១៩៨៥ ក៏ដោយក៏តុលាការនេះទើបតែបានធ្វើការជំនុំជម្រះលើបណ្តឹងសារទុក្ខដោយខ្លួនឯងបានតិចបំផុត ហើយទើបតែមានដំណើរការពេញលេញចាប់តាំងពីខែធ្នូ ឆ្នាំ១៩៩៤ មកនេះប៉ុណ្ណោះ។

តុលាការកំពូលស្ថិតនៅរាជធានីនៃព្រះរាជាណាចក្រកម្ពុជា។ តុលាការកំពូលគឺជាស្ថាប័នជំនុំជម្រះខ្ពស់បំផុត ហើយមានសមត្ថកិច្ចគ្របដណ្តប់លើដែនដីទាំងមូលនៃព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងសម័យគ្រប់គ្រងរបស់សាធារណៈរដ្ឋប្រជាមានិតកម្ពុជា[29] ហើយបន្ទាប់មករដ្ឋកម្ពុជាបើនិយាយពីការរៀបចំ និងការចាត់តាំងតុលាការកំពូលមានប្រធាន អនុប្រធាន និងចៅក្រម។ ប្រធានតុលាការកំពូលនៅកាលណោះត្រូវបានជ្រើសតាំងដោយរដ្ឋសភាសម្រាប់អាណត្តិ៥ឆ្នាំ ហើយទទួលខុសត្រូវចំពោះមុខរដ្ឋសភា។ តួនាទីសំខាន់របស់តុលាការនេះ គឺជំនុំជម្រះបណ្តឹងជាលើកទីមួយ និងជាលើកចុងក្រោយបង្អស់នូវរឿងទាំងឡាយដែលច្បាប់កំណត់ថា ជាសមត្ថកិច្ចរបស់ខ្លួនជំនុំជម្រះ បណ្តឹងសារទុក្ខរបស់ប្រធានតុលាការកំពូល ឬរបស់អគ្គរដ្ឋអាជ្ញាពីសាលក្រមដែលមានអនុភាពអនុវត្តសម្រេចដោយសភាតុលាការកំពូល ឬដោយតុលាការខេត្តក្រុង និងយោធាពិនិត្យសាលក្រមប្រហារជីវិតមុនដាក់ជូនក្រុមប្រឹក្សារដ្ឋសម្រេច[30] និងត្រួតពិនិត្យតាមដានការងាររបស់តុលាការប្រជាជនខេត្ត ក្រុង និងយោធា។

**មហាអយ្យការអមតុលាការកំពូល**

នៅអមតុលាការកំពូលមានស្ថាប័នមហាអយ្យការមួយ ដែលមានសមាសភាពដូចខាងក្រោម៖

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- ក្រឡាបញ្ជី និង

[29] ច្បាប់ស្តីពីការបង្កើតតុលាការប្រជាជនកំពូល និងមហាអយ្យការតុលាការប្រជាជនកំពូលអនុម័តដោយរដ្ឋសភា នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា នៅថ្ងៃទី២១ ខែកក្កដា ១៩៨៥

[30] មាត្រា ១ នៃប្រកាសរបស់ក្រសួងយុត្តិធម៌ លេខ៥០៩ ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៩៨២ ដែលដកស្រង់ចេញពីសៀវភៅកិច្ចសន្យា និងតុលាការ។

- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅមហាអយ្យការអមតុលាការកំពូល។[31]

នៅមហាអយ្យការអមតុលាការកំពូលមានការបែងចែកជា ៣នាយកដ្ឋាន គឺនាយកដ្ឋានស៊ើបអង្កេត និងការត្រួតពិនិត្យការស៊ើបអង្កេត នាយកដ្ឋានព្រហ្មទណ្ឌ និងនាយកដ្ឋានរដ្ឋប្បវេណី។

### ក. នាយកដ្ឋានស៊ើបអង្កេត និងការត្រួតពិនិត្យការស៊ើបអង្កេត

ជាជំនួយមហាអយ្យការក្នុងភារកិច្ចត្រួតពិនិត្យនីត្យានុកូលនៃការស៊ើបអង្កេតពិនិត្យមើលឯកសាររបស់ស្ថាប័ន ឬអង្គការស៊ើបអង្កេតដែលទាក់ទងដល់បទល្មើស និងការបំពានច្បាប់ធ្វើការស៊ើបអង្កេតដោយខ្លួនឯងផ្ទាល់ ក្នុងករណីចាំបាច់ ឬធ្វើការស៊ើបអង្កេតបន្ថែម។

### ខ. នាយកដ្ឋានព្រហ្មទណ្ឌ

ជំនួយការ និងទទួលខុសត្រូវចំពោះអគ្គព្រះរាជអាជ្ញាចំពោះរឿងប្រើសិទ្ធិអយ្យការនៅក្នុងនីតិវិធីព្រហ្មទណ្ឌ (ដូចជាអានលិខិតចោទប្រកាន់) ធ្វើសេចក្ដីសន្និដ្ឋានដេញដោលសួរ ការតាំងខ្លួនជាគូក្ដីដើម ការចោទប្រកាន់ ឬការដកការចោទប្រកាន់ត្រួតពិនិត្យតាមដានការអនុវត្តសាលក្រមព្រហ្មទណ្ឌជាដើម។

### គ. នាយកដ្ឋានរដ្ឋប្បវេណី

ជាជំនួយការ និងទទួលខុសត្រូវចំពោះអគ្គព្រះរាជអាជ្ញាក្នុងការងារដែលទាក់ទិនរឿងវិវាទរដ្ឋប្បវេណីដូចជា រឿងដែលប៉ះពាល់ដល់ផលប្រយោជន៍រដ្ឋ អនីតិជន ជនអសមត្ថភាព។ នាយកដ្ឋាននេះ ត្រូវប្រមែប្រមូលព័ត៌មានភស្តុតាងទាំងឡាយដើម្បីត្រៀមនៅក្នុងសវនាការដែលពាក់ព័ន្ធដល់រឿងក្ដីខាងលើដើម្បីឲ្យតំណាងអគ្គព្រះរាជអាជ្ញាឡើងថ្លែងសេចក្ដីសន្និដ្ឋានក្នុងសវនាការ។

យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា តុលាការគ្រប់ជាន់ថ្នាក់ស្ថិតនៅក្រោមដំបូលរបស់ដំបូលនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម រីឯអយ្យការស្ថិតនៅក្រោមឱវាទរបស់ក្រសួងយុត្តិធម៌។ តុលាការមានសមត្ថកិច្ចជំនុំជម្រះ រីឯអយ្យការជាអ្នកធ្វើបណ្ដឹងអាជ្ញាធ្វើការចោទប្រកាន់ មិនចោទប្រកាន់ និងជាគូក្ដីដើមនៅក្នុងរឿងព្រហ្មទណ្ឌ ព្រមទាំងរឿងរដ្ឋប្បវេណីមួយចំនួនដែលពាក់ព័ន្ធទៅនឹងសណ្ដាប់ធ្នាប់សាធារណៈ និងគូក្ដី (រដ្ឋប្បវេណី)។[32]

[31] មាត្រា ៦៨ នៃច្បាប់ស្ដីពីអង្គការតុលាការ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤

[32] ដកស្រង់ចេញពីសៀវភៅកិច្ចសន្យា និងតុលាការ

## កថាខណ្ឌទី៤ អាគ្គាធិការនៃរដ្ឋបាលតុលាការ និងពន្ធនាគារ

### ក. អង្គភាពរដ្ឋបាលតុលាការ

ផ្អែកតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ បានកំណត់ឲ្យមានអង្គភាពរដ្ឋបាលតុលាការសម្រាប់សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់។ ការបង្កើតអង្គភាពរដ្ឋបាលតុលាការនេះឡើង គឺជាការចាប់ផ្តើមដ៏សំខាន់ និងជាដំណាក់កាលថ្មីមួយលើការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។ ក្នុងនោះអង្គភាពរដ្ឋបាលតុលាការបានចូលរួមចំណែកក្នុងការកសាង និងពង្រឹងក្របខណ្ឌគតិយុត្តសម្រាប់កិច្ចការការងាររបស់តុលាការ និងអយ្យការក៏ដូចជាតម្រូវការចំពោះមុខក្នុងការពង្រឹងយន្តការគ្រប់គ្រងការងាររដ្ឋបាលនៃសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ដើម្បីធានាគុណភាព ប្រសិទ្ធិភាព តម្លាភាពគណនេយ្យភាពនៃការផ្តល់សេវាយុត្តិធម៌ សំដៅបង្កើនជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋលើស្ថាប័នយុត្តិធម៌ និងស្ថាប័នរដ្ឋដែលជាកត្តាចម្បងក្នុងការធានាសន្តិភាព និងស្ថិរភាពសង្គម។

ក្នុងគោលបំណងលើកកម្ពស់ការផ្តល់សេវាយុត្តិធម៌ ដែលជាផ្នែកមួយនៃសេវាសាធារណៈសម្រាប់សាធារណៈជនគ្រប់រូប លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងត្រូវបានបង្កើតឡើងជាជំនួយឱ្យសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត សម្រាប់សាលាជម្រះក្តីជាន់ទាប។ ចំណែកអង្គភាពរដ្ឋបាលតុលាការសម្រាប់សាលាជម្រះក្តីជាន់ខ្ពស់ គឺមានឈ្មោះថា អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ សម្រាប់ជំនួយឲ្យសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ និងអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល សម្រាប់ជំនួយឲ្យតុលាការកំពូល និងមហាអយ្យការអមតុលាការ។ លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង និងអគ្គលេខាធិការដ្ឋានរដ្ឋបាល សាលាឧទ្ធរណ៍ និងតុលាការកំពូល គឺជាច្រករដ្ឋបាលចេញចូលតែមួយ និងជាកន្លែងដែលប្រជាពលរដ្ឋអាចប្រើប្រាស់ និងទំនាក់ទំនងបាន។

### ខ. អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ

ផ្អែកតាមអនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌។ អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ មានតួនាទីជាសេនាធិការឲ្យក្រសួងលើការងារសម្របសម្រួល គ្រប់គ្រង និងត្រួតពិនិត្យអង្គភាពរដ្ឋបាលរបស់អង្គការតុលាការ និងអង្គការអយ្យការ រួមទាំងកិច្ចការសាធារណៈរដ្ឋបាល នីតិវិធីកិច្ចការហិរញ្ញវត្ថុ កិច្ចការបុគ្គលិក ការងារស្រាវជ្រាវ ផ្សព្វផ្សាយ បណ្តុះបណ្តាលច្បាប់លើវិស័យរដ្ឋបាលតុលាការ និងជម្រុញការប្រើប្រាស់បច្ចេកវិជ្ជាជាឧបករណ៍ជំនួយឲ្យការងាររដ្ឋបាល ការចុះបញ្ជី និងការគ្រប់គ្រងសំណុំរឿង ក្នុងគោលបំណងលើកកម្ពស់ និងធានានូវដំណើរការល្អនៃយុត្តិធម៌។ [33]

---

[33] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤

ភារកិច្ចចម្បងរបស់នាយកដ្ឋានកិច្ចការរដ្ឋបាលនៃសាលាជម្រះក្តីទទួលបន្ទុកដូចជា ការសម្របសម្រួល និងគ្រប់គ្រងសេវាគាំទ្រផ្នែករដ្ឋបាលដល់កិច្ចដំណើរការរបស់អង្គការតុលាការ និងអង្គការអយ្យការ។ ធានាប្រសិទ្ធិភាព សុវត្ថិភាពរដ្ឋបាល សណ្តាប់ធ្នាប់ និងគ្រប់គ្រងការងារសង្គមរបស់អង្គការតុលាការ និងអង្គការអយ្យការ។ ទទួលចងក្រង តម្កល់ទុក និងបោះពុម្ពផ្សាយនូវរបាយការណ៍ ស្ថិតិ និងទិន្នន័យអំពីការងារបុគ្គលិក ការងាររដ្ឋបាល និងហិរញ្ញវត្ថុរបស់អង្គភាពរដ្ឋបាលតុលាការ។ ត្រួតពិនិត្យលើកិច្ចដំណើរការរដ្ឋបាលរបស់អង្គភាពរដ្ឋបាលនៃអង្គការតុលាការ និងអង្គការអយ្យការ។ ពិនិត្យ និងផ្តល់យោបល់លើការតវ៉ា ឬពាក្យសុំអន្តរាគមន៍ទាំងឡាយដែលពាក់ព័ន្ធនឹងអង្គភាពរដ្ឋបាលតុលាការ ព្រមទាំងអាចចុះធ្វើអធិការកិច្ចតាមការចាំបាច់។[34]

## ផ្នែកទី២ ការលើកកម្ពស់សិទ្ធិមនុស្ស

ការការពារសេរីភាពបុគ្គលគឺជាបេសកកម្មទីមួយនៃស្ថាប័នតុលាការ។ យុត្តិធម៌ត្រូវតែជាកំពែង ការពារប្រឆាំងនឹងទំនើងចិត្តរបស់រដ្ឋបាល ការប៉ះពាល់ដល់បូរណភាពរូបកាយ និងសីលធម៌របស់បុគ្គលដែលជាទូទៅរាល់ការប៉ះពាល់ដល់ការប្រើប្រាស់សិទ្ធិ ដូច្នេះហើយរាល់កំណែទម្រង់យុត្តិធម៌ត្រូវមានគោលដៅទីមួយក្នុងការពង្រឹងយុត្តិធម៌ក្នុងបេសសកកម្មរបស់ខ្លួន និងការធានាការគោរពសិទ្ធិ។ ក្របខណ្ឌគតិយុត្តិដែលចែងអំពីវិស័យតុលាការ ត្រូវនិយាយពីការធានាចាំបាច់សម្រាប់បុគ្គលដែលប្រឈមនឹងនីតិវិធីព្រហ្មទណ្ឌ។ ការធានាទាំងនេះទាក់ទងជាពិសេសទៅនឹងការប្រព្រឹត្តទៅនៃការប្តឹងផ្តល់ និងលក្ខខណ្ឌនៃការឃុំខ្លួនបន្ទាប់មកទៀតការចូលទៅកាន់ច្បាប់ និងយុត្តិធម៌។

### កថាខណ្ឌទី១ ការធានាបណ្តឹងមួយប្រកបដោយសមធម៌ និងការគោរពសិទ្ធិការពារខ្លួន

ទោះបីជារដ្ឋធម្មនុញ្ញមិនបានយោងស្តែងចេញច្បាស់លាស់ទៅនឹងសិទ្ធិទទួលបានបណ្តឹងប្រកបដោយសមធម៌មួយក៏ដោយក៏រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ចែងពីបទបញ្ញត្តិមួយចំនួនដែលទទួលស្គាល់ដោយតុណ្ហីភាព ជាពិសេសមាត្រា៣៨ វាក្យខណ្ឌទី៧ នៃរដ្ឋធម្មនុញ្ញដែលចែងពីសច្ចធារណ៍នៃការគ្មានទោសពៃ។

ម្យ៉ាងទៀតក្រមនីតិវិធីព្រហ្មទណ្ឌចែងពីបទបញ្ញត្តិមួយចំនួនដែលពង្រឹងដល់សិទ្ធិក្នុងការទទួលបាននូវបណ្តឹងមួយប្រកបដោយសមធម៌តាមការទទួលស្គាល់ និងសិទ្ធិដែលត្រូវបានជួយដោយមេធាវី ក៏ប៉ុន្តែការអនុវត្តជាក់ស្តែងបានច្រានយុត្តិធម៌អោយឆ្ងាយចេញពីតួនាទីរបស់ខ្លួនក្នុងការការពារសេរីភាពបុគ្គល។ ម្យ៉ាងការចាប់ខ្លួនតាមអំពើចិត្តធ្វើឡើងនៅក្នុងការមាក់ងាយទាំងស្រុងនៃ

---

[34] មាត្រា ១៥ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤

នីតិវិធីតុលាការដែលបានទទួលស្គាល់ហើយម្យ៉ាងទៀតសេចក្តីសម្រេចរបស់តុលាការក្លាយជាឧបករណ៍គំនាបនយោបាយ មួយនៅក្នុងដៃនៃអង្គការនីតិប្រតិបត្តិ។

### កថាខណ្ឌទី២ រដ្ឋបាលពន្ធនាគារ

ពន្ធនាគារ គឺជាកន្លែងដែលបង្កើតឡើងស្របច្បាប់ សម្រាប់ឃុំអ្នកទោសតាមអំណាចនៃដីកា ឬការវិនិច្ឆ័យសម្រេចត្រឹមត្រូវតាមច្បាប់ស្តីពីតុលាការមានសមត្ថកិច្ច។ ពន្ធនាគារមិនមែនជាកន្លែងសម្រាប់ស៊ើបអង្កេត ស្រាវជ្រាវ សួរចម្លើយ ឬធ្វើទារុណកម្ម និងមិនមែនជាកន្លែងប្រើប្រាស់សម្រាប់ឃុំខ្លួនជនសង្ស័យរយៈពេល ៤៨ម៉ោងនោះដែរ[35]។ ផ្ទុយទៅវិញ ពន្ធនាគារជាកន្លែងអប់រំធ្វើការកែប្រែកសាងនីតិសម្បទា ហ្វឹកហ្វឺនអ្នកទោសឲ្យកសាងខ្លួនជាថ្មីប្រកបដោយសុខភាព ចេះយល់ពីបញ្ហាសង្គម មានវិជ្ជាជីវៈដើម្បីចិញ្ចឹមជីវិតក្នុងសហគមន៍ប្រកបដោយសមធម៌ត្រឹមត្រូវ ព្រមទាំងចេះស្រលាញ់ និងលើកស្ទួយជីវភាពគ្រួសាររបស់ខ្លួនឯង និងចូលរួមអភិវឌ្ឍន៍សហគមន៍។

ដោយយោងតាមនីតិវិធីពន្ធនាគារនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៩ ការគ្រប់គ្រងពន្ធនាគារត្រូវអនុលោមតាមរដ្ឋធម្មនុញ្ញស្របតាមគោលការណ៍របស់ក្រសួង និងនីតិវិធី ព្រមទាំងគោលការណ៍របស់នាយកដ្ឋានពន្ធនាគារ ជាពិសេសត្រូវស្របទៅនឹងគោលការណ៍សិទ្ធិមនុស្សជាសកលដែលយើងនឹងធ្វើការសិក្សាអំពីភារកិច្ចរបស់នាយកដ្ឋាន និងពន្ធនាគារ។

#### ក. ភារកិច្ចនាយកដ្ឋានពន្ធនាគារ

- គ្រប់គ្រងពន្ធនាគារកណ្តាល និងពន្ធនាគាររាជធានី-ខេត្តទាំងអស់ឲ្យស្របតាមច្បាប់ និងគោលការណ៍សិទ្ធិមនុស្ស។
- រៀបចំសេចក្តីព្រាងប្រកាស នីតិវិធី បទបញ្ជាសម្រាប់គ្រងគ្រងពន្ធនាគារ គ្រប់គ្រងអ្នកទោសទូទាំងប្រទេស។
- កំណត់ចំនួនអ្នកទោសដែលអាចទទួលយកបានក្នុងពន្ធនាគារនីមួយៗ
- ណែនាំ ដឹកនាំ បញ្ជា និងត្រួតពិនិត្យលើការងារការពារពន្ធនាគារ ការពារអ្នកទោស
- សហការជាមួយក្រសួងយុត្តិធម៌ សុខាភិបាល និងក្រសួងពាក់ព័ន្ធ
- ណែនាំ និងត្រួតពិនិត្យមើលតាមការកំណត់របស់រាជរដ្ឋាភិបាល និងក្រសួង
- ផ្គត់ផ្គង់របបហូបចុក សម្ភារប្រើប្រាស់ ការស្នាក់នៅ ការព្យាបាលសុខភាព និងការរក្សាអនាម័យ ព្រមទាំងគោលរបបឧបត្ថម្ភផ្សេងៗទៀតដល់អ្នកទោស

[35] យោងប្រកាសលេខ ២១៧ ប្រ.ក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការគ្រប់គ្រងពន្ធនាគារ

- ត្រួតពិនិត្យ ដឹកនាំ និងលើកសំណើលើគម្រោងការងារគ្រប់គ្រងឯកសារ ការងារបុគ្គលិក ការងារគណនេយ្យ-ភស្តុភារ និងការងារសំណង់ស្ថាបនាពន្ធនាគារ។

## ខ. ភារកិច្ចរបស់ពន្ធនាគារ

- ប្រធានពន្ធនាគារនីមួយៗត្រូវរៀបចំតាក់តែង បទបញ្ជាផ្ទៃក្នុងពន្ធនាគាររបស់ខ្លួន ហើយស្នើសុំការសម្រេចពីប្រធាននាយកដ្ឋានពន្ធនាគារ។

- ប្រធានពន្ធនាគារត្រូវទទួលខុសត្រូវដោយផ្ទាល់ ក្នុងការគ្រប់គ្រងពន្ធនាគារឲ្យបានត្រឹមត្រូវតាមនីតិវិធី និងបទបញ្ជាផ្ទៃក្នុងដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

- ប្រធាននាយកដ្ឋានត្រូវរាយការណ៍ជាបន្ទាន់ទៅព្រះរាជអាជ្ញា គណៈអភិបាលរាជធានី ខេត្ត និងអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារអំពីព័ត៌មាន ឬឧប្បត្តិហេតុទាំងឡាយណាដែលគំរាមកំហែង ឬដែលអាចគំរាមកំហែងដល់សន្តិសុខសុវត្ថិភាពពន្ធនាគារ។

- ប្រធានពន្ធនាគារអាចអនុញ្ញាតឲ្យមន្ត្រីពន្ធនាគារដែលបានបណ្ដុះបណ្ដាលហ្វឹកហាត់ត្រឹមត្រូវឲ្យប្រើប្រាស់អាវុធ និងឧបករណ៍បច្ចេកទេសដើម្បីធានាសន្តិសុខសុវត្ថិភាពក្នុងកិច្ចប្រតិបត្តិការរបស់ពន្ធនាគារ។

- ប្រធានពន្ធនាគារត្រូវចាត់វិធានការ ក្នុងការទទួលឃុំឃាំង និងដោះលែងអ្នកទោស និងធានាអនុវត្តការងារដោយអនុលោមតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងគោលនយោបាយរបស់ក្រសួងមហាផ្ទៃ ព្រមទាំងគោលការណ៍ និងនីតិវិធីផ្សេងៗរបស់អគ្គនាយកដ្ឋានរដ្ឋបាល។

ទោះបីជាមានច្បាប់ និងលិខិតដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការគ្រប់គ្រងពន្ធនាគារក៏ដោយក៏រដ្ឋបាលពន្ធនាគារនៅតែជួបបញ្ហាប្រឈមជាច្រើនដូចជា ហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់ បញ្ហាខ្វះមធ្យោបាយដឹកជញ្ជូនទៅមកតុលាការ និងពន្ធនាគារ ជាពិសេសភាពចង្អៀតណែននៃចំនួនអ្នកទោសក្នុងពន្ធនាគារ។[36]

## កថាខណ្ឌទី៣ ការចូលទៅប្រើសិទ្ធិ និងយុត្តិធម៌

ការទទួលបានសិទ្ធិ និងយុត្តិធម៌ត្រូវធានាចំពោះជនគ្រប់រូបដោយសារស្ថានភាពជាលក្ខណៈសម្ភាររបស់ពួកគេស្ថិតនៅក្នុងភាពមិនអាចអនុវត្តក្នុងការប្រើសិទ្ធិរបស់ខ្លួននៅចំពោះមុខតុលាការដូច្នេះ ហើយត្រូវបង្កើតផងដែរនូវរបបជំនួយខាងផ្នែកច្បាប់ និងតុលាការជាប្រយោជន៍ដល់ជនក្រីក្រដែលធ្វើឲ្យមានភាពជាក់ស្ដែងឡើងក្នុងការឈានទៅទទួលសិទ្ធិ និងយុត្តិធម៌។ របបនេះប្រព្រឹត្តទៅតាមការទទួលបន្ទុកនៃអ្នកប្ដឹងផ្ដល់ដែលជាជនក្រីក្រដោយធានាចំពោះពួកគេក្នុងការចូលទៅ

[36] របាយការណ៍ស្ដីពីសិទ្ធិនៅលើការទិញដូរៈ ជីវិតនៅក្នុងពន្ធនាគារកម្ពុជា

កាន់ការប្រើប្រាស់សិទ្ធិដែលសិទ្ធិនេះត្រូវធានាក្នុងអំឡុងនីតិវិធីតុលាការ និងដើម្បីទទួលបាននូវការអនុវត្តសេចក្ដីសម្រេចរបស់តុលាការ។

# ជំពូកទី៤

# ឆ្ពោះទៅរកទំនើបកម្មនៃប្រព័ន្ធតុលាការ

## ផ្នែកទី១ ទំនើបកម្មនៃរចនាសម្ព័ន្ធ និងរបៀបនៃដំណោះស្រាយជម្លោះ

យុត្តិធម៌មួយឯករាជ្យដែលមានឃ្លាំងច្បាប់សមស្រប ហើយដែលមានធនធានមនុស្សដែលមានគុណភាព និងគ្រប់គ្រាន់អាចបំពេញបេសកកម្មពេញលេញរបស់ខ្លួនបានប្រសិនបើក្របខណ្ឌដែលក្នុងនោះវាប្រព្រឹត្តទៅមិនធានាចំពោះវាបាននូវលក្ខខណ្ឌនូវការងារសមស្រប។ លក្ខខណ្ឌការងារទាំងនោះបញ្ជាក់បានពីអត្ថិភាពនៃហេដ្ឋារចនាសម្ព័ន្ធសមស្របទំនើប និងសម្របបានទៅនឹងតម្រូវការនៃការបែងចែកដ៏ល្អនៃយុត្តិធម៌ ការប្រព្រឹត្តទៅដ៏ល្អនៃផ្នែកនេះដំណើរការបានផងដែរ ដោយការបំពាក់គ្រឿងសម្ភារសមស្របនៃតុលាការ ទីធ្លាតុលាការ ....។

កិច្ចខិតខំប្រឹងប្រែងយល់ព្រមសម្រាប់កំណែទម្រង់យុត្តិធម៌ ត្រូវសំដែងផងដែរដល់ទំនើបកម្មនៃវិស័យនេះ តាមការអនុម័តនយោបាយមួយស្តីពីការទំនាក់ទំនងសមស្របការបញ្ចូលបច្ចេកវិទ្យាថ្មី (កថាខណ្ឌទី១) និងការជម្រុញឲ្យមានរបៀបដោះស្រាយខុសគ្នា(ផ្នែកទី២) ។

### កថាខណ្ឌទី១ ហេដ្ឋារចនាសម្ព័ន្ធ និងការបំពាក់គ្រឿងសម្ភារ

ក្រសួងយុត្តិធម៌ត្រូវធានាឲ្យមានយុត្តិធម៌សម្រាប់បុគ្គលគ្រប់រូបចំពោះមុខច្បាប់ ធានាឲ្យមានការអនុវត្តច្បាប់ និងសេចក្តីសម្រេចទាំងឡាយរបស់តុលាការ និងអយ្យការគ្រប់ជាន់ថ្នាក់ តាមដានត្រួតពិនិត្យការអនុវត្តច្បាប់ សាលក្រម សាលដីកា និងសេចក្តីសម្រេចទាំងឡាយរបស់តុលាការ និងអយ្យការគ្រប់ជាន់ថ្នាក់ធ្វើអធិការកិច្ចក្នុងករណីមានបណ្តឹងតវ៉ាពីរូបវន្តបុគ្គល ឬនីតិបុគ្គលដែលកើតឡើងនៅតាមតុលាការ និងស្ថាប័នអយ្យការគ្រប់ជាន់ថ្នាក់ ត្រួតពិនិត្យមន្ទីរឃុំឃាំង និងពន្ធនាគារក្នុងការអនុវត្តច្បាប់ និងគ្រប់គ្រង ព្រមទាំងចេញសម្រង់លិខិតថ្កោលទោស[37]។

#### ក. អាគារ និងសំណង់

ស្ថានភាពបច្ចុប្បន្នចំពោះអាគារ និងសំណង់តុលាការពុំមានការខូចខាតខ្លាំង ឬខ្វះខាតអ្វីឡើយ។ សំណង់អាគារតុលាការត្រូវបានរៀបចំធ្វើថ្មីស្ទើរតែទាំងអស់ទូទាំងប្រទេស ដោយឡែកសំណង់អាគារតុលាការខេត្តខ្លះក៏មានមានលក្ខណៈចាស់ ហើយដែលកំពុងនឹងដំណើរការក្នុងការសាងសង់ផងដែរ។ ប៉ុន្តែនៅតាមសាលាដំបូងខេត្តមួយចំនួនតូច អាគារចាស់ៗ ប៉ុន្តែខេត្តមួយចំនួនត្រូវបានសាងសង់ក៏ដូចជាកំពុងតែសាងសង់។

[37] កម្រងព័ត៌មានសេវាសាធារណៈ ចង្កោមសេវាទី៣ សេវាពាក់ព័ន្ធយុត្តិធម៌ និងអាជ្ញាកណ្តាល

សាលាដំបូងរាជធានី-ខេត្តមានចំនួន២៥ ទូទាំងប្រទេស រាប់បញ្ចូលទាំងសាលាដំបូងខេត្តត្បូងឃ្មុំដែលទើបតែបង្កើតថ្មី។ សំណង់អាគារនៅតាមសាលាដំបូងខ្លះសមស្រប សំណង់អាគារខ្លះឃើញថា មិនទាន់សមស្រប ដូចដែលបានលើកឡើងខាងលើគឺសាលាដំបូងខេត្តត្បូងឃ្មុំជាដើមដែលមិនទាន់បានសមស្របនៅឡើយដោយហេតុមិនទាន់រកទីតាំងសមស្របបាន។

រីឯពន្ធនាគាររាជធានី-ខេត្តមានចំនួន២៥ ទូទាំងប្រទេស។ ពន្ធនាគារនៅតាមបណ្តាខេត្តមួយចំនួនមានការខ្វះខាត ហើយពន្ធនាគារដែលមានសព្វថ្ងៃនេះនៅមានភាពតូចចង្អៀតនៅឡើយនៃចំនួនអ្នកទោសដែលធ្វើឲ្យប៉ះពាល់ដល់ទណ្ឌិតដែលត្រូវជាប់ឃុំ។

### ខ. ការធ្វើទំនើបកម្ម

ជាយុទ្ធសាស្ត្រអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ត្រូវចេញពីស្ថាននៃទីកន្លែងឲ្យបានសព្វគ្រប់ដូចដែលបានលើកអត្ថាធិប្បាយខាងលើ កម្មវិធីនឹងគិតគូដល់ការគោរពនៃនីតិវិធីបែងចែកតួនាទីភារកិច្ចការតាមដាន និងការអនុវត្តលទ្ធកម្មការងារសាងសង់។

ការធ្វើឲ្យកាន់តែប្រសើរឡើងនៃឧទ្យានដែលមានស្រាប់តាមការផ្តល់នីតិសម្បទាឡើងវិញ និងការលាតសន្ធឹងអាគាររបស់រដ្ឋ ត្រូវផ្តល់នីតិសម្បទាឡើងវិញបន្ទាន់។ នៅក្នុងក្របខណ្ឌនៃការធ្វើឲ្យសម្រេចនៃស្ថានទីកន្លែងគឺជាដំណាក់កាលកំហិតមួយ ដូច្នេះត្រូវប្រមូលព័ត៌មានទាំងអស់ និងទិន្នន័យដែលមានស្រាប់ដើម្បីវាយតម្លៃលើផ្នែក និងវិសាលភាពនៃការងារផ្តល់នីតិសម្បទាឡើងវិញដែលត្រូវសម្រេចឲ្យបាន។ ចំពោះអាគារ និងសំណង់របស់តុលាការត្រូវធ្វើបច្ចុប្បន្នភាពនៃស្ថានភាពដោយចុះទៅមើលផ្ទាល់ក្នុងការសម្រេចស្ថាននៃទីកន្លែងក្នុងភាពលម្អិតឲ្យបាន។

ស្ថានទីកន្លែងនេះ ក្នុងរយៈពេលមធ្យមអាចឲ្យកំណត់បានពីស្ថានភាពសង្ខេបមួយនៃការងារផ្តល់នីតិសម្បទាឡើងវិញដែលត្រូវសម្រេចដោយបញ្ជាក់ពីប្រភេទនៃការ្យ (សេវារដ្ឋបាលតុលាការកំពូល សាលាដំបូង ពន្ធនាគារ) ការពិពណ៌នាការងារសាងសង់ ផែនការ និង "ឬគំនិតបំព្រួញ ថ្លៃបង្ការក៏ដូចជាប្រតិទិនបង្ការស្តីពីការអនុវត្តការងារសាងសង់"។ ការងារផ្តល់នីតិសម្បទាឡើងវិញគួរតែបញ្ចូលគោលដៅនៃការកំណត់មុខងារអាគារ និងសំណង់ ការដាក់ឲ្យត្រូវបទដ្ឋាន និងគំនិតនៃស្ថាបត្យកម្មគំរូដែលបញ្ជាក់បានអំពីលក្ខណៈពិសេសរបស់វា ការងារទាំងនោះនឹងគិតគូទៅលើតម្រូវការពិសេសនៃរចនាសម្ព័ន្ធផ្សេងៗ។

ការបំពាក់សម្ភារគឺចាំបាច់សម្រាប់រយៈពេលខ្លី ចំពោះការប្រព្រឹត្តដ៏ល្អនៃរចនាសម្ព័ន្ធរបស់តុលាការ គេអាចលើកឡើងបានជាពិសេស ការិយាល័យព័ត៌មានវិទ្យា ការបំពាក់ម៉ាស៊ីនត្រជាក់ និងកង្ហារ មធ្យោបាយទំនាក់ទំនង និងសន្តិសុខ មធ្យោបាយដឹកជញ្ជូន (រថយន្ត ម៉ូតូ ឡានពេទ្យ)។

ចំពោះពន្ធនាគារគួរតែពង្រីក និងបង្កើតបន្ទប់ឃុំឃាំងឲ្យទូលាយដើម្បីសមាមាត្រទៅនឹងចំនួនអ្នកទោសដែលជាប់ឃុំឃាំងនៅពេលបច្ចុប្បន្ន ក្នុងនោះគួរតែបែងចែកការឃុំខ្លួនឲ្យដាច់រវាងអ្នកជាប់ទោសបទឧក្រិដ្ឋ និងបទមជ្ឈិម ដើម្បីការពារនូវសណ្តាប់ធ្នាប់សង្គមអាចធានាឲ្យទណ្ឌិតចុះចូល និងស្តារនីតិសម្បទានៅក្នុងសង្គមវិញបាន។

## ផ្នែកទី២ ទំនើបកម្មនៃយុត្តិធម៌ និងការជម្រុញរបៀបឆ្លាស់គ្នានៃដំណោះស្រាយជម្លោះ

ការទាមទារនីតិរដ្ឋបញ្ជាក់បានពីទំនើបកម្មជាប្រចាំនៃវិស័យតុលាការ។ ទំនើបកម្មនេះ តម្រូវឲ្យសម្របតុលាការទៅនឹងការកំណត់កំហិតក្នុងការធានានូវសេវាសាធារណៈមួយដោយឆ្លើយតបទៅនឹងការរង់ចាំរបស់អ្នកប្រើប្រាស់។ ចំពោះទង្វើនេះចាំបាច់ប្រើបច្ចេកទេសទំនាក់ទំនងផ្សព្វផ្សាយ និងការទុកឯកសារតាមលក្ខណៈទំនើប។ នៅក្នុងក្របខណ្ឌនេះក៏ត្រូវកាត់បន្ថយនូវគំនាបលើឧបករណ៍តុលាការផងដែរតាមការជម្រុញ និងការលើកទឹកចិត្តដល់របៀបដោះស្រាយជម្លោះឆ្លាស់គ្នា។

### កថាខណ្ឌទី១ ការអភិវឌ្ឍន៍វិធីនៃបច្ចេកទេសទំនើបកម្មនៃសេវាសាធារណៈ

ការស្វែងរកការបំពេញចិត្តនៃការរង់ចាំរបស់អ្នកប្តឹងផ្តល់គ្នា ចំពោះក្រសួងយុត្តិធម៌សន្មតបាននូវកិច្ចខិតខំប្រឹងប្រែងដ៏ធំធេងមួយនៃទំនាក់ទំនងការចុះផ្សាយជាសាធារណៈ និងទុកដាក់ឯកសារ។ ការសិក្សាស្ថាននៃទីកន្លែងចាំបាច់សម្រាប់ការនាំមកនូវដំណោះស្រាយសមស្របចំពោះភាពលំបាកដែលតុលាការយើងទទួលរង ។

#### ក. ស្ថានភាពបច្ចុប្បន្ន

តាមការចេញសេចក្តីសម្រេចរបស់ខ្លួន តុលាការត្រូវយកចិត្តទុកដាក់អំពីការទុកឯកសារ ការចុះផ្សាយជាសាធារណៈ និងឯកសារកាឡាប់នុវត្ត។ ការមិនមានការទុកដាក់ឯកសារ ការចុះផ្សាយ និងឯកសារកាឡាប់នុវត្តជាលក្ខណៈសនិទានរំខានយ៉ាងខ្លាំង បច្ចុប្បន្នចំពោះការប្រព្រឹត្តទៅទៀងទាត់នៃតុលាការពីព្រោះសៀវភៅ និងក្រមដែលទុកឲ្យប្រើការចុះផ្សាយសេចក្តីសម្រេចរបស់តុលាការហើយជាយុទ្ធសាស្ត្រអាចឲ្យចៅក្រមដឹងជាប្រចាំពីផលិតកម្មតុលាការ។

ទាក់ទងទៅនឹងការទុកដាក់ឯកសារ គ្មានមជ្ឈមណ្ឌលឯកសារណាមួយនោះទេនៅក្រសួងយុត្តិធម៌ ហើយក៏គ្មានអង្គការចុះផ្សាយសេចក្តីសម្រេចរបស់តុលាការដែរ។ ឯកសារកាឡាប់នុវត្តក៏មិនមានការយកចិត្តទុកដាក់ខ្លាំង ដែលឯកសារទាំងនេះតំណាងឲ្យនៅក្នុងវិស័យតុលាការ នៅទីបញ្ចប់គ្រប់រដ្ឋបាលទាំងអស់ ក្រសួងយុត្តិធម៌ផ្តល់តារកាលិកនៃសេវាសាធារណៈមិនបានល្អជាមួយនឹងនីតិវិធីស្មុគស្មាញ និងគ្មានមធ្យោបាយព័ត៌មានវិទ្យាគ្រប់គ្រាន់។ ការខ្វះខាតការសម្របសម្រួល និងសមត្ថកិច្ចខ្វែងគ្នានៅក្នុងសេវាធ្វើឲ្យមានភាពមិនស៊ីសង្វាក់គ្នាបានល្អនៅក្នុងរដ្ឋបាលតុលាការ។

### ខ. សំណើ

ដើម្បីឆ្លើយតបទៅនឹងការកំហិតកំនត់ទាំងនេះមិនត្រឹមតែគ្រងទុកមុននៅក្នុងអាគារ និងសំលាង់នៅលំហាសមស្រប ព្រមទាំងបុគ្គលិកដែលមានគុណភាពហើយបំពាក់ឧបករណ៍គ្រប់គ្រាន់ដើម្បីបំពេញបេសកកម្មនៃការទុកដាក់ឯកសារ ការចុះផ្សាយ និងរក្សានូវឯកសារជាកាឡាប់នុវត្តទាំងនេះ។

## កថាខណ្ឌ ២ ការលើកកម្ពស់វិធីឆ្លាស់គ្នានៃដំណោះស្រាយជម្លោះ

### ក. ស្ថានភាពបច្ចុប្បន្ន

យន្តការឆ្លាស់គ្នានៃដំណោះស្រាយជម្លោះមិនសូវបានប្រើទេរហូតមកដល់ពេលនេះមិនមានមជ្ឈមណ្ឌលមជ្ឈកម្មត្រូវបានបង្កើតឡើងនៅឡើយ។ ការខ្វះខាតព័ត៌មានស្តីពីលទ្ធភាពប្រើអាជ្ញាកណ្តាលបានរួមចំណែកផងដែរដល់ឱនភាពក្នុងការរត់រកអាជ្ញាកណ្តាលដែលត្រូវបានជ្រើសតាំងឡើងដោយភាគី។

### ខ. សំណើ

ដើម្បីជម្រុញឲ្យមានវិធីដោះស្រាយឆ្លាស់គ្នាដោយជម្លោះ ដោយសម្រាលបន្ទុកដល់តុលាការគួរៈ

- លើកទឹកចិត្តគ្រប់មធ្យោបាយសមស្របទាំងអស់ របៀបដោះស្រាយតាមការស្រុះស្រួលគ្នា
- លើកទឹកចិត្តដល់ការបង្កើតមជ្ឈមណ្ឌលមជ្ឈកម្ម
- រៀបចំយុទ្ធនាការផ្សព្វផ្សាយស្តីអំពីយន្តការមជ្ឈកម្ម និងការផ្សះផ្សា
- បង្កើតបញ្ជីអ្នកផ្សះផ្សា ដោយអនុម័តយកលក្ខណៈវិនិច្ឆ័យ វត្ថុវិស័យ សម្រាប់ការព្រមព្រៀងរបស់ពួកគេមានសមត្ថកិច្ច ភាពដែលអាចជឿទុកចិត្តបាន ហើយធានាឲ្យបានត្រឹមត្រូវពីទឹកន្លែងដែលពួកគេត្រូវយល់ព្រម ស្នើអោយមានការស្បថសម្រាប់អ្នកផ្សះផ្សាផងដែរ
- ការដាក់ឲ្យអនុវត្តបទបញ្ញត្តិនៃក្រមលក្ខន្តិកៈបុគ្គលិកទាក់ទងនឹងការអន្តរាគមន៍របស់អ្នកផ្សះផ្សាក្នុងជម្លោះគ្រួសារ ....។

# ជំពូកទី ៥

# ធនធានមនុស្ស និងជំនួយការតុលាការ

## ផ្នែកទី១ ការគ្រប់គ្រងធនធានមនុស្ស

នៅពេលបច្ចុប្បន្ននេះ ចៅក្រម ព្រះរាជអាជ្ញា សុទ្ធសឹងតែជ្រើសរើសតាមរយៈការប្រឡងប្រជែង ក្នុងនោះរាជរដ្ឋាភិបាលបានផលិតចៅក្រមចំនួន៧ ជំនាន់មកហើយ ដែលក្នុងនោះសុទ្ធតែជាអ្នកមានសមត្ថភាពដោយឆ្លងកាត់ការបណ្តុះបណ្តាលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។

### កថាខណ្ឌទី១ ស្ថានភាពបច្ចុប្បន្ននៃចៅក្រម និងព្រះរាជអាជ្ញា

បច្ចុប្បន្នចៅក្រម និងព្រះរាជអាជ្ញាទូទាំងប្រទេសមានចំនួន ៤៤៥នាក់ ដែលក្នុងនោះមានចៅក្រមចំនួន ២៦៦នាក់ និងព្រះរាជអាជ្ញាមានចំនួន ១៧៩នាក់ ក្នុងចំណោមចៅក្រម ព្រះរាជអាជ្ញាទាំងអស់ ភេទប្រុសមានចំនួន ៣៨៥នាក់ និងភេទស្រីមានចំនួន ៦០នាក់។

ចៅក្រមត្រូវបានជ្រើសរើសដំបូងក្នុងឆ្នាំ២០០៦ ចំនួន ៥៥នាក់នៃសិស្សចៅក្រមជំនាន់១ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ សិស្សចៅក្រមជំនាន់២ ចំនួន៥៥នាក់ សិស្សចៅក្រមជំនាន់៣ ចំនួន ៦៣នាក់ សិស្សចៅក្រមជំនាន់៤ ចំនួន ៦២នាក់ សិស្សចៅក្រមជំនាន់៥ ចំនួន ៥៥នាក់ សិស្សចៅក្រមជំនាន់៦ ចំនួន ៥៥នាក់ និងសិស្សចៅក្រមជំនាន់៧ ចំនួន ៥៥នាក់ កំពុងធ្វើការបណ្តុះបណ្តាល។ បច្ចុប្បន្នរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការកំពុងរៀបចំជ្រើសរើសសិស្សចៅក្រមបន្ថែមដើម្បីបំពេញនូវភាពខ្វះខាតដែលមានពេលបច្ចុប្បន្ន។

### កថាខណ្ឌទី២ ការបញ្ជាក់មូលហេតុនៃបុគ្គលិករបស់តុលាការ

ក្របខណ្ឌនៃអង្គចៅក្រម គឺជាការប្រមូលផ្តុំក្របខណ្ឌចៅក្រម និងក្របខណ្ឌព្រះរាជអាជ្ញាដែលមានគុណសម្បត្តិ និងការបណ្តុះបណ្តាលដូចគ្នា ឬប្រហាក់ប្រហែលគ្នាហើយដែលមានឧបនិស្ស័យកាន់មុខតំណែង និងបំពេញមុខងារនៅក្នុងអង្គចៅក្រម[38]។

ក្របខណ្ឌចៅក្រម រួមមាន ៣ (បី) ឋានន្តរស័ក្តិ ឧត្តមចៅក្រម វរៈចៅក្រម អនុចៅក្រម។ ក្របខណ្ឌព្រះរាជអាជ្ញា រួមមាន ៣ (បី) ឋានន្តរស័ក្តិ ឧត្តមព្រះរាជអាជ្ញា វរៈព្រះរាជអាជ្ញា អនុព្រះរាជអាជ្ញា[39]។ ប្រធានតុលាការកំពូលមានឋានន្តរស័ក្តិជាឧត្តមចៅក្រមថ្នាក់ខ្ពស់បំផុត។ អនុប្រធាន និងចៅក្រមទាំងអស់នៃតុលាការកំពូលមានឋានន្តរស័ក្តិជាឧត្តមចៅក្រម និងមានចំនួនមិនលើសពី ២៥ (ម្ភៃប្រាំ) រូប ដោយរួមទាំងប្រធានតុលាការកំពូលផង។ ប៉ុន្តែយោងតាមតម្រូវការចាំបាច់ចំនួនចៅក្រម

[38] ព្រះរាជក្រឹត្យស្តីពី ឋានន្តរស័ក្តិ និងថ្នាក់សម្រាប់ចៅក្រម និងព្រះរាជអាជ្ញា

[39] មាត្រា ៧ នៃព្រះរាជក្រឹត្យស្តីពី ឋានន្តរស័ក្តិ និងថ្នាក់សម្រាប់ចៅក្រម និងព្រះរាជអាជ្ញា

នៃតុលាការកំពូលអាចត្រូវកំណត់លើសពីនេះ ដោយព្រះរាជក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ប្រធានសាលាឧទ្ធរណ៍មានឋានន្តរស័ក្តិជាឧត្តមចៅក្រម។ អនុប្រធាន និងចៅក្រមទាំងអស់នៃសាលាឧទ្ធរណ៍មានឋានន្តរស័ក្តិជាឧត្តមចៅក្រម ឬវរៈចៅក្រម។ ប្រធានសាលាដំបូងមានឋានន្តរស័ក្តិជាវរៈចៅក្រម។ អនុប្រធាន និងចៅក្រមសាលាដំបូងមានឋានន្តរស័ក្តិជាវរៈចៅក្រម ឬអនុចៅក្រម[40]។

ក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន ចៅក្រម និងព្រះរាជអាជ្ញា ត្រូវទទួលបានប្រាក់បំណាច់មុខងារ ប្រាក់បំណាច់ឈ្នួលផ្ទះ ប្រាក់បំណាច់អធិមូលជីវភាព ប្រាក់បំណាច់សម្រាប់ផ្លាស់ប្តូរទីតាំងការងារ ប្រាក់ថ្លៃព្យាបាលនៅក្នុងមន្ទីរពេទ្យ និងប្រាក់ឧបត្ថម្ភសម្រាប់ព្យាបាលជំងឺប្រចាំកាយរយៈពេលយូររបស់ចៅក្រម និងព្រះរាជអាជ្ញា[41]។

## ផ្នែកទី២ ជំនួយការតុលាការផ្សារភ្ជាប់ទៅនឹងលក្ខន្តិកៈសេរី

### កថាខណ្ឌទី១ មេធាវី

មេធាវី គឺជាវិជ្ជាជីវៈឯករាជ្យ និងសេរីដែលចូលរួមបម្រើវិស័យយុត្តិធម៌ និងប្រព្រឹត្តទៅបានតែក្នុងក្របខណ្ឌនៃគណៈមេធាវីប៉ុណ្ណោះ។[42] វិជ្ជាជីវៈមេធាវីស្ថិតនៅក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់គណៈមេធាវីដែលជាស្ថាប័នឯករាជ្យពីគណបក្សនយោបាយ អង្គការសាសនា ឬអង្គការនានាផ្សេងទៀត។[43]

ដើម្បីចូលរួមក្នុងការរៀបចំនីតិរដ្ឋ តាមរយៈគណៈមេធាវី មេធាវីអាចចូលរួមក្នុងសកម្មភាពសង្គមដូចជា ការផ្តល់ការអប់រំ និងលើកកម្ពស់ការយល់ដឹងផ្នែកច្បាប់ ព្រមទាំងបទបញ្ញត្តិនានាដែលបានអនុម័តដោយអង្គការនីតិបញ្ញត្តិ ឬចេញដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាទៅកាន់សាធារណជន។

មេធាវីមានតួនាទីក្នុងការពិគ្រោះយោបល់ ផ្តល់ប្រឹក្សា តំណាង ឬការពារក្តីនៅគ្រប់សាលាជម្រះក្តី និងគ្រប់ដំណាក់កាលនៃនីតិវិធីរាប់បញ្ចូលទាំងរឿងរដ្ឋប្បវេណី ព្រហ្មទណ្ឌ ពាណិជ្ជកម្ម រដ្ឋបាល ការងារ និងសង្គមកិច្ច។ មេធាវីក៏អាចជួយការពារក្តីនៅចំពោះមុខក្រុមប្រឹក្សាវិន័យបានផងដែរ។ មេធាវីផ្តល់យោបល់ និងរៀបចំតាក់តែងលិខិតស្នាមគតិយុត្តផ្សេងៗ ព្រមទាំងផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ទៅដល់សាធារណជនទូទៅ។ មេធាវីអាចត្រូវបានចាត់តាំងដោយគូក្តី ឬ

---

[40] មាត្រា ៤៩ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា

[41] មាត្រា ៤ នៃអនុក្រឹត្យស្តីពី ប្រាក់បំណាច់ចៅក្រម និងព្រះរាជអាជ្ញា

[42] មាត្រា ១ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

[43] មាត្រា ១៣ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

ចៅក្រមឲ្យបំពេញមុខងារជាអ្នកផ្សះផ្សា ឬជាអ្នកសម្រុះសម្រួល ឬអាជ្ញាកណ្តាលក្នុងករណីដែលច្បាប់អនុញ្ញាត។ ដោយមានការពឹងពាក់ពីអតិថិជន មេធាវីក៏មានសិទ្ធិធ្វើជាតំណាងដោយអាណត្តិ និងការពារផលប្រយោជន៍ស្របច្បាប់ឲ្យអតិថិជននៅចំពោះមុខស្ថាប័នមានសមត្ថកិច្ចនានាផ្សេងទៀតដែរ។

មេធាវីមានសិទ្ធិទទួល ឬមិនទទួលជួយអតិថិជន លើកលែងតែត្រូវបានចាត់តាំងដោយប្រធានគណៈមេធាវី។ ប្រសិនបើមេធាវីយល់ព្រមទទួលយកបេសកកម្មជួយដល់អតិថិជនណាមួយ មេធាវីត្រូវបំពេញបេសកកម្មនោះ ដោយយកចិត្តទុកដាក់រហូតដល់ចប់បេសកកម្មលើកលែងតែអតិថិជនឈប់ពឹងពាក់។ មេធាវីត្រូវពន្យល់ប្រាប់អតិថិជនរបស់ខ្លួនអំពីលក្ខណៈនៃរឿងក្តី ជម្រើសនៃនីតិវិធីដោះស្រាយ កម្រៃសេវាមេធាវី ការចំណាយ និងកម្រៃផ្សេងៗទៀត ដោយផ្អែកលើព័ត៌មានដែលទទួលបានពីកូនក្តី។ មេធាវីមិនត្រូវផ្តល់នូវការធានាចំពោះអតិថិជនទាក់ទងនឹងលទ្ធផលវិជ្ជមាននៃរឿងក្តីឡើយ គឺមេធាវីត្រូវស្ថិតនៅជាម្ចាស់នៃមធ្យោបាយការពារ។[44]

មេធាវីត្រូវប្រកែកមិនទទួលយកបេសកកម្មទាំងឡាយណា ឬអំពើទាំងឡាយណាដែលផ្ទុយពីវិធានវិជ្ជាជីវៈ និងសម្បជញ្ញៈរបស់ខ្លួន។ មេធាវីមិនត្រូវតំណាង ឬការពារ ឬក៏ត្រូវបញ្ឈប់ការតំណាង ឬការពារអតិថិជន បើការតំណាង ឬការពារ បានចាប់ផ្តើមរួចហើយនៅក្នុងករណីដូចខាងក្រោមៈ

- ការតំណាង ឬការការពារនោះនឹងក្លាយជាលទ្ធផលនៃការរំលោភលើវិធានវិជ្ជាជីវៈ ឬច្បាប់ផ្សេងទៀត
- ស្ថានភាពរាងកាយ ឬស្មារតីរបស់មេធាវីធ្វើឲ្យប៉ះពាល់ដល់ប្រសិទ្ធិភាពនៅក្នុងការតំណាង ឬការពាររឿងក្តី
- មេធាវីដែលត្រូវបានហាមឃាត់មិនឲ្យប្រកបវិជ្ជាជីវៈ ឬលុបឈ្មោះចេញពីបញ្ជីគណៈមេធាវីដោយទណ្ឌកម្មវិន័យ។ មេធាវីក៏អាចសម្រេចបញ្ឈប់បេសកកម្មរបស់ខ្លួនបានដែរ ដោយសារតែបុព្វហេតុដែលចេញពីសម្បជញ្ញៈរបស់ខ្លួន។

មុនពេលបញ្ចប់បេសកកម្មរបស់ខ្លួន មេធាវីត្រូវតែជូនដំណឹងទៅអតិថិជនអំពីការបញ្ឈប់ ឬការដកខ្លួននេះ ក្នុងពេលវេលាមួយសមស្របដែលផ្តល់លទ្ធភាពឲ្យអតិថិជនអាចបង្ការផលប្រយោជន៍របស់ខ្លួនបាន និងស្វែងរកមេធាវីផ្សេងទៀត។[45]

ផ្ទុយទៅវិញ អតិថិជនអាចបញ្ឈប់បេសកកម្មរបស់មេធាវីនៅពេលណាក៏បានដោយមាន ឬគ្មានមូលហេតុ ប៉ុន្តែអតិថិជនត្រូវទទួលខុសត្រូវបង់កម្រៃសេវាកម្មរបស់មេធាវីដែលបានព្រមព្រៀង។[46]

---

[44] មាត្រា ២២ នៃក្រមសីលធម៌មេធាវីឆ្នាំ២០១២។

[45] មាត្រា ២៩ នៃក្រមសីលធម៌មេធាវីឆ្នាំ២០១២។

**កថាខណ្ឌទី២ សារការី**

សារការី គឺជាមន្ត្រីសាធារណៈដែលបង្កើតឡើងដើម្បីទទួលលិខិតស្នាម និងកិច្ចសន្យាដែលអតិថិជនត្រូវការ ឬចង់បានជាលក្ខណៈយថាភាពភ្ជាប់ជាមួយនោះជាលិខិតរបស់អំណាចសាធារណៈ ហើយមានការធានាអំពីថ្ងៃខែឆ្នាំរក្សាទុកក្នុងការិយាល័យរបស់ខ្លួន ប្រគល់ជូនទៅអតិថិជនតែសេចក្តីចម្លងបញ្ជាក់ពីសារការី។ ដូចនេះសារការីជាមន្ត្រីធ្វើឲ្យមានយថាភាពលើលិខិត ឬកិច្ចសន្យាផ្សេងៗ។ ក្នុងករណីនេះ មន្ត្រីរូបនេះបានបណ្តុះឡើងជាកន្លែងមួយប្លែកក្នុងប្រព័ន្ធច្បាប់បារាំង ហើយពិសេសជាងនេះទៀត ក្នុងប្រព័ន្ធច្បាប់បញ្ជាក់លើភស្តុតាងជាសំខាន់ គឺភស្តុតាងផ្អែកលើការសរសេរពុំមែនលើសក្ខីភាពទេ។ តាមមាត្រា ១៣១៩ នៃក្រមរដ្ឋប្បវេណីបារាំង "**លិខិតយថាភូតមានការបង្ហាញភស្តុតាងយ៉ាងជាក់ស្តែងដែលមាននៅក្នុងអនុសញ្ញា**"។ ច្បាប់នេះ ពុំមែនមានតែលើសារការីប្រទេសបារាំងប៉ុណ្ណោះទេ វាជាការបញ្ជាក់ផងដែរនៅសម័យប្រជុំអន្តរជាតិ[47]។

នៅព្រះរាជប្រកាសស្តីពីវិជ្ជាជីវៈនៃអ្នកស្មារក្តី នៃអ្នកចំណាយក្តីវិជ្ជាជីវៈសារការីនេះ មានវិសមិតភាពនឹងគ្នាបានសេចក្តីថា តាមផ្លូវច្បាប់មិនអាចប្រកបវិជ្ជាជីវៈចូលគ្នាបានទេ បុគ្គលម្នាក់ៗមិនអាចធ្វើជាមេធាវីផង ធ្វើជាសារការីផងទេ។ សារការីក៏មានវិសមិតភាពផងដែរ ជាមួយនឹងចៅក្រមព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលាទៀតដែរ។ សារការីមិនអាចទៅការពារកូនក្តីនៅមុខអង្គសវនាការដូចជាមេធាវីបានទេ។ តុលាការក៏គ្មានសិទ្ធិ និងកោះអញ្ជើញសារការីឲ្យមកចូលការពារកូនក្តីដូចជាមេធាវីបានដែរ។ ក្នុងករណីដែលមានការភ័ន្តច្រឡំក្នុងពាក្យពេចន៍ ឬឃ្លាប្រយោគជាតួអក្ខរាមិនច្បាស់លាស់ តុលាការមានសិទ្ធិសួរបញ្ជាក់ប៉ុណ្ណោះ។ ក្នុងករណីមានកិច្ចសន្យាណាមួយដែលគេប្តឹងថាជាកិច្ចសន្យាក្លែងបន្លំ ចៅក្រមក៏អាចកោះអញ្ជើញសារការីមកសួរបញ្ជាក់បានដែរ។

សារការីជាមន្ត្រីសាធារណៈ ខុសគ្នាពីមេធាវីដែលជាអ្នកច្បាប់សម្រាប់ការពារកូនក្តី។ តាមមាត្រា ១០ នៃព្រះរាជក្រមលេខ ៩១០ន.ស សារការីគ្មានសមត្ថកិច្ចនឹងទទួលបញ្ជាក់លិខិតរបស់ខ្លួនឯង ឬបងប្អូនខ្លួន ញាតិពន្ធដូរត្រង់ ឬសាខាញាតិ រហូតដល់ថ្នាក់ជាក្មួយ គិតទាំងថ្នាក់នេះផងដើម្បីឲ្យបានផលប្រយោជន៍ដល់ខ្លួន ឬបងប្អូននោះ[48]។

---

[46] មាត្រា ៣០ នៃក្រមសីលធម៌មេធាវីឆ្នាំ២០១២។

[47] ដកស្រង់ចេញពីសៀវភៅវិជ្ជាជីវៈសារការីនៃព្រះរាជាណាចក្រកម្ពុជា ដែលរៀបរៀងដោយលោកមេធាវី អាំង អេង ថុង នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី

[48] មាត្រា១០ នៃព្រះរាជក្រមលេខ ៩១០ន.ស ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៩៤

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី **កំណែទម្រង់យុត្តិធម៌ និងការការពារសិទ្ធិមនុស្សនៅកម្ពុជា** យើញថា ដើម្បីឲ្យប្រជាពលរដ្ឋទទួលបាននូវយុត្តិធម៌មួយប្រកបដោយតម្លាភាព យើងត្រូវពង្រឹងការការពារសិទ្ធិមនុស្ស និងសេរីភាពរបស់បុគ្គល ដោយធ្វើទំនើបកម្មក្របខណ្ឌច្បាប់ ផ្តល់លទ្ធភាពឲ្យទទួលបានព័ត៌មានអំពីច្បាប់ និងតុលាការឲ្យកាន់តែប្រសើរឡើងនៃគុណភាពនៃដំណើរការរឿងក្តី និងសេវាកម្មពាក់ព័ន្ធ និងពង្រឹងសេវាកម្មយុត្តិធម៌។ សកម្មភាពមួយដែលទាញចេញពីតម្លៃ គឺបម្រើទិសដៅជាយុទ្ធសាស្ត្រ ហើយលទ្ធផលជាយុទ្ធសាស្ត្រនេះដែលលើកឡើងក្នុងយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់។

ជាការពិតណាស់ ដើម្បីជាយុទ្ធសាស្ត្រក្នុងការទទួលបាននូវយុត្តិធម៌មួយដ៏ត្រឹមត្រូវ គឺដោយការលើកកម្ពស់តុលាការឲ្យមានឯករាជភាព និងដែលអាចជឿទុកចិត្តបាន មានដំណើរការ និងភារកិច្ចកំណត់ត្រឹមត្រូវតាមអាណត្តិរដ្ឋធម្មនុញ្ញ និងមានការការពារដោយច្បាប់ មិនមានការជ្រៀតជ្រែកខាងរចនាសម្ព័ន្ធតួនាទី និងបុគ្គលិកពីអំណាចដទៃទៀត រួមទាំងការធានាកំណត់តួនាទីឲ្យបានច្បាស់លាស់រវាងតួអង្គនីមួយៗនៅក្នុងស្ថាប័នតុលាការ ដើម្បីបង្កលក្ខណៈឲ្យបំពេញភារកិច្ចយុត្តិធម៌របស់ខ្លួនប្រកបដោយកម្រិតវិជ្ជាជីវៈខ្ពស់ ស្របតាមច្បាប់ទាំងអស់ដែលមាន។ បង្កើតការទទួលខុសត្រូវដោយធានាឲ្យមានលទ្ធភាពទទួលបាននូវការវិនិច្ឆ័យត្រឹមត្រូវ យោងទៅច្បាប់ពាក់ព័ន្ធអាចប្តឹងតវ៉ាបាន និងមានប្រព័ន្ធមួយដែលមានតម្លាភាពស្តីពីការតែងតាំង ការដំឡើងឋានន្តរស័ក្តិ និងថ្នាក់ប្រាក់បៀវត្សចៅក្រម និងព្រះរាជអាជ្ញា និងមន្ត្រីតុលាការដទៃទៀត ដោយចាត់វិធានការដាក់វិន័យដល់ចៅក្រម ព្រះរាជអាជ្ញា ដែលបានប្រព្រឹត្តកំហុសក្នុងការបំពេញកាតព្វកិច្ចវិជ្ជាជីវៈ ដោយផ្អែកលើវិធានលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងច្បាប់។

ដូចនេះដើម្បីធានានូវយុត្តិធម៌មួយប្រកបដោយឯករាជភាពរបស់តុលាការ និងដើម្បីធានាឲ្យដំណើរការមានតម្លាភាព ព្រមទាំងផ្តល់មធ្យោបាយគ្រប់គ្រាន់ដើម្បីឲ្យប្រជាពលរដ្ឋប្រើប្រាស់ប្រព័ន្ធតុលាការដោយការផ្តល់នូវក្របខណ្ឌច្បាប់ និងស្ថាប័ន ដែលយើងត្រូវធ្វើការបង្គ្រប់បន្ថែមដោយធានានូវធនធានមួយដែលចាំបាច់ និងធ្វើការហ្វឹកហ្វឺនដើម្បីអនុវត្តសាលក្រម និងពង្រឹងយន្តការក្នុងការអនុវត្តដើម្បីដាក់ទណ្ឌកម្មចំពោះភាពខ្វះខាតក្នុងការអនុវត្ត ក៏ដូចជាចំពោះការជ្រៀតជ្រែកតួនាទីក្នុងប្រព័ន្ធយុត្តិធម៌។

# ឯកសារយោង

---*---

## ១. បទដ្ឋានគតិយុត្តជាតិ

- រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣
- ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥
- ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
- ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤
- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឆ្នាំ២០១៤
- ច្បាប់ស្តីពីការបង្កើតតុលាការប្រជាជនកំពូល និងមហាអយ្យការតុលាការប្រជាជនកំពូល
- ច្បាប់ស្តីពីអង្គការតុលាការ ឆ្នាំ២០១៤
- ព្រះរាជក្រឹត្យស្តីពី ឋានន្តរស័ក្តិ និងថ្នាក់សម្រាប់ចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤
- ព្រះរាជក្រមលេខ ៩១០ ន.ស ចុះថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ១៩៩៤
- អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- អនុក្រឹត្យស្តីពី ប្រាក់បំណាច់ចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤
- ប្រកាសរបស់ក្រសួងយុត្តិធម៌ លេខ ៥០៩ ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ១៩៨២ ដែលដកស្រង់ចេញពីសៀវភៅ កិច្ចសន្យា និងតុលាការ។
- ប្រកាសលេខ ២១៧ ប្រ.ក ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការគ្រប់គ្រងពន្ធនាគារ

## ២. ឯកសារស្រាវជ្រាវ

- ក្រមសីលធម៌មេធាវីឆ្នាំ ២០១២
- សៀវភៅកិច្ចសន្យា និងតុលាការ
- របាយការណ៍ស្តីពីសិទ្ធិនៅលើការទិញដូរៈ ជីវិតនៅក្នុងពន្ធនាគារកម្ពុជា
- កម្រងព័ត៌មានសេវាសាធារណៈ៖ ចង្កោមសេវាទី ៣ សេវាពាក់ព័ន្ធយុត្តិធម៌ និងអាជ្ញាកណ្តាល

- សៀវភៅវិជ្ជាជីវៈសារការីនៃព្រះរាជាណាចក្រកម្ពុជា ដែលរៀបរៀងដោយលោកមេធាវី អាំង អេងថុង នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី

## ៣. ឯកសារស្រាវជ្រាវភាសាបរទេស

- Institution Constitutionnelles et Politiques du cambodge 1965
- ADHEMARD LECLERE Resident de france au cambodge 1898
- ASPECTS OF ADMINISTRATIVE LAW IN FRANCE, Jean-Luc GREGORCZYK, 2014
- HISTORICAL DEVELOPMENT OF ADMINISTRATIVE LAW IN CAMBODIA, Yan VANDELUXE, 2014

# ព្រះរាជក្រម

នស/រកម/០៧១៤/០១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី៥ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របតាមនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ១៤៨/០០២/២០១៤ កបធ.ច ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅនៃ
# ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅបង្កើត និងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងគោលបំណងជួយព្រះមហាក្សត្រ ដើម្បីធានាឯករាជ្យនៃអំណាច តុលាការស្រប តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ច្បាប់នេះ មានវិសាលភាពអនុវត្តទៅលើចៅក្រម និងព្រះរាជអាជ្ញា ទូទាំងព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានច្បាប់ដោយឡែកកំណត់ផ្សេងពីនេះ ។

**មាត្រា ៣.-**

វាក្យស័ព្ទបច្ចេកទេសដែលប្រើក្នុងច្បាប់នេះ មានន័យដូចខាងក្រោម៖

-ចៅក្រម សំដៅដល់ចៅក្រមអាសនៈ រួមមានជាអាទិ៍ ចៅក្រមជំនុំជម្រះក្ដី និងចៅក្រមស៊ើបសួរ ។

-ព្រះរាជអាជ្ញា សំដៅដល់ព្រះរាជអាជ្ញារង ព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង អគ្គព្រះរាជអាជ្ញា ។

-អង្គចៅក្រម សំដៅដល់ចៅក្រម និងព្រះរាជអាជ្ញា ។

## ជំពូកទី ២
## ការរៀបចំឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

### ផ្នែកទី ១
### សមាសភាពឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

**មាត្រា ៤.-**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមស្ថិតក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ និងរួមមានសមាសភាពដូចខាងក្រោម ៖

១-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាសមាជិក

២-ប្រធានតុលាការកំពូល ជាសមាជិក

៣-អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ជាសមាជិក

៤-សមាជិក ០១ (មួយ) រូប ជ្រើសតាំងដោយព្រឹទ្ធសភា តាមមតិភាគច្រើនដាច់ខាតនៃសមាជិកព្រឹទ្ធសភាទាំងមូល ក្នុងចំណោមឥស្សរជនជាអតីតចៅក្រម ឬអតីតព្រះរាជអាជ្ញា ឬឥស្សរជនដែលមានបទពិសោធន៍ការងារ យ៉ាងតិច ១៥ ឆ្នាំ ឡើងទៅ ក្នុងវិស័យច្បាប់ ឬតុលាការ

៥-សមាជិក ០១ (មួយ) រូប ជ្រើសតាំងដោយរដ្ឋសភា តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ក្នុងចំណោមឥស្សរជនជាអតីតចៅក្រម ឬអតីតព្រះរាជអាជ្ញា ឬឥស្សរជនដែលមានបទពិសោធន៍ការងារ យ៉ាងតិច ១៥ ឆ្នាំ ឡើងទៅ ក្នុងវិស័យច្បាប់ ឬតុលាការ

៦-សមាជិក ០១ (មួយ) រូប ជ្រើសតាំងដោយក្រុមប្រឹក្សាធម្មនុញ្ញ តាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ក្នុងចំណោមឥស្សរជនជាអតីតចៅក្រម ឬអតីតព្រះរាជអាជ្ញា ឬឥស្សរជនដែលមានបទពិសោធន៍ការងារ យ៉ាងតិច ១៥ ឆ្នាំ ឡើងទៅ ក្នុងវិស័យច្បាប់ ឬតុលាការ

៧-សមាជិក ០១ (មួយ) រូប ជ្រើសតាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្នុងចំណោមព្រះរាជអាជ្ញាពេញសិទ្ធិទាំងអស់

៨-សមាជិក ០១ (មួយ) រូប ជាចៅក្រមនៃសាលាជម្រះក្តីជាន់ខ្ពស់ ជ្រើសតាំងតាមការបោះឆ្នោតដោយចៅក្រមនៃសាលាជម្រះក្តីជាន់ខ្ពស់

៩-សមាជិក០១ (មួយ) រូប ជាព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាជម្រះក្តីជាន់ខ្ពស់ ឬព្រះរាជអាជ្ញាបម្រើការងារនៅក្រសួងយុត្តិធម៌ ជ្រើសតាំងតាមការបោះឆ្នោតដោយព្រះរាជអាជ្ញាបម្រើការងារនៅមហាអយ្យការអមសាលាជម្រះក្តីជាន់ខ្ពស់ និងនៅក្រសួងយុត្តិធម៌

១០-សមាជិក ០១ (មួយ) រូប ជាចៅក្រមពេញសិទ្ធិនៃសាលាដំបូង ជ្រើសតាំងតាមការបោះឆ្នោតដោយចៅក្រមពេញសិទ្ធិនៃសាលាដំបូងទូទាំងប្រទេស

១១-សមាជិក ០១(មួយ) រូប ជាព្រះរាជអាជ្ញាពេញសិទ្ធិនៃអយ្យការអមសាលាដំបូង ជ្រើសតាំងតាមការបោះឆ្នោតដោយព្រះរាជអាជ្ញាពេញសិទ្ធិនៃអយ្យការអមសាលាដំបូងទូទាំងប្រទេស ។

សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទាំងអស់ខាងលើ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌លើកសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រចំពោះកិច្ចការនេះ ។

បែបបទ និងនីតិវិធីនៃការបោះឆ្នោតជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដូចមានក្នុងចំណុចទី ៨ ដល់ចំណុចទី ១១ នៃមាត្រានេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីទទួលបានការឯកភាពពីសមាជិកភាគច្រើននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

## មាត្រា ៥.-

សមាជិកជ្រើសតាំងនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានអាណត្តិ ០៥ (ប្រាំ) ឆ្នាំ ហើយត្រូវបញ្ចប់នៅពេលសមាជិកជ្រើសតាំងថ្មីត្រូវបានតែងតាំង ។ សមាជិកជ្រើសតាំងនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចឈរឈ្មោះជាថ្មីសម្រាប់អាណត្តិបន្តបន្ទាប់ទៀតបាន ។ ការបោះឆ្នោតជ្រើសតាំង

សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវចាប់ផ្តើមរៀបចំរយៈពេល ៩០ (កៅសិប) ថ្ងៃ មុនពេលបញ្ចប់អាណត្តិនីមួយៗ ។

ក្នុងករណីដែលសមាជិកណាម្នាក់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ទទួលមរណភាព លាលែងចេញពីតំណែង ឬបាត់បង់លក្ខណសម្បត្តិដូចមានកំណត់ក្នុងមាត្រា ៤ ខាងលើ ឬស្ថិតក្នុងស្ថានភាពមិនអាចបំពេញមុខងាររបស់ខ្លួនបានដោយប្រការណាមួយ សមាជិកនេះត្រូវជំនួសដោយសមាជិកថ្មីសម្រាប់ចីរវេលាដែលនៅសល់សម្រាប់អាណត្តិនោះ តាមបែបបទ ដូចមានចែងក្នុងមាត្រា ៤ ខាងលើនេះ ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវរៀបចំចាត់ចែងកិច្ចការនេះជាបន្ទាន់ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចសម្រេចដកតំណែងសមាជិកជ្រើសតាំងណាម្នាក់របស់ខ្លួនបាន ដោយមូលហេតុនៃការរំលោភបំពានធ្ងន់ធ្ងរលើបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ឬការធ្វើសកម្មភាពនានាដែលនាំឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ ការសម្រេចដកសមាជិកជ្រើសតាំងរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមណាម្នាក់ តម្រូវឲ្យមានការយល់ព្រមពីសមាជិកចំនួនយ៉ាងតិច ០៨ (ប្រាំបី) រូប នៃចំនួនសមាជិកទាំងមូល ។ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារ ដោយគ្មានការព្យួរទោសពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិមដែលប្រព្រឹត្តដោយចេតនា ត្រូវដកចេញពីមុខតំណែងដោយស្វ័យប្រវត្តិ ។ សមាជិកថ្មីដែលត្រូវចូលកាន់តំណែងជំនួស ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

## មាត្រា ៦.-

មុខងារជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានវិសមិតភាពជាមួយនឹងការបំពេញមុខងារជាចៅក្រម ឬព្រះរាជអាជ្ញា នៅតាមសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តី នៅក្នុងអាណត្តិរបស់ខ្លួនជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកលែងតែប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ។

សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលមានវិសមិតភាពមុខងារ ដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវស្នើសុំផ្អាកពីមុខងារជាចៅក្រម ឬព្រះរាជអាជ្ញា នៅតាមសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តី ។

## មាត្រា ៧.-

ព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ទ្រង់អាចចាត់តាំងព្រះរាជតំណាងម្នាក់របស់ព្រះអង្គ ឲ្យធ្វើជាអធិបតីនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបាន ។ ព្រះរាជតំណាងដែលទទួលបានការចាត់តាំង ដឹកនាំ និងចាត់ចែងការងាររបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវរាយការណ៍ឲ្យបានទៀងទាត់ អំពីសកម្មភាពរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមថ្វាយព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ព្រះរាជតំណាងមិនចូលរួមក្នុងការធ្វើសេចក្តីសម្រេច របស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឡើយ ។ ប៉ុន្តែ ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬប្រធានតុលាការកំពូល ត្រូវបានចាត់តាំងជាព្រះរាជតំណាង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬប្រធានតុលាការកំពូល មានសិទ្ធិចូលរួមធ្វើសេចក្តីសម្រេច របស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដូចសមាជិកដទៃទៀតដែរ ។

## ផ្នែកទី ២
## អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

### មាត្រា ៨.-

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានអគ្គលេខាធិការដ្ឋានមួយស្ថិតនៅក្រោមរដ្ឋបាលកណ្តាលនៃក្រសួងយុត្តិធម៌ ដើម្បីធ្វើជាសេនាធិការសម្រាប់គាំទ្រដល់កិច្ចដំណើរការរបស់ខ្លួន ។ អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដឹកនាំដោយអគ្គលេខាធិការមួយរូប មានឋានៈស្មើរដ្ឋលេខាធិការ ឬរដ្ឋមន្ត្រី និងមានអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ។

អគ្គលេខាធិការ និងអគ្គលេខាធិការរងនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ អគ្គលេខាធិការ និងអគ្គលេខាធិការរងនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវជ្រើសរើសចេញពីឥស្សរជន ឬមន្ត្រីរាជការ និងត្រូវមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុ យ៉ាងតិចចំនួន ១០(ដប់) ឆ្នាំ ។ មន្ត្រីរាជការបម្រើការងារក្នុងអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវមានក្របខណ្ឌរបស់ខ្លួននៅក្រសួងយុត្តិធម៌ ។ អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាចមានមន្ត្រីជាប់កិច្ចសន្យា ដើម្បីជួយការងាររបស់ខ្លួនតាមការចាំបាច់ ។ អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបែងចែកជានាយកដ្ឋាន ដែលដឹកនាំដោយប្រធាន ០១ (មួយ) រូប និងអនុប្រធានមួយចំនួនតាមការចាំបាច់ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវកំណត់ដោយអនុក្រឹត្យ ។

### មាត្រា ៩.-

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អមដោយមន្ត្រីមួយចំនួននៃអគ្គលេខាធិការដ្ឋាននេះ តាមការចាំបាច់ ជាលេខាកត់ត្រាសម្រាប់រាល់កិច្ចប្រជុំរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

## ជំពូកទី ៣
## កិច្ចដំណើរការនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

### មាត្រា ១០.-

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌កោះប្រជុំឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តាមព្រះរាជបញ្ជានៃព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមចំនួន ០៤ (បួន) រូប យ៉ាងតិច អាចស្នើឲ្យមានកិច្ចប្រជុំរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបាន ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវរៀបចំទូលថ្វាយព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ស្នើសុំព្រះរាជតម្រិះ ដើម្បីកោះប្រជុំ ។

### មាត្រា ១១.-

ការប្រជុំរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងទុកជាបានការ លុះត្រាតែមានសមាជិកចូលរួមប្រជុំចំនួន០៦ (ប្រាំមួយ) រូប យ៉ាងតិច ។

ការសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលយកជាការបាន ត្រូវមានសំឡេងយ៉ាងតិច ០៦ (ប្រាំមួយ) សំឡេង តាមការបោះឆ្នោតជាសម្ងាត់ ។ ព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មិនចូលរួមក្នុងការធ្វើសេចក្តីសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមឡើយ ។

ក្នុងករណីបន្ទាន់ចាំបាច់ និងតាមសំណើរបស់សមាជិកចំនួន ០៦ (ប្រាំមួយ) រូប យ៉ាងតិច នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ការសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចធ្វើឡើងតាមការបោះឆ្នោតជាសម្ងាត់ ដោយប្រយោលបាន ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវរៀបចំកិច្ចការនេះបន្ទាប់ពីទទួលបានព្រះរាជតម្រិះពីព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

### មាត្រា ១២.-

សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម រួមទាំងលេខាកត់ត្រា និងអ្នកអមលេខាកត់ត្រាត្រូវរក្សាការសម្ងាត់នៃកិច្ចប្រជុំ ។

### មាត្រា ១៣.-

រាល់កិច្ចការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ទាក់ទងនឹងការលើកសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវរៀបចំកិច្ចការនេះ ក្នុងនាមឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជាតំណាងឲ្យឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៅក្នុងទំនាក់ទំនងជាមួយបុគ្គលឯកជន ឬបុគ្គលសាធារណៈនានា និងមានភារកិច្ចចាត់ចែងកិច្ចការរដ្ឋបាលរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយមានអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាសេនាធិការ ។

**មាត្រា ១៤.-**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវរៀបចំឲ្យមានបទបញ្ជាផ្ទៃក្នុង ដើម្បីកំណត់អំពីរបៀបរបប ការងាររបស់ខ្លួន ។ បទបញ្ជាផ្ទៃក្នុងត្រូវអនុម័តដោយសំឡេងយ៉ាងតិច ០៦ (ប្រាំមួយ)សំឡេង នៃ ចំនួនសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

**មាត្រា ១៥.-**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមានកញ្ចប់ថវិការបស់ខ្លួន ដែលផ្គត់ផ្គង់ដោយថវិកាជាតិ ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាអាណាប័កទទួលសិទ្ធិដោយពេញច្បាប់ ពីព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានៃ អង្គចៅក្រម ។

**មាត្រា ១៦.-**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវទទួលប្រាក់បំណាច់មុខងារ ប្រាក់បំណាច់ម៉ោងប្រជុំ និង របបឧបត្ថម្ភនានាសម្រាប់ការបំពេញមុខងាររបស់ខ្លួន ។

សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចជ្រើសរើសប្រាក់បំណាច់មុខងារតែមួយគត់ ក្នុង ចំណោមប្រាក់បំណាច់មុខងារដែលខ្លួនមានសិទ្ធិទទួល ។

**មាត្រា ១៧.-**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមប្រើប្រាស់ត្រារបស់ខ្លួន នៅក្នុងការបំពេញការងារ ។

## ជំពូកទី ៤
## សមត្ថកិច្ចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
### ផ្នែកទី ១
### សមត្ថកិច្ចទូទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

**មាត្រា ១៨.-**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសម្រេច និងលើកសេចក្ដីស្នើថ្វាយព្រះមហាក្សត្រអំពីការតែង តាំង ការផ្លាស់ប្ដូរ ការផ្អាក់ពីមុខងារ ការដាក់ឲ្យនៅក្រៅក្របខណ្ឌ ការដាក់ឲ្យនៅទំនេរ និងការលុបឈ្មោះ ចៅក្រមទាំងអស់ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្ដីស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំង ការផ្លាស់ ប្ដូរ ការផ្អាក់ពីមុខងារ ការដាក់ឲ្យនៅទំនេរ ការដាក់ឲ្យនៅក្រៅក្របខណ្ឌ និងការលុបឈ្មោះព្រះរាជអាជ្ញា

ទាំងអស់ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវបានពិគ្រោះយោបល់ជាចាំបាច់ចំពោះសំណើខាងលើ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមផ្តល់យោបល់ចំពោះការដំឡើងថ្នាក់ និងការដំឡើងឋានន្តរស័ក្តិឲ្យចៅក្រម និងព្រះរាជអាជ្ញាទាំងអស់ តាមបែបបទ និងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ។

## មាត្រា ១៩.-

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវបានពិគ្រោះមតិជាចាំបាច់ ដើម្បីផ្តល់យោបល់លើសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់ ដែលទាក់ទងដល់ការរៀបចំវិស័យតុលាការ និងការប្រព្រឹត្តទៅនៃវិស័យនេះ ។ យោបល់របស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវផ្តល់យ៉ាងយូរ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតពីថ្ងៃដែលបានទទួលសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់ ពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ ក្នុងករណីប្រញាប់ រយៈពេលនេះ អាចបន្ថយមកត្រឹម ១០ (ដប់) ថ្ងៃ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមពិនិត្យ និងសម្រេចលើក្រមសីលធម៌ចៅក្រម និងព្រះរាជអាជ្ញា ។

# ផ្នែកទី ២
# សមត្ថកិច្ចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងមុខការដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា

## មាត្រា ២០.-

ក្នុងមុខការដាក់វិន័យចំពោះចៅក្រម ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវប្រជុំក្រោមរូបភាពជាក្រុមប្រឹក្សាវិន័យក្រោមអធិបតីភាពនៃប្រធានតុលាការកំពូល ។ ក្នុងមុខការដាក់វិន័យចំពោះព្រះរាជអាជ្ញា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវប្រជុំក្រោមរូបភាពជាក្រុមប្រឹក្សាវិន័យ ក្រោមអធិបតីភាពនៃអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ។ ក្នុងករណីទាំងនេះ ព្រះមហាក្សត្រ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មិនចូលរួមក្នុងក្រុមប្រឹក្សាវិន័យទេ ។

ក្នុងករណីសំណុំរឿងវិន័យទាក់ទងនឹងប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ក្រុមប្រឹក្សាវិន័យត្រូវប្រជុំក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ឬព្រះរាជតំណាង ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចូលរួមប្រជុំក្នុងក្រុមប្រឹក្សាវិន័យនេះ ។

ចៅក្រម ឬព្រះរាជអាជ្ញាដែលជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយដែលមានសំណុំរឿងវិន័យពាក់ព័ន្ធនឹងខ្លួន មិនអាចចូលរួមប្រជុំក្នុងឋានៈជាសមាជិកក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីពិនិត្យ និងសម្រេចលើសំណុំរឿងវិន័យនោះបានឡើយ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## មាត្រា ២១.-

ត្រូវបង្កើតឲ្យមានក្រុមអធិការកិច្ចនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីជួយការងាររបស់ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងការស៊ើបអង្កេត និងស្រាវជ្រាវសំណុំ រឿងវិន័យ ។ សមាសភាពនៃក្រុមអធិការកិច្ចនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវតែងតាំងដោយព្រះរាជក្រឹត្យ បន្ទាប់ពីបានទទួលការសម្រេចតាមមតិភាគច្រើននៃសមាជិករបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ ក្រុមអធិការកិច្ចនេះដឹកនាំដោយសហប្រធាន ដែលសហប្រធាន ០១ (មួយ) រូប ត្រូវជ្រើសរើសក្នុងចំណោមចៅក្រម ដែលមានឋានន្តរស័ក្តិជាឧត្តមចៅក្រម និងសហប្រធាន ០១ (មួយ) រូប ទៀត ត្រូវជ្រើសរើសក្នុងចំណោមព្រះរាជអាជ្ញា ដែលមានឋានន្តរស័ក្តិជាឧត្តមព្រះរាជអាជ្ញា។

មុខងារលំអិត ព្រមទាំងការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមអធិការកិច្ចនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវកំណត់ដោយក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

## មាត្រា ២២.-

ក្រុមអធិការកិច្ច បំពេញការងារតាមការចាត់តាំងរបស់ប្រធានក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ ក្នុងក្របខណ្ឌនៃការបំពេញការងាររបស់ខ្លួន ក្រុមអធិការកិច្ចអាចស្នើសុំពិនិត្យសំណុំរឿងនានា ដែលមានការពាក់ព័ន្ធនឹងសំណុំរឿងវិន័យ ឬមានប្រយោជន៍ដល់សំណុំរឿងវិន័យ ។ ក្នុងករណីចាំបាច់ ក្រុមអធិការកិច្ចអាចស្នើសុំការបំភ្លឺពីគ្រប់បុគ្គលនានាបាន ។ ចៅក្រម និងព្រះរាជអាជ្ញាដែលមិនផ្តល់កិច្ចសហការតាមការស្នើសុំរបស់ក្រុមអធិការកិច្ច ត្រូវចាត់ទុកជាកំហុសវិន័យ ដែលត្រូវកត់ត្រាចូលក្នុងកំណត់ហេតុអធិការកិច្ច ។

## មាត្រា ២៣.-

ពាក្យបណ្តឹងអំពីវិន័យទាក់ទងនឹងចៅក្រម និងព្រះរាជអាជ្ញា ត្រូវដាក់នៅអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬនៅក្រសួងយុត្តិធម៌ ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់ឲ្យពិនិត្យនិងស្រាវជ្រាវជាបឋមលើពាក្យបណ្តឹងទាំងនេះ ដើម្បីកសាងសំណុំរឿងវិន័យ មុននឹងសម្រេចបញ្ជូនសំណុំរឿងនេះ ទៅក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីចាត់នីតិវិធីបន្ត ។

## មាត្រា ២៤.-

បន្ទាប់ពីទទួលបានសំណុំរឿងវិន័យ និងប្រសិនបើយល់ឃើញថា ជាការចាំបាច់ ប្រធានក្រុមប្រឹក្សាវិន័យអាចចាត់ឲ្យមានការស្រាវជ្រាវបន្ថែម ដោយប្រើយន្តការក្រុមអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

**មាត្រា ២៥.-**

ប្រធានក្រុមប្រឹក្សាវិន័យ កោះប្រជុំក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ សំណុំរឿងវិន័យ ព្រមទាំងសំណុំឯកសារពាក់ព័ន្ធនឹងវិន័យរបស់ចៅក្រម និងព្រះរាជអាជ្ញា ត្រូវផ្ញើជូនទៅសមាជិកទាំងអស់នៃក្រុមប្រឹក្សាវិន័យយ៉ាងតិច ១០ (ដប់) ថ្ងៃ មុនថ្ងៃប្រជុំ ។ ចៅក្រម ឬព្រះរាជអាជ្ញាដែលជាប់ពាក់ព័ន្ធក្នុងសំណុំរឿងវិន័យនេះ មានសិទ្ធិដឹងអំពីបទវិន័យដែលចោទប្រកាន់លើខ្លួន និងមានសិទ្ធិការពារខ្លួនដោយខ្លួនឯង ឬដោយមានជំនួយពីមេធាវី នៅចំពោះមុខក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ការប្រជុំរបស់ក្រុមប្រឹក្សាវិន័យត្រូវធ្វើជាអសាធារណៈ ។ ប្រធានក្រុមប្រឹក្សាវិន័យ អាចអញ្ជើញបុគ្គលពាក់ព័ន្ធនានាឲ្យចូលរួមក្នុងការប្រជុំរបស់ខ្លួនបាន បើយល់ឃើញថាជាការចាំបាច់ ។ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រមទាំងបុគ្គលដែលចូលរួមប្រជុំក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវរក្សាការសម្ងាត់នៃអង្គប្រជុំ ។

កូរ៉ុមប្រជុំរបស់ក្រុមប្រឹក្សាវិន័យ ត្រូវអនុវត្តដូចគ្នានឹងកូរ៉ុមប្រជុំរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដូចមានចែងក្នុងមាត្រា ១១ នៃច្បាប់នេះ ។

នីតិវិធីលំអិតសម្រាប់កិច្ចដំណើរការនៃក្រុមប្រឹក្សាវិន័យ ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

**មាត្រា ២៦.-**

ក្នុងករណីរកឃើញកំហុស ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសម្រេចដាក់ទណ្ឌកម្មវិន័យ ដូចមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យត្រូវមានសំអាងហេតុ និងសំអាងច្បាប់ ។

ការសម្រេចរបស់ក្រុមប្រឹក្សាវិន័យ ត្រូវអនុវត្តដូចគ្នានឹងការសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដូចមានចែងក្នុងមាត្រា ១១ នៃច្បាប់នេះ ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យ ត្រូវដាក់ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដើម្បីពិនិត្យនិងសម្រេច ។ សេចក្តីសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ។

ក្នុងករណីដែលទណ្ឌកម្មវិន័យថ្នាក់ទី ២ ត្រូវបានប្រកាស ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីកិច្ចការនេះ ។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា ២៧.-**

សម្រាប់អំឡុងពេលនៃការរៀបចំសមាសភាពថ្មីនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដូចមានចែង

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ក្នុងមាត្រា ៤ នៃច្បាប់នេះ សមាសភាពនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលមានមុនច្បាប់នេះចូលជាធរមាន ត្រូវបន្តការងាររបស់ខ្លួន ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ រហូតដល់ពេលដែលសមាសភាពថ្មីត្រូវបានតែងតាំងជាផ្លូវការដោយព្រះរាជក្រឹត្យ ។ ក្នុងករណីនេះគោលការណ៍ វិសមិតភាពដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ មិនត្រូវយកមកអនុវត្តឡើយ ។

**មាត្រា ២៨.-**

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវរៀបចំឲ្យមានការបោះឆ្នោតជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដូចមានចែងចាប់ពីចំណុចទី ៨ ដល់ចំណុចទី ១១ នៃមាត្រា ៤ នៃច្បាប់នេះក្នុងអំឡុងពេល០៣ (បី) ខែ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ។

បែបបទ និងនីតិវិធីនៃការបោះឆ្នោតលើកទី ១ សម្រាប់ការជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដូចមានចែងក្នុងកថាខណ្ឌទី ៣ នៃមាត្រា ៤ នៃច្បាប់នេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ២៩.-**

សម្រាប់អំឡុងពេលដែលក្រុមអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រមពុំទាន់ត្រូវបានតែងតាំងតាមបញ្ញត្តិនៃមាត្រា ២១ នៃច្បាប់នេះ ប្រធានក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចចាត់ឲ្យចៅក្រម ឬព្រះរាជអាជ្ញាដែលបម្រើការងារនៅតាមសាលា ជម្រះក្តី និងនៅតាមអង្គការអយ្យការអមសាលាជម្រះក្តី ដើម្បីឲ្យចុះធ្វើការស្រាវជ្រាវ និងស៊ើបអង្កេត លើសំណុំរឿងវិន័យបាន ។

**មាត្រា ៣០.-**

បទប្បញ្ញត្តិនៃមាត្រា ៦ នៃច្បាប់នេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះការបំពេញមុខងារជាចៅក្រម ឬព្រះរាជអាជ្ញា នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា ៣១.-**

ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលត្រូវបានប្រកាស

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ឲ្យប្រើដោយព្រះរាជក្រមលេខ ០៩ ន.ស.៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តដែលផ្ទុយពីនេះ ត្រូវទុកជានិរាករណ៍ ហើយត្រូវជំនួសដោយច្បាប់នេះ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ការ.១៤០៧.៨៦៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**
**ហត្ថលេខា**
**អង្គ វង្សវឌ្ឍានា**

លេខ: ៩០៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រម

នស/រកម/០៧១៤/០១៥

## យើង

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
### សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
### ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
### ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៩៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី៥ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របតាមនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ១៤៩/០០៣/២០១៤ កបធ.ច ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

# ច្បាប់

# ស្ដីពី

# ការរៀបចំអង្គការតុលាការ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណង៖

- ធានាឯករាជ្យនៃអំណាចតុលាការ
- ធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ
- ធានាឲ្យមានកិច្ចដំណើរការល្អរបស់អង្គការតុលាការ និងអង្គការអយ្យការ
- លើកកម្ពស់សេវាសាធារណៈឲ្យមានប្រសិទ្ធភាព និងឆាប់រហ័ស
- ធានាក្នុងការផ្ដល់យុត្តិធម៌លើរឿងក្ដីគ្រប់ប្រភេទ ដើម្បីបង្កើនជំនឿទុកចិត្តពីប្រជាពលរដ្ឋ និងរួមចំណែកពង្រឹងសុវត្ថិភាពសង្គម ។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅ៖

- កំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការតុលាការគ្រប់ផ្នែកនិងគ្រប់ជាន់ថ្នាក់ដែលជាសាលាជម្រះក្ដីនៃព្រះរាជាណាចក្រកម្ពុជា
- កំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការអយ្យការអមសាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់នៃព្រះរាជាណាចក្រកម្ពុជា
- កំណត់អំពីសមត្ថកិច្ចរបស់តុលាការគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ទៅតាមជំនាញ
- រៀបចំការងារគ្រប់គ្រង ការងាររដ្ឋបាល និងដំណើរការប្រព្រឹត្តទៅរបស់តុលាការ ។

**មាត្រា ៣.-**

សាលាជម្រះក្ដីនៃព្រះរាជាណាចក្រកម្ពុជា រួមមាន៖

- សាលាដំបូង
- សាលាឧទ្ធរណ៍
- តុលាការកំពូល ។

សាលាដំបូង ជាសាលាជម្រះក្ដីជាន់ទាប ។ សាលាឧទ្ធរណ៍ និងតុលាការកំពូល ជាសាលាជម្រះក្ដីជាន់ខ្ពស់ ។

យោងតាមសេចក្ដីត្រូវការចាំបាច់ជាក់ស្ដែង ការបង្កើតសាលាជម្រះក្ដីណាមួយ ឬសាលាជម្រះក្ដីសោមញ្ញត្រូវធ្វើឡើងដោយច្បាប់ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា ៤.-**

សាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ អនុវត្តអំណាចតុលាការ ដែលគ្របដណ្តប់លើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ។

**មាត្រា ៥.-**

សាលាជម្រះក្តីជាន់ទាបត្រូវបែងចែកជាតុលាការជំនាញ ។ ការបង្កើត ការលុបចោល និងការកែប្រែតុលាការជំនាញត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

ប្រធានសាលាដំបូង មានអំណាចឋានានុក្រមផ្នែករដ្ឋបាលដោយផ្ទាល់លើប្រធានតុលាការជំនាញទាំងអស់នៃសាលាដំបូងនោះ ។ ប្រធានតុលាការជំនាញនីមួយៗ មានអំណាចឋានានុក្រមផ្នែករដ្ឋបាលដោយផ្ទាល់លើចៅក្រមដែលជាសមាជិក ។ ប្រធានសាលាដំបូងមិនអាចធ្វើជាប្រធានតុលាការជំនាញណាមួយបានឡើយ ។ ប្រធានតុលាការជំនាញនីមួយៗ អាចធ្វើជាប្រធានតុលាការជំនាញបានតែមួយគត់នៃសាលាដំបូងនោះ ។

សាលាជម្រះក្តីជាន់ខ្ពស់ត្រូវបែងចែកជាសភាជំនាញ ។ ការបង្កើត ការលុបចោល និងការកែប្រែសភាជំនាញ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

ប្រធានសាលាជម្រះក្តីជាន់ខ្ពស់ មានអំណាចឋានានុក្រមផ្នែករដ្ឋបាលដោយផ្ទាល់លើប្រធានសភាជំនាញទាំងអស់នៃសាលាជម្រះក្តីជាន់ខ្ពស់នោះ ។ ប្រធានសភាជំនាញនីមួយៗ មានអំណាចឋានានុក្រមផ្នែករដ្ឋបាលដោយផ្ទាល់លើចៅក្រមដែលជាសមាជិក ។ ប្រធានសាលាជម្រះក្តីជាន់ខ្ពស់មិនអាចធ្វើជាប្រធានសភាជំនាញណាមួយបានឡើយ ។ ប្រធានសភាជំនាញនីមួយៗ អាចធ្វើជាប្រធានសភាជំនាញបានតែមួយគត់នៃសាលាជម្រះក្តីជាន់ខ្ពស់នោះ ។

**មាត្រា ៦.-**

មានតែចៅក្រមទេ ដែលមានសិទ្ធិជម្រះក្តី ។ ចៅក្រមត្រូវបំពេញភារកិច្ចនេះដោយឯករាជ្យ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឲ្យអស់ពីដួងចិត្តនិងសម្បជញ្ញៈរបស់ខ្លួន ។

ការជម្រះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរតាមនីតិវិធី និងច្បាប់ជាធរមាន ។

មានតែសាលាជម្រះក្តីប៉ុណ្ណោះ ទើបមានអំណាចកាត់សេចក្តី និងចេញសេចក្តីសម្រេចរបស់តុលាការបាន ។

**មាត្រា ៧.-**

សវនាការត្រូវធ្វើឡើងជាសាធារណៈ លើកលែងតែសាធារណភាពនេះអាចបង្កឲ្យមានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬដល់ទំនៀមទម្លាប់ល្អ ឬមានបទប្បញ្ញត្តិពិសេសក្នុងច្បាប់ចែងផ្សេងពីនេះ ។

នៅគ្រប់ករណីទាំងអស់ សាលក្រម និងសាលដីកាតុលាការ ត្រូវប្រកាសនៅក្នុងសាលសវនាការ ដែលបើកជាសាធារណៈ ។

ការពិភាក្សាសម្រេចសេចក្តីរបស់អង្គជំនុំជម្រះត្រូវធ្វើជាសម្ងាត់ ។

លើកលែងតែមានបទប្បញ្ញត្តិផ្សេងពីនេះ ការប្រកាសសាលក្រម ឬសាលដីការបស់តុលាការ ត្រូវធ្វើឡើងដោយប្រធានអង្គជំនុំជម្រះ ឬចៅក្រមមួយរូបក្នុងចំណោមចៅក្រមដែលជាសមាសភាពនៃ អង្គជំនុំជម្រះ ។

គ្រប់សាលក្រម និងសាលដីកាតុលាការ ត្រូវតែមានសំអាងហេតុ ។

លើកលែងតែមានបទប្បញ្ញត្តិផ្សេងពីនេះ សាលក្រម និងសាលដីកា ត្រូវចុះហត្ថលេខាដោយ ប្រធានអង្គជំនុំជម្រះ និងចុះហត្ថលេខាអមដោយក្រឡាបញ្ជីនៃសវនាការ ។

## មាត្រា ៨.–

នៅអមសាលាដំបូង ត្រូវមានអង្គការអយ្យការមួយ ហៅថា អយ្យការអមសាលាដំបូង ។

នៅអមសាលាឧទ្ធរណ៍ ត្រូវមានអង្គការអយ្យការមួយហៅថាមហាអយ្យការអមសាលាឧទ្ធរណ៍ ។

នៅអមតុលាការកំពូល ត្រូវមានអង្គការអយ្យការមួយ ហៅថា មហាអយ្យការអមតុលាការកំពូល ។

តំណាងអង្គការអយ្យការ ត្រូវមានវត្តមាននៅគ្រប់សវនាការទាំងអស់នៃរឿងក្តីព្រហ្មទណ្ឌ និង រឿងក្តីផ្សេងៗ ទៀតដែលច្បាប់កំណត់ ។

## មាត្រា ៩.–

នៅគ្រប់អង្គការតុលាការ និងអង្គការអយ្យការគ្រប់ជាន់ថ្នាក់ មានក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាល ព្រមទាំងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ជាជំនួយការតាមការចាំបាច់ ។

ក្រឡាបញ្ជីជួយចៅក្រម និងព្រះរាជអាជ្ញានៅគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការ និង អយ្យការ ។

តួនាទី និងមុខងាររបស់ក្រឡាបញ្ជី ត្រូវកំណត់ក្នុងលក្ខន្តិកៈក្រឡាបញ្ជី ។

បែបបទ និងលក្ខខណ្ឌនៃការជ្រើសរើសមន្ត្រីជំនាញផ្នែកច្បាប់ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## មាត្រា ១០.–

នៅសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ មានអង្គភាពរដ្ឋបាលមួយ ដែលស្ថិតនៅក្រោមរដ្ឋបាលកណ្តាល របស់ក្រសួងយុត្តិធម៌ សម្រាប់គាំទ្រដល់កិច្ចដំណើរការរបស់អង្គការតុលាការ និងអង្គការអយ្យការ។

នៅថ្នាក់សាលាដំបូង អង្គភាពរដ្ឋបាលនេះ ហៅថា លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងមាន ថ្នាក់ស្មើនឹងនាយកដ្ឋាន ។

នៅថ្នាក់សាលាឧទ្ធរណ៍ អង្គភាពរដ្ឋបាលនេះ ហៅថា អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ មានថ្នាក់ស្មើនឹងអគ្គនាយកដ្ឋាន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

នៅថ្នាក់តុលាការកំពូល អង្គភាពរដ្ឋបាលនេះ ហៅថា អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល មានថ្នាក់ស្មើនឹងអគ្គនាយកដ្ឋាន ។

**មាត្រា ១១.-**

ក្រសួងយុត្តិធម៌ មានសិទ្ធិត្រួតពិនិត្យលើកិច្ចការរដ្ឋបាលរបស់សាលាជម្រះក្តីទាំងអស់ ដោយមានអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការមួយជាសេនាធិការ ។ ក្រសួងយុត្តិធម៌អាចចេញលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំចាំបាច់នានា ដើម្បីជានាដំណើរការប្រព្រឹត្តទៅល្អប្រសើរនៃការគ្រប់គ្រងរដ្ឋបាលតុលាការគ្រប់ជាន់ថ្នាក់ ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចចាត់ឲ្យធ្វើអធិការកិច្ចលើបញ្ហាណាមួយជាកំណត់ រួចធ្វើរបាយការណ៍ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដើម្បីពិនិត្យ និងសម្រេច ។

សាលាជម្រះក្តីជាន់ខ្ពស់ មានសមត្ថកិច្ចត្រួតពិនិត្យលើកិច្ចការជម្រះក្តីរបស់សាលាជម្រះក្តីជាន់ទាប ។ ការត្រួតពិនិត្យនេះ ប្រព្រឹត្តទៅក្នុងក្របខណ្ឌនៃនីតិវិធីឧបាស្រ័យ ដោយអនុលោមតាមបទប្បញ្ញត្តិស្តីពីនីតិវិធីជាធរមាន ។

## ជំពូកទី ២
## សាលាដំបូង និងអយ្យការអមសាលាដំបូង
## ផ្នែកទី ១
## សាលាដំបូង
## អនុផ្នែកទី ១
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់សាលាដំបូង

**មាត្រា ១២.-**

សាលាដំបូងជាសាលាជម្រះក្តីថ្នាក់ទីមួយ ដែលត្រូវបង្កើតឲ្យមាននៅរាជធានីភ្នំពេញ និងនៅគ្រប់ខេត្តនៃព្រះរាជាណាចក្រកម្ពុជា ។ ការដាក់ឲ្យដំណើរការសាលាដំបូងនានា ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ ។

សាលាដំបូងត្រូវបែងចែកជាតុលាការជំនាញ ។ សាលាដំបូង គឺជាសាលាជម្រះក្តីទូទៅដែលមានសមត្ថកិច្ចជំនុំជម្រះក្តីទៅលើរឿងក្តីទាំងអស់ លើកលែងតែរឿងក្តីដែលស្ថិតនៅក្រោមសមត្ថកិច្ចនៃសាលាជម្រះក្តីពិសេស ឬសាលាជម្រះក្តីវិសាមញ្ញដែលបង្កើតឡើងដោយច្បាប់ដោយឡែក ។

**មាត្រា ១៣.-**

សមាសភាពសាលាដំបូង រួមមាន៖

- ប្រធាន

- អនុប្រធាន
- ចៅក្រម
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅសាលាដំបូង ។

**មាត្រា ១៤.-**

សាលាដំបូងនីមួយៗបែងចែកជាតុលាការជំនាញ ដូចខាងក្រោម៖

- តុលាការរដ្ឋប្បវេណី
- តុលាការព្រហ្មទណ្ឌ
- តុលាការពាណិជ្ជកម្ម
- តុលាការការងារ ។

តុលាការជំនាញផ្សេងទៀតរបស់សាលាដំបូង អាចត្រូវបង្កើតឡើង ដោយយោងតាមសេចក្ដីត្រូវការចាំបាច់ ។ ការបង្កើតនេះ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ ។

តុលាការជំនាញនីមួយៗរបស់សាលាដំបូង ចេញសេចក្ដីសម្រេចរបស់ខ្លួនប្រកបដោយស្វ័យភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងនាមសាលាដំបូងដែលតុលាការជំនាញនោះស្ថិតនៅ ។

**មាត្រា ១៥.-**

សមាសភាពរបស់តុលាការជំនាញនីមួយៗរួមមាន៖

- ប្រធានតុលាការ
- ចៅក្រម
- ក្រឡាបញ្ជី ។

ប្រធានតុលាការជំនាញនីមួយៗ រួមទាំងចៅក្រម និងក្រឡាបញ្ជី ត្រូវចាត់តាំងដោយប្រធានសាលាដំបូង ។ ដំណើរការរបស់តុលាការជំនាញទាំងនេះ ត្រូវកំណត់ដោយប្រធានសាលាដំបូងដោយអនុលោមទៅតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា ១៦.-**

តុលាការជំនាញនីមួយៗនៃសាលាដំបូង សម្រេចសេចក្ដីដោយមានចៅក្រមទោល ឬដោយក្រុមប្រឹក្សាជំនុំជម្រះ ដោយអនុលោមតាមបទប្បញ្ញត្តិស្ដីពីនីតិវិធីរដ្ឋប្បវេណី នីតិវិធីព្រហ្មទណ្ឌ ឬបទប្បញ្ញត្តិស្ដីពីនីតិវិធីជាធរមានផ្សេងទៀត ។ ក្នុងករណីចៅក្រមណាម្នាក់មានធុរៈ ឬស្ថិតក្នុងស្ថានភាពមិនអាចបំពេញកិច្ចការបាន ចៅក្រមនោះអាចជំនួសដោយចៅក្រមនៅក្នុងលំដាប់បន្តបន្ទាប់ ដែលមានកំណត់ក្នុងដីកាសម្រេចប្រចាំឆ្នាំរបស់ប្រធានសាលាដំបូង ។

ក្នុងករណីដែលតុលាការជំនាញណាមួយមិនអាចបើកសវនាការបាន ដោយមានមូលហេតុមកពីខ្វះចៅក្រម ប្រធានសាលាដំបូងត្រូវចាត់តាំងចៅក្រមពីតុលាការជំនាញផ្សេងមកបំពេញ ។ ប្រសិនបើត្រូវស្នើសុំចៅក្រមមួយរូប ឬច្រើនរូបនៃសាលាដំបូងផ្សេងសម្រាប់បំពេញសមាសភាពនៃតុលាការជំនាញនេះ ប្រធានសាលាដំបូងត្រូវស្នើសុំទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## មាត្រា ១៧.-

ប្រធានសាលាដំបូងចាត់វិធានការគ្រប់គ្រងជាចាំបាច់សម្រាប់ដំណើរការនៃសាលាដំបូង ។ ក្នុងករណីប្រធានសាលាដំបូងស្ថិតក្នុងស្ថានភាពមិនអាចបំពេញការងារបាន ឬក្នុងករណីតំណែងប្រធានសាលាដំបូងស្ថិតក្នុងស្ថានភាពទំនេរ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់តាំងអនុប្រធានសាលាដំបូងម្នាក់ ឬបើគ្មានអនុប្រធានទេ អាចចាត់តាំងចៅក្រមណាម្នាក់ឲ្យធ្វើជាប្រធានស្តីទីជំនួសបាន ដើម្បីធានាដំណើរការរបស់សាលាដំបូង រហូតដល់មានការតែងតាំងប្រធានសាលាដំបូងជាផ្លូវការ ។ ការតែងតាំងប្រធានសាលាដំបូង ត្រូវធ្វើក្នុងរយៈពេលខ្លីបំផុត និងយ៉ាងយូរបំផុតមិនឲ្យលើសពី ៣០ ( សាមសិប ) ថ្ងៃ ។

ប្រធានសាលាដំបូងត្រូវចេញដីកាសម្រេចដើម្បីៈ

- ចាត់តាំងអនុប្រធានសាលាដំបូងណាម្នាក់ ឲ្យចាត់ចែងការងារជំនួសខ្លួនបាន ក្នុងករណីចាំបាច់
- ចាត់តាំងអនុប្រធានសាលាដំបូង ឲ្យទទួលបន្ទុកធ្វើជាប្រធានតុលាការជំនាញនីមួយៗដោយផ្អែកតាមជំនាញ ឬបទពិសោធន៍ការងារ ។ ក្នុងករណីខ្វះអនុប្រធានប្រធានសាលាដំបូងអាចចាត់តាំងចៅក្រមណាម្នាក់ ដែលមានឋានន្តរស័ក្តិខ្ពស់ ឬមានបទពិសោធន៍ច្រើនឲ្យធ្វើជាប្រធានតុលាការជំនាញបាន
- កំណត់លំដាប់សម្រាប់ជំនួសចៅក្រមនៅក្នុងតុលាការជំនាញនីមួយៗ និងនៅក្នុងក្រុមប្រឹក្សាជំនុំជម្រះនៃតុលាការជំនាញទាំងនេះ ក្នុងករណីដែលចៅក្រមណាម្នាក់អវត្តមាន ឬមានធុរៈ
- ចាត់តាំង និងផ្លាស់ប្តូរក្រឡាបញ្ជីនៅក្នុងតុលាការជំនាញនីមួយៗ តាមសេចក្តីត្រូវការចាំបាច់ជាក់ស្តែង ។

## មាត្រា ១៨.-

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចសម្រេចអនុញ្ញាតឲ្យសាលាដំបូងបើកសវនាការនៅក្រៅទីតាំងស្នាក់ការរបស់ខ្លួនបាន តាមការស្នើសុំពីប្រធានសាលាដំបូង ។

## អនុផ្នែកទី ២
## សមត្ថកិច្ច

### មាត្រា ១៩.-

សាលាដំបូងមានសមត្ថកិច្ចជំនុំជម្រះរឿងក្តី ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន លើកលែងតែរឿងក្តីទាំងឡាយដែលច្បាប់ប្រគល់សមត្ថកិច្ចទៅឲ្យសាលាជម្រះក្តីផ្សេងទៀត ។

ក្នុងករណីចាំបាច់ ដើម្បីជានាប្រយោជន៍សាធារណៈ សុវត្ថិភាព សន្តិសុខសង្គម និងដំណើរការល្អនៃយុត្តិធម៌តុលាការ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចសម្រេចផ្ទេរសមត្ថកិច្ចក្នុងការចាត់ការរឿងក្តីពីសាលាដំបូងមួយទៅសាលាដំបូងមួយទៀតបាន ។

ក្នុងករណីមានវិវាទសមត្ថកិច្ចរវាងតុលាការជំនាញផ្សេងៗនៅក្នុងសាលាដំបូង ប្រធានសាលាដំបូងត្រូវកោះប្រជុំប្រធានតុលាការជំនាញដែលពាក់ព័ន្ធដោយឆន្ទានុសិទ្ធិរបស់ខ្លួន ឬតាមសំណើរបស់ប្រធានតុលាការជំនាញណាមួយដើម្បីសម្រេចអំពីសមត្ថកិច្ច ។ ប្រធានសាលាដំបូងសម្រេចលើវិវាទសមត្ថកិច្ចនេះដោយដីកាសម្រេច ។ ដីកាសម្រេចនេះ គឺជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ។

### មាត្រា ២០.-

តុលាការព្រហ្មទណ្ឌនៃសាលាដំបូងជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌទាំងឡាយ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ លើកលែងតែមានបទប្បញ្ញត្តិច្បាប់ចែងផ្សេងពីនេះ ។

តុលាការព្រហ្មទណ្ឌនៃសាលាដំបូងជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ ដោយចៅក្រមទោល ឬដោយក្រុមប្រឹក្សាជំនុំជម្រះ ដោយអនុលោមតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

មន្ទីរស៊ើបសួរនៃសាលាដំបូង គឺជាផ្នែកមួយនៃតុលាការព្រហ្មទណ្ឌ និងមានសមត្ថកិច្ចស៊ើបសួររឿងក្តីព្រហ្មទណ្ឌ ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ ។ ប្រធានសាលាដំបូងត្រូវចាត់តាំងចៅក្រមយ៉ាងតិច ០២ (ពីរ) រូប តាមដីកាសម្រេចឲ្យបំពេញតួនាទីជាចៅក្រមស៊ើបសួរនៅមន្ទីរស៊ើបសួរនៃតុលាការព្រហ្មទណ្ឌនៃសាលាដំបូង ។ ដីកាសម្រេចនេះ ត្រូវកំណត់ផងដែរអំពីលំដាប់លេខរៀងសម្រាប់ការទទួលបំពេញការងារ ។ ក្នុងករណីពុំមានចៅក្រមស៊ើបសួរ ឬខ្វះចៅក្រមស៊ើបសួរប្រធានសាលាដំបូងអាចចាត់តាំងចៅក្រមនៃតុលាការជំនាញផ្សេង ដើម្បីបំពេញមុខងារស៊ើបសួរបាន ។

ក្នុងករណីចាំបាច់ ចៅក្រមស៊ើបសួរអាចបំពេញការងារជាចៅក្រមនៅតុលាការជំនាញផ្សេងទៀតបាន តាមការចាត់តាំងរបស់ប្រធានសាលាដំបូង ។

### មាត្រា ២១.-

តុលាការរដ្ឋប្បវេណីនៃសាលាដំបូង មានសមត្ថកិច្ចជំនុំជម្រះរឿងក្តីរដ្ឋប្បវេណី និងរឿងក្តីទាំង

ឡាយណាដែលពុំមានបទប្បញ្ញត្តិណាមួយ ប្រគល់សមត្ថកិច្ចទៅឲ្យតុលាការជំនាញផ្សេងទៀត ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី ។

តុលាការរដ្ឋប្បវេណីនៃសាលាដំបូងជំនុំជម្រះរឿងក្តីរដ្ឋប្បវេណីដោយមានចៅក្រមទោល ឬដោយមានក្រុមប្រឹក្សាជំនុំជម្រះ ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី ។

## មាត្រា ២២.-

តុលាការពាណិជ្ជកម្មនៃសាលាដំបូង មានសមត្ថកិច្ចជំនុំជម្រះរឿងក្តីពាណិជ្ជកម្ម ដោយរួមទាំងរឿងក្តីក្ស័យធនក្នុងរឿងពាណិជ្ជកម្ម ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីពាណិជ្ជកម្ម ។

## មាត្រា ២៣.-

តុលាការពាណិជ្ជកម្មជំនុំជម្រះដោយមានចៅក្រម ០៣ (បី) រូប និងអមដោយទីប្រឹក្សា ០២ (ពីរ) រូប ជាពាណិជ្ជករ ឬអ្នកដែលមានចំណេះដឹងផ្នែកច្បាប់ពាណិជ្ជកម្មក្នុងករណីរឿងក្តីពាណិជ្ជកម្មដែលកម្មវត្ថុបណ្តឹងមានតម្លៃចាប់ពី ១.០០០.០០០.០០០ (មួយពាន់លាន) រៀល ឡើងទៅ ។

តុលាការពាណិជ្ជកម្មជំនុំជម្រះដោយមានចៅក្រម ០១ (មួយ) រូប និងអមដោយទីប្រឹក្សា ០២ (ពីរ) រូប ជាពាណិជ្ជករ ឬអ្នកដែលមានចំណេះដឹងផ្នែកច្បាប់ពាណិជ្ជកម្មក្នុងករណីរឿងក្តីពាណិជ្ជកម្មដែលកម្មវត្ថុបណ្តឹងមានតម្លៃចាប់ពី ១០០.០០០.០០០ (មួយរយលាន) រៀល ដល់ក្រោម ១.០០០.០០០.០០០ (មួយពាន់លាន) រៀល ។

តុលាការពាណិជ្ជកម្មជំនុំជម្រះដោយចៅក្រម ០១ (មួយ) រូប ដោយមិនចាំបាច់មានការចូលរួមពីទីប្រឹក្សាពាណិជ្ជកម្មឡើយក្នុងករណីរឿងក្តីពាណិជ្ជកម្ម ដែលកម្មវត្ថុបណ្តឹងមានតម្លៃក្រោម ១០០.០០០.០០០ (មួយរយលាន) រៀល ។

សាលក្រមរបស់តុលាការពាណិជ្ជកម្មត្រូវសម្រេចដោយចៅក្រម ០១ (មួយ) រូប ឬ ០៣ (បី) រូប យោងទៅតាមកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ ក្រោយពីបានពិគ្រោះយោបល់ជាមួយទីប្រឹក្សាពាណិជ្ជកម្ម ។

ទីប្រឹក្សាពាណិជ្ជកម្មមិនបំពេញមុខងាររបស់ខ្លួនជាអចិន្ត្រៃយ៍ នៅក្នុងតុលាការពាណិជ្ជកម្មនៃសាលាដំបូងឡើយ ។ ទីប្រឹក្សាពាណិជ្ជកម្មត្រូវចូលមកបំពេញមុខងាររបស់ខ្លួននៅសាលាដំបូងតាមការអញ្ជើញរបស់ប្រធានតុលាការពាណិជ្ជកម្មនៃសាលាដំបូង ។

## មាត្រា ២៤.-

បែបបទនៃការជ្រើសតាំង និងការបំពេញភារកិច្ចរបស់ទីប្រឹក្សាពាណិជ្ជកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

### មាត្រា ២៥.-

តុលាការការងារនៃសាលាដំបូង មានសមត្ថកិច្ចជំនុំជម្រះលើរឿងក្ដីការងារ ដោយអនុវត្តតាមបទប្បញ្ញត្តិស្ដីពីនីតិវិធីការងារ ។

### មាត្រា ២៦.-

តុលាការការងារនៃសាលាដំបូងត្រូវជំនុំជម្រះដោយចៅក្រម ០១ (មួយ) រូប អមដោយទីប្រឹក្សាការងារ ០២ (ពីរ) រូប ដែល ០១ (មួយ) រូបជាកម្មករនិយោជិត និង០១ (មួយ) រូបទៀតជានិយោជក ។

សាលក្រមរបស់តុលាការការងារនៃសាលាដំបូង ត្រូវសម្រេចដោយចៅក្រម ០១(មួយ) រូប ក្រោយពីបានពិគ្រោះយោបល់ជាមួយទីប្រឹក្សាការងារ ។

ទីប្រឹក្សាការងារ ពុំបំពេញមុខងាររបស់ខ្លួនជាអចិន្ត្រៃយ៍ នៅក្នុងតុលាការការងារនៃសាលាដំបូងឡើយ ។ ទីប្រឹក្សាការងារត្រូវចូលរួមបំពេញមុខងាររបស់ខ្លួននៅសាលាដំបូង តាមការអញ្ជើញរបស់ប្រធានតុលាការការងារ ។

### មាត្រា ២៧.-

តុលាការការងារដែលមានសមត្ថកិច្ច គឺតុលាការការងារនៃសាលាដំបូងនាទីកន្លែងវិវាទការងារ ។

ទោះបីមានការកំណត់សមត្ថកិច្ចដូចកថាខណ្ឌខាងលើក៏ដោយ ក៏កម្មករនិយោជិតអាចប្ដឹងទៅសាលាដំបូងតាមការកំណត់ដូចខាងក្រោម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ៖

- នាលំនៅឋានរបស់ខ្លួន ឬ
- នាទីតាំងនៃទីស្នាក់ការ ឬទីកន្លែងអាជីវកម្មជាចម្បងរបស់ក្រុមហ៊ុន ឬ
- នាលំនៅឋានរបស់អ្នកតំណាង ឬអ្នកទទួលខុសត្រូវរបស់ក្រុមហ៊ុន ប្រសិនបើគ្មានទីស្នាក់ការ ឬទីកន្លែងអាជីវកម្មជាចម្បងរបស់ក្រុមហ៊ុនទេ ។

### មាត្រា ២៨.-

បែបបទនៃការបោះឆ្នោតជ្រើសតាំង និងការបំពេញភារកិច្ចរបស់ទីប្រឹក្សាការងារ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ ។

## ផ្នែកទី ២
## អយ្យការអមសាលាដំបូង

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

### មាត្រា ២៩.-

សមាសភាពអយ្យការអមសាលាដំបូង រួមមាន៖

- ព្រះរាជអាជ្ញា
- ព្រះរាជអាជ្ញារង
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅអយ្យការអមសាលាដំបូង ។

**មាត្រា ៣០.-**

អង្គការអយ្យការជាអង្គអវិភាគ ។ អយ្យការមានមុខងារធ្វើបណ្តឹងអាជ្ញា និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ព្រមទាំងអនុវត្តមុខងារផ្សេងទៀតតាមការកំណត់របស់ច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង គឺជាតំណាងអយ្យការអមសាលាដំបូងដែលខ្លួនបំពេញការងារ ។ ព្រះរាជអាជ្ញារង ចូលរួមអនុវត្តមុខងាររបស់អយ្យការក្រោមការដឹកនាំ និងទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង ។

ក្នុងករណីមានធុរៈ ឬមានជំងឺ ឬអវត្តមាន ព្រះរាជអាជ្ញាត្រូវចាត់តាំងព្រះរាជអាជ្ញារងណាម្នាក់ដើម្បីជំនួសបាន ។ ក្នុងករណីដែលព្រះរាជអាជ្ញាស្ថិតក្នុងស្ថានភាពមិនអាចបំពេញការងារបាន ឬក្នុងករណីតំណែងព្រះរាជអាជ្ញាស្ថិតក្នុងស្ថានភាពទំនេរ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់តាំងព្រះរាជអាជ្ញារងណាម្នាក់ឲ្យធ្វើជាព្រះរាជអាជ្ញាស្តីទីជំនួសបាន ដើម្បីធានាដំណើរការរបស់អយ្យការអមសាលាដំបូងរហូតដល់មានការតែងតាំងព្រះរាជអាជ្ញាជាផ្លូវការ ។

**មាត្រា ៣១.-**

ព្រះរាជអាជ្ញាមានអំណាចលើព្រះរាជអាជ្ញារងទាំងអស់ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ ព្រះរាជអាជ្ញាចាត់តាំង និងបែងចែកការងារដល់ព្រះរាជអាជ្ញារងទាំងអស់ ។

ព្រះរាជអាជ្ញាមានសិទ្ធិធ្វើអធិបញ្ញាឲ្យព្រះរាជអាជ្ញារងធ្វើការចោទប្រកាន់ ឬក៏ចាត់ឲ្យចោទប្រកាន់ ឬក៏ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមដែលខ្លួនយល់ឃើញថាជាការគួរ ។ សេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញារង ត្រូវតែបញ្ជូនទៅព្រះរាជអាជ្ញាពិនិត្យនៅមុនពេលសវនាការ ។ ប្រសិនបើព្រះរាជអាជ្ញាមិនយល់ព្រមលើសេចក្តីសន្និដ្ឋាននោះទេ ហើយតំណាងអយ្យការដែលជាអ្នកធ្វើសេចក្តីសន្និដ្ឋាននោះនៅតែមិនព្រមធ្វើតាមព្រះរាជអាជ្ញាអាចចាត់តាំងព្រះរាជអាជ្ញារងផ្សេងទៀត ឬក៏ចាត់តាំងខ្លួនឯងតែម្តង ឲ្យធ្វើជាតំណាងអយ្យការនៅក្នុងសវនាការនៃសាលាដំបូង ។

ប៉ុន្តែ នៅពេលសវនាការ ព្រះរាជអាជ្ញារងអាចធ្វើការកត់សម្គាល់ដោយផ្ទាល់មាត់បានដោយសេរីតាមការដែលខ្លួនយល់ឃើញថា ស្របតាមសតិសម្បជញ្ញៈរបស់ខ្លួន ។ គ្មានការចោទប្រកាន់ខាងវិន័យណាមួយដែលអាចត្រូវធ្វើចំពោះតំណាងអយ្យការ ដោយសារតែការកត់សម្គាល់ផ្ទាល់មាត់របស់ខ្លួននាពេលសវនាការ ខុសពីសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរឡើយ ។

# ផ្នែកទី ៣
# លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង

## មាត្រា៣២.-

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង គឺជាសេនាធិការឲ្យសាលាដំបូង និងអយ្យការអមសាលាដំបូងលើ៖

- ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ
- ការងារគ្រប់គ្រងរដ្ឋបាលតុលាការ សម្រាប់ជាជំនួយបច្ចេកទេសដល់កម្មវិធីការងាររបស់សាលាដំបូង និងអយ្យការអមសាលាដំបូង
- ការងាររៀបចំគម្រោងថវិកាជូនប្រធានសាលាដំបូងនិងព្រះរាជអាជ្ញា ដើម្បីពិនិត្យ និងសម្រេច
- របាយការណ៍អំពីការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុជាប្រចាំជូនប្រធានសាលាដំបូង និងព្រះរាជអាជ្ញា
- ការអនុវត្តការងារថវិកាតាមគម្រោងដែលបានអនុម័ត
- ការងារទំនាក់ទំនងសាធារណៈ
- ការងារបញ្ជូនសាលក្រមរបស់សាលាដំបូង ជូនទៅក្រសួងយុត្តិធម៌ឲ្យបានទៀងទាត់
- រៀបចំ និងបញ្ជូនរបាយការណ៍ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនទៅក្រសួងយុត្តិធម៌
- ការងារផ្សេងទៀតដែលប្រធានសាលាដំបូង និងព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងប្រគល់ឲ្យ
- អនុវត្តការងារផ្សេងទៀតតាមការកំណត់នៃបទដ្ឋានគតិយុត្ត ។

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ត្រូវបែងចែកជាការិយាល័យតាមចំនួនចាំបាច់ជាក់ស្តែង ។ ការិយាល័យដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនតាមការចាំបាច់ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## មាត្រា ៣៣.-

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនតាមការចាំបាច់ ។ ប្រធានលេខាធិការដ្ឋាន ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយប្រធានសាលាដំបូង និងព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង ។ មន្ត្រីបម្រើការងារនៅលេខាធិការដ្ឋានថ្នាក់ក្រោមប្រធានលេខាធិការដ្ឋាន ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ប្រធាន និងអនុប្រធានលេខាធិការដ្ឋាន ត្រូវជ្រើសរើសចេញពីមន្ត្រីរាជការ ដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុ យ៉ាងតិចចំនួន ០៥ (ប្រាំ) ឆ្នាំ ។ ប្រធាន និង អនុប្រធានការិយាល័យ ត្រូវជ្រើសរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុ យ៉ាងតិចចំនួន ០៣ (បី) ឆ្នាំ ។

មន្ត្រីបម្រើការងារនៅលេខាធិការដ្ឋានទាំងអស់ ដោយរួមទាំងប្រធានលេខាធិការដ្ឋានផងត្រូវមានក្របខណ្ឌរបស់ខ្លួននៅក្រសួងយុត្តិធម៌ ។

**មាត្រា ៣៤.-**

សន្និបាតរបស់សាលាដំបូង ប្រព្រឹត្តទៅក្រោមអធិបតីភាពនៃប្រធានសាលាដំបូង និងព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង ដើម្បីបូកសរុបលទ្ធផលការងារកន្លងមក និងកំណត់ទិសដៅការងាររដ្ឋបាលរបស់សាលាដំបូងសម្រាប់ឆ្នាំបន្ទាប់ទៀត ។ របាយការណ៍សន្និបាតរបស់សាលាដំបូងត្រូវបញ្ជូនទៅក្រសួងយុត្តិធម៌ ។

## ជំពូកទី ៣
## សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
## ផ្នែកទី ១
## សាលាឧទ្ធរណ៍
## អនុផ្នែកទី ១
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់សាលាឧទ្ធរណ៍

**មាត្រា ៣៥.-**

សាលាឧទ្ធរណ៍ គឺជាសាលាជម្រះក្តីថ្នាក់ទីពីរ ។

សាលាឧទ្ធរណ៍រួមមានសាលាឧទ្ធរណ៍ភ្នំពេញ និងសាលាឧទ្ធរណ៍តំបន់ ។ ការដាក់ឲ្យដំណើរការសាលាឧទ្ធរណ៍តំបន់នីមួយៗ និងការកំណត់ពីសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍តំបន់នេះ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ ។

**មាត្រា ៣៦.-**

សមាសភាពសាលាឧទ្ធរណ៍រួមមាន៖

- ប្រធាន
- អនុប្រធាន
- ចៅក្រម
- ក្រឡាបញ្ជីនិង

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS

- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅសាលាឧទ្ធរណ៍ ។

**មាត្រា ៣៧.-**

សាលាឧទ្ធរណ៍មានសភាជំនាញ ដូចខាងក្រោម៖

- សភាព្រហ្មទណ្ឌ
- សភារដ្ឋប្បវេណី
- សភាស៊ើបសួរ
- សភាពាណិជ្ជកម្ម
- សភាការងារ ។

ក្នុងករណីចាំបាច់សភា ជំនាញផ្សេងទៀតនៃសាលាឧទ្ធរណ៍អាចត្រូវបង្កើតឡើង ដោយព្រះរាជក្រឹត្យ ។

សភានីមួយៗ ចេញសេចក្តីសម្រេចដោយស្វ័យភាព ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងនាមសាលាឧទ្ធរណ៍ដែលសភានោះស្ថិតនៅ ។

**មាត្រា ៣៨.-**

សមាសភាពរបស់សភានីមួយៗរួមមាន៖

- ប្រធានសភា
- ចៅក្រម និង
- ក្រឡាបញ្ជី ។

ប្រធានសភានីមួយៗ ត្រូវចាត់តាំងដោយប្រធានសាលាឧទ្ធរណ៍ ។

ចំនួនចៅក្រម ក្រឡាបញ្ជី និងដំណើរការរបស់សភាទាំងនេះ ត្រូវកំណត់ដោយប្រធានសាលាឧទ្ធរណ៍ ។

**មាត្រា ៣៩.-**

សភានីមួយៗនៃសាលាឧទ្ធរណ៍សម្រេចសេចក្តីដោយមានចៅក្រម ០៣(បី) រូប ដែល ០១(មួយ) រូបជាប្រធាន ដោយអនុលោមតាមបទប្បញ្ញត្តិស្តីពីនីតិវិធីជាធរមាន ។

រឿងក្តីណាដែលតុលាការកំពូលបានបង្វិលមកវិញ នោះសាលាឧទ្ធរណ៍ត្រូវជំនុំជម្រះនៅក្នុងសវនាការមួយ ដែលមានចៅក្រម ០៥ (ប្រាំ) រូប ហើយសុទ្ធតែជាចៅក្រមដែលមិនបានចូលរួមជំនុំជម្រះលើកមុន ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីជាធរមាន ។

**មាត្រា ៤០.–**

ប្រធានសាលាឧទ្ធរណ៍ ចាត់វិធានការគ្រប់គ្រងជាចាំបាច់សម្រាប់ដំណើរការនៃសាលាឧទ្ធរណ៍ ។ ប្រធានសាលាឧទ្ធរណ៍ត្រូវចេញដីកាសម្រេចដើម្បី៖

- ចាត់តាំងអនុប្រធានសាលាឧទ្ធរណ៍ណាម្នាក់ ឲ្យចាត់ចែងការងារជំនួសខ្លួនបានក្នុងករណីចាំបាច់
- ចាត់តាំងអនុប្រធានសាលាឧទ្ធរណ៍ ឲ្យទទួលបន្ទុកធ្វើជាប្រធានសភានីមួយៗទៅតាមជំនាញ និងបទពិសោធន៍ការងារ ។ ក្នុងករណីខ្វះអនុប្រធានសាលាឧទ្ធរណ៍ ប្រធានសាលាឧទ្ធរណ៍ អាចចាត់តាំងចៅក្រមណាម្នាក់ដែលមានឋានន្តរស័ក្តិខ្ពស់ ឬមានបទពិសោធន៍ការងារច្រើន ឲ្យធ្វើជាប្រធានសភាបាន
- កំណត់លំដាប់សម្រាប់ជំនួសចៅក្រមនៅក្នុងក្រុមប្រឹក្សាជំនុំជម្រះនៃសភានីមួយៗ ក្នុងករណីចៅក្រមណាម្នាក់អវត្តមាន ឬមានធុរៈ
- ចាត់តាំង និងផ្លាស់ប្តូរក្រឡាបញ្ជីនៅក្នុងសភានីមួយៗ តាមការចាំបាច់ជាក់ស្តែង ។

## អនុផ្នែកទី ២
## សមត្ថកិច្ច

**មាត្រា ៤១.–**

សាលាឧទ្ធរណ៍មានសមត្ថកិច្ចជំនុំជម្រះរឿងក្តី ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួនលើកលែងតែរឿងក្តីទាំងឡាយណាដែលច្បាប់ប្រគល់សមត្ថកិច្ចទៅឲ្យតុលាការផ្សេងទៀត ។

**មាត្រា ៤២.–**

សាលាឧទ្ធរណ៍សម្រេចសេចក្តីទាំងអង្គហេតុ និងអង្គច្បាប់ លើរឿងក្តីដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៤៣.–**

សភាព្រហ្មទណ្ឌមានសមត្ថកិច្ចជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូង និងរឿងក្តីផ្សេងទៀត ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៤៤.–**

សភារដ្ឋប្បវេណីមានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រម និងបណ្តឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលាដំបូងក្នុងរឿងក្តីរដ្ឋប្បវេណី និងរឿងក្តីផ្សេងទៀតដែលស្ថិតក្នុងដែន

សមត្ថកិច្ចរបស់ខ្លួន ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជាធរមាន ។ សេចក្តីសម្រេច ត្រូវធ្វើឡើងដោយចៅក្រម ០៣ (បី) រូប ដែល ០១ (មួយ) រូប ជាប្រធាន ។

## មាត្រា ៤៥.-

សភាស៊ើបសួរមានសមត្ថកិច្ចដោះស្រាយលើបណ្តឹងនានាចំពោះកិច្ចស៊ើបសួរ ឬដីកាសម្រេចនានារបស់ចៅក្រមស៊ើបសួរ និងរឿងក្តីផ្សេងទៀតដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន ។ សេចក្តីសម្រេចរបស់សភាស៊ើបសួរត្រូវធ្វើឡើងដោយចៅក្រម ០៣ (បី) រូបដែល ០១ (មួយ) រូប ជាប្រធាន ។

## មាត្រា ៤៦.-

សភាពាណិជ្ជកម្មមានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នឹងសាលក្រម និងបណ្តឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលាដំបូងក្នុងរឿងក្តីពាណិជ្ជកម្ម និងរឿងក្តីផ្សេងទៀត ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីពាណិជ្ជកម្ម ។ សភាពាណិជ្ជកម្មនៃសាលាឧទ្ធរណ៍ត្រូវជំនុំជម្រះដោយចៅក្រម ០៣ (បី) រូប ដែល ០១(មួយ) រូប ជាប្រធាននិងអមដោយទីប្រឹក្សា ០២ (ពីរ) រូបជាពាណិជ្ជករ ឬអ្នកដែលមានចំណេះដឹងផ្នែកច្បាប់ពាណិជ្ជកម្ម និងមិនមែនជាទីប្រឹក្សាពាណិជ្ជកម្មនៅក្នុងរឿងក្តីតែមួយ ដែលត្រូវបានជំនុំជម្រះដោយសាលាដំបូង និងសាលាឧទ្ធរណ៍ ។ សាលដីការបស់សភាពាណិជ្ជកម្មនៃសាលាឧទ្ធរណ៍ត្រូវធ្វើឡើងដោយចៅក្រម ០៣ (បី)រូប ដែល ០១(មួយ)រូប ជាប្រធានក្រោយពីបានពិគ្រោះយោបល់ជាមួយទីប្រឹក្សាពាណិជ្ជកម្ម ។

ទីប្រឹក្សាពាណិជ្ជកម្មមិនបំពេញមុខងាររបស់ខ្លួនជាអចិន្ត្រៃយ៍ នៅក្នុងសភាពាណិជ្ជកម្មនៃសាលាឧទ្ធរណ៍ឡើយ ។ ទីប្រឹក្សាពាណិជ្ជកម្មត្រូវចូលមកបំពេញមុខងាររបស់ខ្លួនតាមការអញ្ជើញរបស់ប្រធានសភាពាណិជ្ជកម្មនៃសាលាឧទ្ធរណ៍ប៉ុណ្ណោះ ។

បែបបទនៃការជ្រើសតាំង និងការបំពេញភារកិច្ចរបស់ទីប្រឹក្សាពាណិជ្ជកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

## មាត្រា ៤៧.-

សភាការងារនៃសាលាឧទ្ធរណ៍ មានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នឹងសាលក្រម និងបណ្តឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលាដំបូង ក្នុងរឿងក្តីការងារ និងរឿងក្តីផ្សេងទៀត ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីការងារ ។ សភាការងារនៃសាលាឧទ្ធរណ៍ត្រូវជំនុំជម្រះដោយចៅក្រម ០៣ (បី) រូប ដែល ០១(មួយ) រូប ជាប្រធាន និងអមដោយទីប្រឹក្សា ០២ (ពីរ) រូប ដែល ០១ (មួយ) រូប ជាកម្មករនិយោជិត និង ០១ (មួយ) រូប ទៀតជានិយោជក និងមិនមែនជាទីប្រឹក្សាការងារនៅក្នុងរឿងក្តីតែមួយ ដែលត្រូវបានជំនុំជម្រះដោយសាលាដំបូង និង

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

សាលាឧទ្ធរណ៍ ។ សេចក្តីសម្រេចរបស់សភាការងារនៃសាលាឧទ្ធរណ៍ ត្រូវធ្វើឡើងដោយចៅក្រម ០៣ (បី) រូប ដែល ០១ (មួយ) រូប ជាប្រធាន ក្រោយពីបានពិគ្រោះយោបល់ជាមួយទីប្រឹក្សាការងារ ។

ទីប្រឹក្សាការងារមិនបំពេញមុខងាររបស់ខ្លួនជាអចិន្ត្រៃយ៍ នៅក្នុងសភាការងារនៃសាលាឧទ្ធរណ៍ឡើយ ។ ទីប្រឹក្សាការងារត្រូវចូលមកបំពេញមុខងាររបស់ខ្លួន តាមការអញ្ជើញរបស់ប្រធានសភាការងារនៃសាលាឧទ្ធរណ៍ប៉ុណ្ណោះ ។

បែបបទនៃការជ្រើសតាំង និងការបំពេញភារកិច្ចរបស់ទីប្រឹក្សាការងារត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ ។

**មាត្រា ៤៨.-**

សភារួមក្រុមអាចត្រូវបង្កើតឲ្យមានដំណើរការបាន ដោយដីកាសម្រេចរបស់ប្រធានសាលាឧទ្ធរណ៍ តាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬតាមការស្នើសុំរបស់ប្រធានសភាណាមួយ កាលណាមានរឿងក្តីណាមួយចោទជាបញ្ហាដែលត្រូវស្ថិតនៅក្នុងសមត្ថកិច្ចរបស់សភាច្រើន ឬប្រសិនបើបញ្ហានោះបានទទួលនូវដំណោះស្រាយខ្វែងគ្នា នៅចំពោះមុខសភាផ្សេងគ្នានៃសាលាឧទ្ធរណ៍តែមួយ ។ សភារួមក្រុមប្រព្រឹត្តទៅតាមការកោះអញ្ជើញរបស់ប្រធានសាលាឧទ្ធរណ៍ ។

សេចក្តីសម្រេចរបស់សភារួមក្រុម អំពីសមត្ថកិច្ចរវាងសភាផ្សេងៗ និងវិវាទច្បាប់ មានអំណាចបង្ខំឲ្យសភាទាំងអស់នៃសាលាឧទ្ធរណ៍គោរពតាម ។

កាលបើសភារួមក្រុមត្រូវបង្កើតឡើង សភានេះត្រូវមានសមាសភាពជាចៅក្រមយ៉ាងតិច ០៥ (ប្រាំ) រូប ដែលបែងចែកស្មើគ្នារវាងចៅក្រមជាតំណាងនៃសភាពាក់ព័ន្ធ ។ សភារួមក្រុមស្ថិតក្រោមអធិបតីភាពរបស់ប្រធានសាលាឧទ្ធរណ៍ ។

ប្រធានសាលាឧទ្ធរណ៍ចេញដីកាសម្រេច ដោយអនុលោមតាមសេចក្តីសម្រេចរបស់សភារួមក្រុម ។ ដីកាសម្រេចលើវិវាទសមត្ថកិច្ច និងវិវាទច្បាប់ គឺជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ។

## ផ្នែកទី ២
## មហាអយ្យការអមសាលាឧទ្ធរណ៍

**មាត្រា ៤៩.-**

នៅអមសាលាឧទ្ធរណ៍មានមហាអយ្យការដែលមានសមាសភាពដូចខាងក្រោម៖

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- ក្រឡាបញ្ជី និង

- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅមហាអយ្យការអមសាលាឧទ្ធរណ៍ ។

## មាត្រា ៥០.-

មុខងាររបស់មហាអយ្យការអមសាលាឧទ្ធរណ៍ ត្រូវបានប្រគល់ឲ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ចូលរួមអនុវត្តមុខងារនេះ ក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

ក្នុងករណីមានធុរៈ ឬមានជំងឺ ឬអវត្តមាន អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវចាត់តាំងអគ្គព្រះរាជអាជ្ញារងមួយរូប ឬបើគ្មានអគ្គព្រះរាជអាជ្ញារងទេ អាចចាត់តាំងព្រះរាជអាជ្ញាណាម្នាក់ដើម្បីជំនួសខ្លួនបាន ។

ក្នុងករណីដែលអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ស្ថិតក្នុងស្ថានភាពមិនអាចបំពេញការងារបាន ឬក្នុងករណីតំណែងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ស្ថិតក្នុងស្ថានភាពទំនេររដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់តាំងអគ្គព្រះរាជអាជ្ញារងណាម្នាក់ ឲ្យធ្វើជាអគ្គព្រះរាជអាជ្ញាស្ដីទីជំនួសបាន ដើម្បីធានាដំណើរការរបស់មហាអយ្យការអមសាលាឧទ្ធរណ៍ រហូតដល់មានការតែងតាំងអគ្គព្រះរាជអាជ្ញាជាផ្លូវការ ។

## មាត្រា ៥១.-

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានអំណាចគ្រប់គ្រងលើអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ចាត់តាំង និងបែងចែកដល់អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទៅក្នុងការងារផ្សេងៗនៃមហាអយ្យការនិងអង្គជំនុំជម្រះ ។

សេចក្ដីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវតែបញ្ជូនទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដើម្បីពិនិត្យនៅមុនពេលសវនាការ ។ ប្រសិនបើអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មិនយល់ព្រមលើសេចក្ដីសន្និដ្ឋាននោះទេ ហើយតំណាងមហាអយ្យការដែលជាអ្នកធ្វើសេចក្ដីសន្និដ្ឋាននោះ នៅតែមិនព្រមធ្វើតាម អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចចាត់តាំងអគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាផ្សេងទៀត ឬក៏ចាត់តាំងខ្លួនឯងតែម្ដងឲ្យធ្វើជាតំណាងមហាអយ្យការនៅក្នុងសវនាការ ។

ប៉ុន្តែ នៅពេលសវនាការ អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចធ្វើការកត់សម្គាល់ដោយផ្ទាល់មាត់បានដោយសេរី តាមការដែលខ្លួនយល់ឃើញថា ស្របតាមសតិសម្បជញ្ញៈរបស់ខ្លួន ។ គ្មានការចោទប្រកាន់ខាងវិន័យណាមួយដែលអាចត្រូវធ្វើចំពោះតំណាងមហាអយ្យការដោយសារតែការកត់សម្គាល់ផ្ទាល់មាត់របស់ខ្លួននាពេលសវនាការ ខុសពីសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរឡើយ ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានសិទ្ធិធ្វើអធិបញ្ញាឲ្យព្រះរាជអាជ្ញាអមសាលាដំបូង ធ្វើការចោទប្រកាន់បាន ដោយអនុវត្តតាមបទប្បញ្ញត្តិស្ដីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

## ផ្នែកទី ៣
## អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍

### មាត្រា ៥២.-

អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ គឺជាសេនាធិការឲ្យសាលាឧទ្ធរណ៍ និង មហាអយ្យការអមសាលាឧទ្ធរណ៍លើ៖

- ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ
- ការងារគ្រប់គ្រងរដ្ឋបាលតុលាការសម្រាប់ជាជំនួយការបច្ចេកទេសដល់កម្មវិធីការងាររបស់ សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
- ការងាររៀបចំគម្រោងថវិកាជូនប្រធានសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញាអមសាលា ឧទ្ធរណ៍ដើម្បីពិនិត្យ និងសម្រេច
- ការអនុវត្តការងារថវិកាតាមគម្រោងដែលបានអនុម័ត
- រាយការណ៍អំពីការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុជាប្រចាំជូនប្រធានសាលាឧទ្ធរណ៍ និង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- ការងារទំនាក់ទំនងសាធារណៈ
- ការងារបញ្ជូនសាលដីការបស់សាលាឧទ្ធរណ៍ជូនទៅក្រសួងយុត្តិធម៌ឲ្យបានទៀងទាត់
- រៀបចំ និងបញ្ជូនរបាយការណ៍ ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនទៅក្រសួងយុត្តិធម៌
- ការងារផ្សេងទៀតដែលប្រធានសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្រគល់ឲ្យ
- អនុវត្តការងារផ្សេងទៀតតាមការកំណត់នៃបទដ្ឋានគតិយុត្ត។

អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍បែងចែកជានាយកដ្ឋាន ដែលដឹកនាំដោយប្រធាន មួយរូប និងអនុប្រធានមួយចំនួនតាមការចាំបាច់។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ត្រូវកំណត់ ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

### មាត្រា ៥៣.-

អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ ដឹកនាំដោយអគ្គលេខាធិការមួយរូប និងអគ្គលេខាធិការ រងមួយចំនួនតាមការចាំបាច់ ។ អគ្គលេខាធិការ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់ នាយករដ្ឋមន្ត្រី ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិគ្រោះយោបល់ជាមួយប្រធានសាលាឧទ្ធរណ៍ និងអគ្គព្រះរាជ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

អាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ ដើម្បីលើកសំណើជូននាយករដ្ឋមន្ត្រី ។ អគ្គលេខាធិការត្រូវជ្រើសរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុ យ៉ាងតិចចំនួន ០៧ (ប្រាំពីរ) ឆ្នាំ ។

អគ្គលេខាធិការរង និងប្រធាននាយកដ្ឋានត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយប្រធានសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ ។ អគ្គលេខាធិការរង និងប្រធាននាយកដ្ឋាន ត្រូវជ្រើសរើសចេញពីមន្ត្រីរាជការ ដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុ យ៉ាងតិចចំនួន ០៥ (ប្រាំ) ឆ្នាំ ។

មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋានថ្នាក់ក្រោមប្រធាននាយកដ្ឋាន ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ អនុប្រធាននាយកដ្ឋាន ព្រមទាំងប្រធាន និងអនុប្រធានការិយាល័យ ត្រូវជ្រើសរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុ យ៉ាងតិចចំនួន ០៣ (បី) ឆ្នាំ ។

មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋានទាំងអស់ដោយរួមទាំងអគ្គលេខាធិការផង ត្រូវមានក្របខណ្ឌរបស់ខ្លួននៅក្រសួងយុត្តិធម៌ ។

**មាត្រា ៥៤.-**

សន្និបាតរបស់សាលាឧទ្ធរណ៍នីមួយៗ ត្រូវប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ប្រធានសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍នោះ ដើម្បីបូកសរុបលទ្ធផលការងារកន្លងមក និងកំណត់ទិសដៅការងាររដ្ឋបាលរបស់សាលាឧទ្ធរណ៍សម្រាប់ឆ្នាំបន្ទាប់ទៀត ។ របាយការណ៍សន្និបាតរបស់សាលាឧទ្ធរណ៍ ត្រូវបញ្ជូនទៅក្រសួងយុត្តិធម៌ ។

## ជំពូកទី ៤
## តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល
### ផ្នែកទី ១
### តុលាការកំពូល
### អនុផ្នែកទី ១
### ការរៀបចំ និងការប្រព្រឹត្តទៅរបស់តុលាការកំពូល

**មាត្រា ៥៥.-**

តុលាការកំពូលមានតែមួយគត់ ដែលមានទីតាំងនៅរាជធានីភ្នំពេញ ។

**មាត្រា ៥៦.-**

សមាសភាពតុលាការកំពូលរួមមាន៖

- ប្រធាន
- អនុប្រធាន
- ចៅក្រម
- ក្រឡាបញ្ជី និង
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅតុលាការកំពូល ។

**មាត្រា ៥៧.-**

តុលាការកំពូលមានសភាជំនាញ ដូចខាងក្រោម៖

- សភាព្រហ្មទណ្ឌ
- សភារដ្ឋប្បវេណី
- សភាពាណិជ្ជកម្ម
- សភាការងារ ។

ក្នុងករណីចាំបាច់ សភាជំនាញផ្សេងទៀតរបស់តុលាការកំពូល អាចត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យ ។

សភានីមួយៗ ចេញសេចក្ដីសម្រេចរបស់ខ្លួនប្រកបដោយស្វ័យភាព ក្នុងនាមតុលាការកំពូល ។

**មាត្រា ៥៨.-**

សមាសភាពរបស់សភានីមួយៗរួមមាន៖

- ប្រធានសភា
- ចៅក្រម និង
- ក្រឡាបញ្ជី ។

ប្រធានសភានីមួយៗត្រូវបានចាត់តាំងដោយប្រធានតុលាការកំពូល ។ ចំនួនចៅក្រម ក្រឡាបញ្ជី និងដំណើរការរបស់សភាទាំងនេះ ត្រូវកំណត់ដោយប្រធានតុលាការកំពូល។

**មាត្រា ៥៩.-**

សភានីមួយៗនៃតុលាការកំពូលសម្រេចសេចក្ដីដោយចៅក្រម ០៥(ប្រាំ)រូប ដែល ០១ (មួយ) រូបជាប្រធាន ដោយអនុលោមតាមបទប្បញ្ញត្តិស្ដីពីនីតិវិធីជាធរមាន ។

**មាត្រា ៦០.-**

ប្រធានតុលាការកំពូល ចាត់វិធានការគ្រប់គ្រងជាចាំបាច់ក្នុងការប្រព្រឹត្តទៅនៃតុលាការកំពូល និងណែនាំសភាទាំងអស់របស់តុលាការកំពូលឲ្យអនុវត្តច្បាប់ ។

ប្រធានតុលាការកំពូលត្រូវចេញដីកាសម្រេចដើម្បី៖

- ចាត់តាំងអនុប្រធានតុលាការកំពូលណាម្នាក់ ឲ្យចាត់ចែងការងារជំនួសខ្លួនបានក្នុងករណីចាំបាច់
- ចាត់តាំងអនុប្រធានតុលាការកំពូល ឲ្យទទួលបន្ទុកធ្វើជាប្រធានសភានីមួយៗ ទៅតាមជំនាញ និងបទពិសោធន៍ការងារ ។ ក្នុងករណីខ្វះអនុប្រធាន ប្រធានតុលាការកំពូលអាចចាត់តាំងចៅក្រមណាម្នាក់ឲ្យធ្វើជាប្រធានសភាបាន ។

## អនុផ្នែកទី ២
## សមត្ថកិច្ច

**មាត្រា ៦១.-**

តុលាការកំពូល មានសមត្ថកិច្ចដោះស្រាយរឿងក្ដីដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនស្របតាមការកំណត់របស់ច្បាប់ ។

**មាត្រា ៦២.-**

សភាពេញអង្គត្រូវបង្កើតឲ្យមានដំណើរការ ដោយដីកាសម្រេចរបស់ប្រធានតុលាការកំពូល ដើម្បីជំនុំជម្រះ ជាអាទិ៍៖

- លើបណ្ដឹងសាទុក្ខលើកទីពីរចំពោះសាលដីការបស់សាលាឧទ្ធរណ៍ ស្របតាមនីតិវិធីជាធរមាន
- លើបណ្ដឹងសើរើចំពោះសាលក្រម និងសាលដីកាស្ថាពរ ស្របតាមនីតិវិធីជាធរមាន ។

សភាពេញអង្គក៏អាចត្រូវបង្កើតឲ្យមានដំណើរការផងដែរ ដើម្បីជំនុំជម្រះលើបណ្ដឹងសើរើ ឬបណ្ដឹងជំនុំជម្រះសាជាថ្មី ក្នុងករណីដែលមានការស្នើសុំឲ្យមានការពិនិត្យ និងសម្រេចឡើងវិញចំពោះរឿងក្ដីណាមួយ ពីព្រះមហាក្សត្រដែលជាព្រះប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

សភាពេញអង្គប្រព្រឹត្តទៅតាមការកោះអញ្ជើញរបស់ប្រធានតុលាការកំពូល ។

សភាពេញអង្គនៃតុលាការកំពូល គឺជាអង្គជំនុំជម្រះដែលចេញសេចក្ដីសម្រេចក្នុងនាមតុលាការកំពូល ។

កាលបើសភាពេញអង្គត្រូវបង្កើតឲ្យមានឡើង សភានេះត្រូវមានសមាសភាពចៅក្រមយ៉ាងតិច ០៩ (ប្រាំបួន) រូប ដែលមានចៅក្រមជាតំណាងនៃសភាទាំងអស់របស់តុលាការកំពូល ។

សភាពេញអង្គស្ថិតក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូល ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## មាត្រា ៦៣.-

សភារួមក្រុមអាចត្រូវបង្កើតឲ្យមានដំណើរការបាន ដោយដីកាសម្រេចរបស់ប្រធានតុលាការកំពូល តាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬតាមការស្នើសុំរបស់ប្រធានសភាណាមួយកាលណាមានរឿងក្តីណាមួយ ចោទជាបញ្ហាដែលត្រូវស្ថិតនៅក្នុងសមត្ថកិច្ចរបស់សភាច្រើន ឬប្រសិនបើបញ្ហានោះបានទទួលនូវដំណោះស្រាយខ្វែងគ្នា នៅចំពោះមុខសភាផ្សេងគ្នានៃតុលាការកំពូល ។ សភារួមក្រុមប្រព្រឹត្តទៅតាមការកោះអញ្ជើញរបស់ប្រធានតុលាការកំពូល ។

សេចក្តីសម្រេចរបស់សភារួមក្រុមអំពីសមត្ថកិច្ចរវាងសភាផ្សេងៗ និងវិវាទអំពីច្បាប់ មានអំណាចបង្ខំឲ្យសភាទាំងអស់នៃតុលាការកំពូល និងតុលាការថ្នាក់ក្រោមគោរពតាម ។

កាលបើសភារួមក្រុមត្រូវបង្កើតឲ្យមានឡើង សភានេះត្រូវមានសមាសភាពចៅក្រមយ៉ាងតិច ០៩ (ប្រាំបួន) រូប ដែលបែងចែកស្មើគ្នារវាងចៅក្រមជាតំណាងនៃសភាពាក់ព័ន្ធ ។ សភារួមក្រុមស្ថិតក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូល ។

ប្រធានតុលាការកំពូលចេញដីកាសម្រេច ដោយអនុលោមតាមសេចក្តីសម្រេចរបស់សភារួមក្រុម ។ ដីកាសម្រេចលើវិវាទសមត្ថកិច្ច និងវិវាទអំពីច្បាប់ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ។

## មាត្រា ៦៤.-

សភាព្រហ្មទណ្ឌនៃតុលាការកំពូលមានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងសាទុក្ខ ចំពោះសាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

## មាត្រា ៦៥.-

សភារដ្ឋប្បវេណីនៃតុលាការកំពូលមានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងសាទុក្ខ ចំពោះសាលដីកា និងបណ្តឹងជំទាស់ចំពោះដីកាសម្រេចក្នុងរឿងរដ្ឋប្បវេណីរបស់សាលាឧទ្ធរណ៍ ព្រមទាំងលើបណ្តឹងសាទុក្ខចំពោះសាលក្រមរដ្ឋប្បវេណីរបស់សាលាដំបូង និងរឿងក្តីផ្សេងទៀតដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជាធរមាន ។

## មាត្រា ៦៦.-

សភាពាណិជ្ជកម្មនៃតុលាការកំពូល មានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងសាទុក្ខចំពោះសាលដីកា និងបណ្តឹងជំទាស់ចំពោះដីកាសម្រេចក្នុងរឿងពាណិជ្ជកម្មរបស់សាលាឧទ្ធរណ៍ ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីពាណិជ្ជកម្ម ។

## មាត្រា ៦៧.-

សភាការងារនៃតុលាការកំពូល មានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងសាទុក្ខចំពោះសាលដីកា និងបណ្តឹងជំទាស់ចំពោះដីកាសម្រេចក្នុងរឿងការងាររបស់សាលាឧទ្ធរណ៍ ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីការងារ ។

## ផ្នែកទី ២
## មហាអយ្យការអមតុលាការកំពូល

### មាត្រា ៦៨.–

មហាអយ្យការអមតុលាការកំពូលមានសមាសភាពដូចខាងក្រោម៖

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- ក្រឡាបញ្ជី និង
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅមហាអយ្យការអមតុលាការកំពូល ។

### មាត្រា ៦៩.–

មុខងាររបស់មហាអយ្យការអមតុលាការកំពូល ត្រូវបានប្រគល់ឲ្យអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល ចូលរួមអនុវត្តមុខងារនេះ ក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ។

ក្នុងករណីមានធុរៈ ឬមានជំងឺ ឬអវត្តមាន អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ត្រូវចាត់តាំងអគ្គព្រះរាជអាជ្ញារងមួយរូប ឬបើគ្មានអគ្គព្រះរាជអាជ្ញារងទេ អាចចាត់តាំងព្រះរាជអាជ្ញាណាម្នាក់ដើម្បីជំនួសខ្លួនបាន ។

ក្នុងករណីដែលអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ស្ថិតក្នុងស្ថានភាពមិនអាចបំពេញការងារបាន ឬក្នុងករណីតំណែងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលស្ថិតក្នុងស្ថានភាពទំនេររដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់តាំងអគ្គព្រះរាជអាជ្ញារងណាម្នាក់ ឲ្យធ្វើជាអគ្គព្រះរាជអាជ្ញាស្តីទីជំនួសបាន ដើម្បីធានាដំណើរការរបស់មហាអយ្យការអមតុលាការកំពូល រហូតដល់មានការតែងតាំងអគ្គព្រះរាជអាជ្ញាជាផ្លូវការ ។

### មាត្រា ៧០.–

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល មានអំណាចគ្រប់គ្រងលើអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល ។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលចាត់តាំង និងបែងចែកដល់អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូលទៅក្នុងការងារផ្សេងៗនៃមហាអយ្យការ និងក្នុងអង្គជំនុំជម្រះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

សេចក្ដីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមតុលាការកំពូលត្រូវតែបញ្ជូនទៅអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ដើម្បីពិនិត្យនៅមុនពេលសវនាការ ។ ប្រសិនបើអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលមិនយល់ព្រមលើសេចក្ដីសន្និដ្ឋាននោះទេ ហើយតំណាងមហាអយ្យការដែលជាអ្នកធ្វើសេចក្ដីសន្និដ្ឋាននោះ នៅតែមិនព្រមធ្វើតាម អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលអាចចាត់តាំងអគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាផ្សេងទៀត ឬក៏ចាត់តាំងខ្លួនឯងតែម្ដងឲ្យធ្វើជាតំណាងមហាអយ្យការនៅក្នុងសវនាការ ។

ប៉ុន្តែ នៅពេលសវនាការ អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមតុលាការកំពូលអាចធ្វើការកត់សម្គាល់ដោយផ្ទាល់មាត់បានដោយសេរី តាមការដែលខ្លួនយល់ឃើញថាស្របតាមសតិសម្បជញ្ញៈរបស់ខ្លួន ។ គ្មានការចោទប្រកាន់ខាងវិន័យណាមួយដែលអាចត្រូវធ្វើចំពោះតំណាងមហាអយ្យការ ដោយសារតែការកត់សម្គាល់ផ្ទាល់មាត់របស់ខ្លួននាពេលសវនាការ ខុសពីសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរឡើយ ។

## ផ្នែកទី ៣
## អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល

### មាត្រា ៧១.-

អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល គឺជាសេនាធិការឲ្យតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូលលើ៖

- ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ
- ការងារគ្រប់គ្រងរដ្ឋបាលតុលាការសម្រាប់ជាជំនួយការបច្ចេកទេសដល់កម្មវិធីការងាររបស់តុលាការ
- ការងាររៀបចំគម្រោងថវិកាជូនប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលដើម្បីពិនិត្យ និងសម្រេច
- របាយការណ៍អំពីការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុជាប្រចាំជូនប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
- ការងារទំនាក់ទំនងសាធារណៈ
- ការងារបញ្ជូនសាលដីការបស់តុលាការកំពូលជូនទៅក្រសួងយុត្តិធម៌ឲ្យបានទៀងទាត់
- រៀបចំ និងបញ្ជូនរបាយការណ៍ ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនទៅក្រសួងយុត្តិធម៌

- ការងារផ្សេងទៀតដែលប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ប្រគល់ឱ្យ
- អនុវត្តការងារផ្សេងទៀតតាមការកំណត់នៃបទដ្ឋានគតិយុត្ត ។

អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលបែងចែកជានាយកដ្ឋាន ដែលដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនតាមការចាំបាច់ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## មាត្រា ៧២.-

អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល ដឹកនាំដោយអគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ។

អគ្គលេខាធិការ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិគ្រោះយោបល់ជាមួយប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ដើម្បីលើកសំណើជូននាយករដ្ឋមន្ត្រី ។ អគ្គលេខាធិការត្រូវជ្រើសរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុយ៉ាងតិចចំនួន ០៧ (ប្រាំពីរ) ឆ្នាំ ។

អគ្គលេខាធិការរង និងប្រធាននាយកដ្ឋានត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ។ អគ្គលេខាធិការរង និងប្រធាននាយកដ្ឋាន ត្រូវជ្រើសរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុ យ៉ាងតិចចំនួន ០៥ (ប្រាំ) ឆ្នាំ ។

មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋានថ្នាក់ក្រោមប្រធាននាយកដ្ឋាន ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ អនុប្រធាននាយកដ្ឋាន ព្រមទាំងប្រធាន និងអនុប្រធានការិយាល័យ ត្រូវជ្រើសរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុ យ៉ាងតិចចំនួន ០៣ (បី) ឆ្នាំ ។

មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋានទាំងអស់ដោយរួមទាំងអគ្គលេខាធិការផង ត្រូវមានក្របខណ្ឌរបស់ខ្លួននៅក្រសួងយុត្តិធម៌ ។

## មាត្រា ៧៣.-

សន្និបាតរបស់តុលាការកំពូល ត្រូវប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ដើម្បីបូកសរុបលទ្ធផលការងារកន្លងមក និង

កំណត់ទិសដៅការងាររដ្ឋបាលរបស់តុលាការកំពូលសម្រាប់ឆ្នាំបន្ទាប់ទៀត ។ របាយការណ៍សន្និបាតរបស់តុលាការកំពូល ត្រូវបញ្ជូនទៅក្រសួងយុត្តិធម៌ ។

## ជំពូកទី ៥
## ទិសមិតភាព

### មាត្រា ៧៤.-

មុខងារធ្វើបណ្តឹងអាជ្ញា មុខងារស៊ើបសួរ និងមុខងារជំនុំជម្រះ ត្រូវបែងចែកដាច់ពីគ្នា ។ ចៅក្រមណាម្នាក់ដែលបានទទួលបន្ទុកចាត់ការរឿងក្តីណាមួយក្នុងឋានៈជាតំណាងអយ្យការ ឬជាចៅក្រមស៊ើបសួររួចហើយមិនអាចជំនុំជម្រះ ឬចូលរួមជំនុំជម្រះរឿងក្តីដែលខ្លួនបានទទួលចាត់ការនោះឡើយ បើពុំដូច្នោះទេ សាលក្រម ឬសាលដីកានឹងត្រូវទុកជាមោឃៈ ។

### មាត្រា ៧៥.-

ចៅក្រមមិនអាចចូលរួមជំនុំជម្រះរឿងក្តីតែមួយជាមួយគ្នានឹងចៅក្រមម្នាក់ ឬច្រើននាក់ដែលជាសហព័ទ្ធ ឬញាតិលោហិត រហូតដល់ថ្នាក់ទី ៤ (បួន) រាប់ទាំងថ្នាក់ទី ៤ (បួន) នេះផង ឬញាតិពន្ធ រហូតដល់ថ្នាក់ទី ៣ (បី) រាប់ទាំងថ្នាក់ទី ៣ (បី) នេះផងទោះក្នុងឋានៈជាចៅក្រមជំនុំជម្រះក្តី ឬជាតំណាងអយ្យការក្តី ។ គោលការណ៍នេះត្រូវអនុវត្តដូចគ្នាផងដែរសម្រាប់ចៅក្រមនៅសាលាជម្រះក្តីជាន់ខ្ពស់ ចំពោះរឿងក្តីដែលត្រូវបានជំនុំជម្រះដោយចៅក្រមនៅសាលាជម្រះក្តីជាន់ទាបដែលជាសហព័ទ្ធ ឬញាតិលោហិតរហូតដល់ថ្នាក់ទី ៤ (បួន) រាប់ទាំងថ្នាក់ទី ៤ (បួន) នេះផង ឬញាតិពន្ធ រហូតដល់ថ្នាក់ទី ៣ (បី) រាប់ទាំងថ្នាក់ទី ៣ (បី) នេះផង ។

### មាត្រា ៧៦.-

ចៅក្រមទាំងឡាយដែលមានសហព័ទ្ធ ឬញាតិលោហិត រហូតដល់ថ្នាក់ទី៤ (បួន) រាប់ ទាំងថ្នាក់ទី ៤ (បួន) នេះផង ឬញាតិពន្ធ រហូតដល់ថ្នាក់ទី ៣ (បី) រាប់ទាំងថ្នាក់ទី ៣ (បី) នេះផង ធ្វើជាមេធាវីឲ្យភាគីម្ខាងនៃរឿងក្តីណាមួយ មិនអាចចូលរួមជំនុំជម្រះរឿងក្តីនោះបានឡើយ ។

### មាត្រា ៧៧.-

ចៅក្រមមិនអាចចូលរួមជំនុំជម្រះរឿងក្តីណាមួយ ដែលមានភាគីម្ខាងជាសហព័ទ្ធ ឬញាតិលោហិតរហូតដល់ថ្នាក់ទី ៦ (ប្រាំមួយ) រាប់ទាំងថ្នាក់ទី ៦ (ប្រាំមួយ) នេះផង ឬញាតិពន្ធ រហូតដល់ថ្នាក់ទី ៣ (បី) រាប់ទាំងថ្នាក់ទី ៣ (បី) នេះផង ។

ROYAUME DU CAMBODGE • CABINET DU ROI • LE MINISTRE DU PALAIS ROYAL

### មាត្រា ៧៨.-

លើកលែងតែមានបទប្បញ្ញត្តិស្តីពីនីតិវិធីចែងផ្សេងពីនេះ ភាគីទាំងឡាយនៅក្នុងរឿងក្តី និងបុគ្គលដែលមានប្រយោជន៍ក្នុងរឿងក្តី ដោយរួមទាំងតំណាងអយ្យការផង អាចប្តឹងសុំមោឃកម្មចំពោះសាលក្រម ឬសាលដីការបស់តុលាការ ដោយហេតុបំពានវិធានស្តីពីវិសមិតភាពដូចមានចែងក្នុងមាត្រា ៧៤ មាត្រា ៧៥ មាត្រា ៧៦ និងមាត្រា ៧៧ ខាងលើ ។

បណ្តឹងសុំមោឃកម្មនេះ អាចធ្វើបានគ្រប់ពេលវេលា នៅចំពោះមុខតុលាការ នៅក្នុងនីតិវិធីឧបាស្រ័យដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីជាធរមាន ។ បើទោះបីជាសាលក្រមឬសាលដីកានោះបានចូលស្ថាពរហើយក៏ដោយ ក៏បណ្តឹងសុំមោឃកម្ម នៅតែអាចធ្វើឡើងបានដដែលក្នុងអំឡុងពេល ៦០ (ហុកសិប) ថ្ងៃ គិតពីថ្ងៃបានដឹងអំពីមូលហេតុដូចមានចែងក្នុងមាត្រា ៧៤ មាត្រា ៧៥ មាត្រា ៧៦ និងមាត្រា ៧៧ ខាងលើក្រោយពេលសាលក្រម ឬសាលដីកាបានចូលជាស្ថាពរ ។ ក្នុងករណីចុងក្រោយនេះ បណ្តឹងសុំមោឃកម្ម ត្រូវដាក់នៅសាលាជម្រះក្តីដែលបានចេញសាលក្រម ឬសាលដីកាស្ថាពរ ប៉ុន្តែ ត្រូវមានសមាសភាពចៅក្រមជំនុំជម្រះផ្សេងដើម្បីពិនិត្យ និងសម្រេចអំពីមោឃកម្មនៃសាលក្រម ឬសាលដីកាស្ថាពរនោះ និងអនុវត្តនីតិវិធីបន្តស្របតាមបទប្បញ្ញត្តិជាធរមាន ។

## ជំពូកទី ៦
## ថវិកាសាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តី

### មាត្រា ៧៩.-

សាលាដំបូង និងអយ្យការអមសាលាដំបូង សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ព្រមទាំងតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល មានកញ្ចប់ថវិកាដោយឡែក សម្រាប់ដំណើរការ ដែលស្ថិតនៅក្នុងកញ្ចប់ថវិការបស់ក្រសួងយុត្តិធម៌ ។

ប្រធានសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ជាអាណាប័កផ្ទេរសិទ្ធិពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ការគ្រប់គ្រង និងការចាត់ចែងថវិការបស់សាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តីដូចបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

### មាត្រា ៨០.-

សាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ ព្រមទាំងអង្គការអយ្យការនៅអមសាលាជម្រះក្តីទាំងនេះ ដែលត្រូវបានបង្កើតឡើង នៅមុនពេលច្បាប់នេះចូលជាធរមាន ត្រូវបន្តដំណើរការរបស់ខ្លួន ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៨១.–**

បទប្បញ្ញត្តិពីមុនពាក់ព័ន្ធនឹងតុលាការយោធា និងអយ្យការអមតុលាការយោធា ព្រមទាំងបទប្បញ្ញត្តិស្តីពីសមត្ថកិច្ច និងនីតិវិធី ដែលអនុវត្តសម្រាប់ដំណើរការរឿងក្តីបទល្មើសយោធា ត្រូវបន្តមានអានុភាពអនុវត្តក្រោយច្បាប់នេះចូលជាធរមាន រហូតដល់មានបទប្បញ្ញត្តិថ្មីមកជំនួស ។

**មាត្រា ៨២.–**

នៅពេលរង់ចាំការដាក់ឲ្យដំណើរការសាលាឧទ្ធរណ៍ផ្សេងទៀត សាលាឧទ្ធរណ៍បច្ចុប្បន្នដែលមានទីតាំងនៅរាជធានីភ្នំពេញ មានសមត្ថកិច្ចដែនដីលាតសន្ធឹងលើដែនដីទាំងមូលនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៨៣.–**

ការដាក់ឲ្យដំណើរការតុលាការជំនាញនានារបស់សាលាដំបូងដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់នេះ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៨៤.–**

ក្នុងករណីដែលសាលាដំបូងនៃខេត្តណាមួយមិនទាន់ត្រូវបានដាក់ឲ្យដំណើរការ ឬមិនអាចដាក់ឲ្យដំណើរការបាន សមត្ថកិច្ចជំនុំជម្រះរឿងក្តីទាំងឡាយនៅក្នុងខេត្តនោះ ត្រូវប្រគល់ទៅឲ្យសាលាដំបូងណាមួយដោយព្រះរាជក្រឹត្យ ។

**មាត្រា ៨៥.–**

កាលបើសភាពាណិជ្ជកម្ម និងសភាការងារនៃសាលាជម្រះក្តីជាន់ខ្ពស់ មិនអាចដំណើរការបានដោយមូលហេតុខ្វះចៅក្រម ការជំនុំជម្រះរឿងក្តីពាណិជ្ជកម្ម និងរឿងក្តីការងារ គឺជាសមត្ថកិច្ចនៃសភារដ្ឋប្បវេណីនៃសាលាជម្រះក្តីជាន់ខ្ពស់ ។ កិច្ចការទាំងនេះ ត្រូវចាត់ចែងដោយប្រធានសាលាជម្រះក្តីជាន់ខ្ពស់ ដែលសភាជំនាញនោះស្ថិតនៅ ។

កាលបើសភាជំនាញណាមួយខាងលើមានដំណើរការស្របតាមច្បាប់នេះ សភាជំនាញផ្សេងទៀតត្រូវផ្ទេររឿងក្តីដែលមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន ហើយមិនទាន់ចាត់ការ ទៅសភាជំនាញដែលមានសមត្ថកិច្ចវិញ ។

**មាត្រា ៨៦.–**

ក្នុងករណីដែលមិនទាន់មានចៅក្រមគ្រប់គ្រាន់ ចៅក្រមស៊ើបសួរអាចបំពេញមុខងារជាចៅក្រមជម្រះក្តីបាន ប៉ុន្តែ មិនអាចជំនុំជម្រះរឿងក្តីដែលខ្លួនស៊ើបសួរបានឡើយ ។

ROYAUME DU CAMBODGE · MINISTRE DU PALAIS ROYAL

**មាត្រា ៨៧.–**

ក្នុងករណីមិនទាន់មានសាលាជម្រះក្តីរដ្ឋបាល សមត្ថកិច្ចជំនុំជម្រះរឿងក្តីរដ្ឋបាលត្រូវប្រគល់ឱ្យតុលាការរដ្ឋប្បវេណីនៃសាលាជម្រះក្តីជាន់ទាប និងសភារដ្ឋប្បវេណីនៃសាលាជម្រះក្តីជាន់ខ្ពស់ ។

**មាត្រា ៨៨.–**

នៅពេលដែលមិនទាន់មានទីប្រឹក្សាពាណិជ្ជកម្ម ឬទីប្រឹក្សាការងារ សមាសភាពជំនុំជម្រះរឿងក្តីពាណិជ្ជកម្ម និងរឿងក្តីការងារ ត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី ។

**មាត្រា ៨៩.–**

នៅពេលដែលមិនទាន់មានបទប្បញ្ញត្តិស្តីពីនីតិវិធីពាណិជ្ជកម្ម ការជំនុំជម្រះរឿងក្តីពាណិជ្ជកម្មត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី និងបទប្បញ្ញត្តិច្បាប់ផ្សេងៗ ទៀតជាធរមាន ។

នៅពេលដែលមិនទាន់មានបទប្បញ្ញត្តិស្តីពីនីតិវិធីការងារការជំនុំជម្រះរឿងក្តីការងារ ត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី និងបទប្បញ្ញត្តិច្បាប់ផ្សេងៗ ទៀតជាធរមាន ។

នៅពេលដែលមិនទាន់មានបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋបាល ការជំនុំជម្រះរឿងក្តីរដ្ឋបាលត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី និងបទប្បញ្ញត្តិច្បាប់ផ្សេងៗ ទៀតជាធរមាន ។

**មាត្រា ៩០.–**

ក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំដំបូងបន្ទាប់ពីច្បាប់នេះចូលជាធរមាន ការតែងតាំងថ្នាក់ដឹកនាំនៃអង្គភាពរដ្ឋបាលរបស់សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ អាចអនុវត្តបានយោងទៅតាមលក្ខខណ្ឌគុណវុឌ្ឍិជាក់ស្តែង ។

នាយកក្រឡាបញ្ជីនៃសាលាដំបូង អាចត្រូវបានតែងតាំងជាប្រធាន ឬអនុប្រធាននៃលេខាធិការដ្ឋានរដ្ឋបាលនៃសាលាដំបូងដែលខ្លួនកំពុងបំពេញការងារនោះបាន ។

នាយកក្រឡាបញ្ជីនៃសាលាជម្រះក្តីជាន់ខ្ពស់ អាចត្រូវបានតែងតាំងជាអគ្គលេខាធិការ ឬអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានរដ្ឋបាលនៃសាលាជម្រះក្តីជាន់ខ្ពស់ ដែលខ្លួនកំពុងបំពេញការងារនោះបាន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៩១.-**

បទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាលចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ និងច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជាដែលប្រកាសឲ្យប្រើដោយក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ព្រមទាំងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ហើយត្រូវជំនួសដោយច្បាប់នេះ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស/រកម.០៧១៤.០១៦ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ហត្ថលេខា**

**អង្គ វង្សវឌ្ឍានា**

លេខៈ៩០៣ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រម

នស/រកម/០៧១៤/០១៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី៥ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របតាមនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ១៤៧/០០១/២០១៤ កបធ.ច ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# លក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

## ជំពូកទី ១
## បទប្បញ្ញត្តិរួម

**មាត្រា ១.-**

ច្បាប់នេះ កំណត់ពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ព្រមទាំងគោលការណ៍ផ្សេងៗ ទៀតទាក់ទងនឹងចៅក្រម និងព្រះរាជអាជ្ញា ក្នុងគោលបំណងធានាឯករាជ្យនៃអំណាចតុលាការស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះចៅក្រម និងព្រះរាជអាជ្ញាទូទាំងព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានច្បាប់ដោយឡែកកំណត់ផ្សេងពីនេះ ។

**មាត្រា ៣.-**

វាក្យសព្ទបច្ចេកទេសក្នុងច្បាប់នេះ មានន័យដូចតទៅ ៖

- ចៅក្រម សំដៅដល់ចៅក្រមអាសនៈ រួមមាន ជាអាទិ៍ ចៅក្រមជម្រះក្តី និងចៅក្រមស៊ើបសួរ
- ព្រះរាជអាជ្ញា សំដៅដល់ព្រះរាជអាជ្ញារង ព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងអគ្គព្រះរាជអាជ្ញា
- អង្គចៅក្រម សំដៅដល់ចៅក្រម និងព្រះរាជអាជ្ញា ។

**មាត្រា ៤.-**

បុគ្គលដែលត្រូវជ្រើសរើសសម្រាប់ឲ្យបំពេញមុខងារជាចៅក្រម និងព្រះរាជអាជ្ញា ត្រូវតែជាអ្នកមានសមត្ថភាព និងជាអ្នកសុចរិតមានសីលធម៌ស្អាតស្អំ ។

**មាត្រា ៥.-**

នៅក្នុងអាជីពរបស់ខ្លួន ចៅក្រមអាចត្រូវបានតែងតាំងជាព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញាក៏អាចត្រូវបានតែងតាំងជាចៅក្រមវិញបានដែរ ។

**មាត្រា ៦.-**

ចៅក្រម និងព្រះរាជអាជ្ញា ត្រូវទទួលបានការធានាការពារសន្តិសុខ សុវត្ថិភាពផ្ទាល់ខ្លួន និងគ្រួសារក្នុងករណីចាំបាច់តាមសំណូមពររបស់សាមីខ្លួន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ចៅក្រម និងព្រះរាជអាជ្ញា មិនត្រូវទទួលខុសត្រូវខាងបទព្រហ្មទណ្ឌ ឬបទរដ្ឋប្បវេណីណាមួយ ចំពោះការសម្រេច ដែលបានធ្វើក្នុងក្របខណ្ឌសមត្ថកិច្ច និងមុខងាររបស់ខ្លួនក្នុងឋានៈជាចៅក្រម ឬព្រះរាជអាជ្ញាឡើយ ។ គោលការណ៍នេះ មិនត្រូវយកមកអនុវត្តឡើយ ក្នុងករណីដែលចៅក្រម ឬព្រះរាជអាជ្ញាប្រើប្រាស់ការសម្រេចរបស់ខ្លួនដោយរំលោភបំពានធ្ងន់ធ្ងរក្នុងចេតនាទុច្ចរិត លើសមត្ថកិច្ច និងមុខងារដែលច្បាប់ប្រគល់ឲ្យ ។

**មាត្រា ៧.-**

ចៅក្រម និងព្រះរាជអាជ្ញាទាំងអស់ ស្ថិតនៅក្នុងក្របខណ្ឌរដ្ឋបាលកណ្តាលរបស់ក្រសួងយុត្តិធម៌ និងអាចចាត់ឲ្យបំពេញការងារនៅក្រសួងយុត្តិធម៌បាន ។ ក្នុងករណីត្រូវទៅបំពេញការងារនៅក្រសួងយុត្តិធម៌ ចៅក្រមត្រូវស្នើសុំការយល់ព្រមពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

ក្នុងរយៈពេលបំពេញការងារនៅក្រសួងយុត្តិធម៌ ចៅក្រម និងព្រះរាជអាជ្ញា ត្រូវស្ថិតនៅក្រោមលក្ខន្តិកៈព្រះរាជអាជ្ញា និងទទួលបាននូវប្រាក់បៀវត្ស និងប្រាក់បំណាច់មុខងារ ដូចព្រះរាជអាជ្ញាដែលបម្រើការងារនៅក្នុងអង្គការអយ្យការអមសាលាជម្រះក្តីដែរ ។ ក្នុងករណីដែលប្រាក់បៀវត្ស និងប្រាក់បំណាច់មុខងារមានភាពខុសគ្នា សាមីខ្លួនមានសិទ្ធិជ្រើសរើសយកប្រាក់បៀវត្ស ឬប្រាក់បំណាច់មុខងារណាមួយដែលខ្ពស់ជាង។

## ជំពូកទី ២
## ចៅក្រម
## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ៨.-**

ចៅក្រមទាំងឡាយត្រូវសម្រេចសេចក្តីដោយមិនលំអៀង ដោយឈរលើគោលការណ៍គោរពច្បាប់ដោយមិនទទួលការគាបសង្កត់ ការគំរាមកំហែង ឬការបំភិតបំភ័យ ការបង្គាប់បញ្ជាដោយផ្ទាល់ ឬដោយប្រយោលពីភាគីណាមួយក្នុងរឿងក្តី ឬពីបុគ្គលណាមួយឡើយ ។

**មាត្រា ៩.-**

ចៅក្រមត្រូវចាត់តាំងឲ្យបំពេញការងារនៅសាលាជម្រះក្តីណាមួយសម្រាប់រយៈពេល៤ (បួន) ឆ្នាំ ។ ចៅក្រមមិនត្រូវបានផ្លាស់ប្តូរទៅកន្លែងណាមួយផ្សេងទៀត ដោយមិនមានការយល់ព្រមពីសាមីខ្លួនជា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

មុនឡើយ ក្នុងអំឡុងពេលបំពេញការងារដែលមានចែងក្នុងកថាខណ្ឌទី ១ ខាងលើទោះជាកន្លែងនោះមានឋានន្តរស័ក្តិខ្ពស់ជាងក៏ដោយ ។ ប៉ុន្តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាចផ្លាស់ប្តូរចៅក្រមឲ្យទៅបំពេញការងារកន្លែងណាមួយផ្សេងទៀតបាន ក្នុងករណីចៅក្រមនោះមានទោសវិន័យថ្នាក់ទី២ (ពីរ) ដូចមានចែងក្នុងមាត្រា ៥៥ នៃច្បាប់នេះ ឬតាមតម្រូវការចាំបាច់ដើម្បីដំណើរការល្អនៃយុត្តិធម៌ ។

## ផ្នែកទី ២
## ឋានន្តរស័ក្តិ និងថ្នាក់

### មាត្រា ១០.-

ក្របខណ្ឌចៅក្រមរួមមាន ៣ (បី) ឋានន្តរស័ក្តិ៖

- ឧត្តមចៅក្រម
- វរៈចៅក្រម
- អនុចៅក្រម ។

### មាត្រា ១១.-

ថ្នាក់សម្រាប់ឋានន្តរស័ក្តិឧត្តមចៅក្រម ឋានន្តរស័ក្តិវរៈចៅក្រម និងឋានន្តរស័ក្តិអនុចៅក្រម ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

## ផ្នែកទី ៣
## ឯកសណ្ឋាន

### មាត្រា ១២.-

ឯកសណ្ឋានរបស់ចៅក្រម រួមមាន៖

- ឯកសណ្ឋានក្នុងពេលជំនុំជម្រះ និងឯកសណ្ឋានក្នុងពេលបំពេញមុខងារផ្សេងទៀតក្រៅពីការជំនុំជម្រះ
- ឯកសណ្ឋានផ្លូវការក្នុងពិធីបុណ្យជាតិផ្សេងៗ ។

ឯកសណ្ឋានទាំងនេះ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ តាមសំណើរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

### មាត្រា ១៣.-

ឯកសណ្ឋានដែលចៅក្រមទាំងអស់ត្រូវពាក់ក្នុងពេលជំនុំជម្រះ គឺជាអាវផាយ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ឯកសណ្ឋានក្នុងពេលបំពេញមុខងារផ្សេងទៀតក្រៅពីការជំនុំជម្រះ គឺជាសម្លៀកបំពាក់ ឬគ្រឿងសម្គាល់ផ្សេងៗ ។ ការប្រើប្រាស់សម្លៀកបំពាក់ ឬគ្រឿងសម្គាល់នេះ ត្រូវកំណត់ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ឯកសណ្ឋានដែលចៅក្រមទាំងអស់ត្រូវពាក់ក្នុងពេលហែក្បួន ឬក្នុងពិធីបុណ្យជាតិផ្សេងៗបើមានតម្រូវជាផ្លូវការ គឺជាសម្លៀកបំពាក់ផ្លូវការ ។

## ផ្នែកទី ៤
## ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ ប្រាក់រង្វាន់ និងការឈប់សម្រាក

### មាត្រា ១៤.-

ចៅក្រមត្រូវទទួលប្រាក់បៀវត្ស ដែលមានកម្រិតតាមឋានន្តរស័ក្តិ និងថ្នាក់របស់ខ្លួនប្រាក់បំណាច់មុខងារ និងប្រាក់បំណាច់ផ្សេងៗទៀត ព្រមទាំងប្រាក់រង្វាន់ដទៃទៀត ស្របតាមបទប្បញ្ញត្តិជាធរមាន ។

### មាត្រា ១៥.-

ប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារ និងប្រាក់បំណាច់ផ្សេងៗទៀត ដូចជាប្រាក់បំណាច់ក្នុងកិច្ចការបំពេញបេសកកម្ម ប្រាក់បំណាច់ឈ្នួលផ្ទះ ប្រាក់បំណាច់អធិមូលជីវភាព ប្រាក់បំណាច់សម្រាប់ផ្លាស់ប្តូរទីតាំងការងារ ប្រាក់ថ្លៃព្យាបាលនៅក្នុងមន្ទីរពេទ្យ និងប្រាក់ឧបត្ថម្ភសម្រាប់ព្យាបាលជំងឺប្រចាំកាយរយៈពេលយូររបស់ចៅក្រម ត្រូវកំណត់ដោយអនុក្រឹត្យ ។

### មាត្រា ១៦.-

ចៅក្រមត្រូវមានរបបឈប់សម្រាកប្រចាំឆ្នាំចំនួន ៣០ (សាមសិប) ថ្ងៃ បន្ថែមពីលើថ្ងៃឈប់សម្រាកដែលកំណត់ដោយរាជរដ្ឋាភិបាល ។ រយៈពេលធ្វើការដែលនាំឲ្យមានសិទ្ធិឈប់សម្រាកប្រចាំឆ្នាំនេះត្រូវគិតចាប់ពីថ្ងៃទី ១ ខែ មករា ។

ចៅក្រមអាចសុំឈប់សម្រាកជាច្រើនដងក៏បាន ឬឈប់សម្រាកតែម្តងក្នុងមួយឆ្នាំក៏បាន ។ ការឈប់សម្រាកនេះ អាចបន្តរហូតផុតខែ កុម្ភៈ នៃឆ្នាំបន្ទាប់បាន ។

ការសុំឈប់សម្រាកប្រចាំឆ្នាំ ត្រូវស្នើសុំទៅប្រធានសាលាជម្រះក្តីឲ្យបានយ៉ាងតិច ៣(បី) ខែ មុនពេលឈប់សម្រាក ។

ចៅក្រមជាស្ត្រីមានសិទ្ធិឈប់សម្រាកលំហែមាតុភាពចំនួន ៩០ (កៅសិប) ថ្ងៃ ។

ROYAUME DU CAMBODGE · LE CABINET DU PALAIS ROYAL

រយៈពេលនៃការឈប់សម្រាកខាងលើនេះ ចៅក្រមត្រូវទទួលបានប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារ និងប្រាក់បំណាច់ផ្សេងៗទៀត ។

## មាត្រា ១៧.-

ចៅក្រមដែលបានបំពេញការងារបានគ្រប់ ២ (ពីរ) ឆ្នាំ មិនដែលមានអាក់ខាន ឬមានអាក់ខានដែរ ប៉ុន្តែបានបំពេញការងារគ្រប់ចំនួន ២ (ពីរ) ឆ្នាំ អាចទទួលការអនុញ្ញាតឲ្យឈប់ដើម្បីទៅព្យាបាលជំងឺបាន រយៈពេល ៦ (ប្រាំមួយ) ខែ ដោយមិនកាត់ប្រាក់បៀវត្ស ។

បើឈប់ដើម្បីទៅព្យាបាលជំងឺបន្តលើសពី៦ (ប្រាំមួយ) ខែ ទៅ ១ (មួយ) ឆ្នាំ ប្រាក់បៀវត្សត្រូវបន្ថយមកនៅត្រឹមពាក់កណ្តាល ។ បើត្រូវឈប់ដើម្បីទៅព្យាបាលជំងឺបន្តថែមទៀតលើសពី ១(មួយ) ឆ្នាំ ចៅក្រមនោះត្រូវស្នើសុំនៅទំនេរគ្មានបៀវត្ស តាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់នេះ ។ ក្នុងករណីមិនបានស្នើសុំនៅទំនេរគ្មានបៀវត្ស ចៅក្រមនោះត្រូវដាក់ឲ្យចូលនិវត្តន៍ ដោយមូលហេតុបាត់បង់សម្បទាវិជ្ជាជីវៈស្របតាមបញ្ញត្តិមាត្រា ៦៦ នៃច្បាប់នេះ ។

ចៅក្រមដែលមានជំងឺ អាចសុំច្បាប់ឈប់សម្រាកព្យាបាលជំងឺមកក្រសួងយុត្តិធម៌ ហើយត្រូវផ្តល់វិញ្ញាបនបត្រពេទ្យជាសេចក្តីបញ្ជាក់ ។ ក្រសួងយុត្តិធម៌អាចឲ្យគ្រូពេទ្យជំនាញមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យបានគ្រប់ពេលវេលា ប្រសិនបើយល់ឃើញថាជាការចាំបាច់ ។

## មាត្រា ១៨.-

ចំពោះចៅក្រមមិនបានឈប់សម្រាកប្រចាំឆ្នាំ រយៈពេលមិនបានឈប់នោះ អាចយកទៅគិតបន្ថែមលើរយៈពេលព្យាបាលជំងឺខាងលើ ដោយមិនកាត់ប្រាក់បៀវត្ស ។

# ផ្នែកទី ៥
# ការជ្រើសរើសចៅក្រម

## មាត្រា ១៩.-

ត្រូវបានអនុញ្ញាតឲ្យប្រឡងជ្រើសរើសជាសិស្សចៅក្រម ចំពោះបេក្ខជនដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១- ត្រូវមានសញ្ជាតិខ្មែរពីកំណើត

២- មានអាយុ ៣៥ (សាមសិបប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបេក្ខជនជានិស្សិត និងមានអាយុ ៤០ (សែសិប) ឆ្នាំ យ៉ាងច្រើន ចំពោះបេក្ខជនជាមន្ត្រីរាជការ គិតមកដល់ថ្ងៃប្រឡង

៣- ត្រូវមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រច្បាប់ឡើងទៅ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

៤- មិនដែលមានទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ

៥- ត្រូវមានកាយសម្បទាគ្រប់គ្រាន់អាចបំពេញការងារបាន ។

**មាត្រា ២០.-**

ការកំណត់ចំនួននៃការជ្រើសរើសសិស្សចៅក្រម ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

**មាត្រា ២១.-**

បេក្ខជនដែលប្រឡងជាប់ចូលជាសិស្សចៅក្រម ត្រូវទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈដែលរៀបចំដោយក្រសួងយុត្តិធម៌ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃការបណ្តុះបណ្តាលវិជ្ជាជីវៈនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ២២.-**

បែបបទ នីតិវិធី កាលបរិច្ឆេទ និងទីកន្លែង ព្រមទាំងគណៈមេប្រយោគនៃការប្រឡងប្រជែងជ្រើសរើសសិស្សចៅក្រម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ២៣.-**

ការជ្រើសរើសបញ្ចូលក្នុងក្របខណ្ឌចៅក្រម អាចធ្វើឡើងតាមរយៈការប្រឡងប្រជែងផ្ទៃក្នុងពីក្នុងចំណោមមន្ត្រីរាជការ និងក្រឡាបញ្ជី ដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រច្បាប់ឡើងទៅ និងមានបទពិសោធន៍ក្នុងវិស័យច្បាប់ ឬយុត្តិធម៌យ៉ាងតិច ៥ (ប្រាំ) ឆ្នាំ ហើយដែលមានអាយុមិនលើសពី ៤៥ (សែសិបប្រាំ) ឆ្នាំគិតមកដល់ថ្ងៃប្រឡង ។ មេធាវី ដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រច្បាប់ឡើងទៅ និងបានបំពេញវិជ្ជាជីវៈរបស់ខ្លួនយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ អាចចុះឈ្មោះចូលរួមប្រឡងប្រជែងតាមបញ្ញត្តិនៃវាក្យខណ្ឌទី ១ ខាងលើនេះបាន ប្រសិនបើមេធាវីនោះ មានអាយុមិនលើសពី ៤៥ (សែសិបប្រាំ) ឆ្នាំ គិតមកដល់ថ្ងៃប្រឡង ។

បុគ្គលដែលបានប្រឡងជាប់ក្នុងក្របខណ្ឌចៅក្រមតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលរៀបចំដោយក្រសួងយុត្តិធម៌ ។

បែបបទ និងនីតិវិធីនៃការប្រឡងប្រជែងផ្ទៃក្នុងខាងលើ និងចំនួននៃការជ្រើសរើសបញ្ចូលក្នុងក្របខណ្ឌចៅក្រមតាមមាត្រានេះ ព្រមទាំងការរៀបចំ និងការប្រព្រឹត្តទៅនៃការបណ្តុះបណ្តាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

# ផ្នែកទី ៦
# ការធ្វើកម្មសិក្សា និងការតាំងស៊ប់ក្នុងក្របខណ្ឌចៅក្រម

## មាត្រា ២៤.-

សិស្សចៅក្រមដែលត្រូវបានជ្រើសរើសតាមបញ្ញត្តិនៃមាត្រា ១៩ និងមាត្រា ២៣ នៃច្បាប់នេះ និងដែលបានបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈដោយជោគជ័យ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យជាចៅក្រមកម្មសិក្សាក្នុងឋានន្តរស័ក្តិជាអនុចៅក្រមថ្នាក់ដំបូងគេ ។ ចៅក្រមកម្មសិក្សា ត្រូវធ្វើកម្មសិក្សារយៈពេល ១ (មួយ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការតែងតាំង ។

បែបបទនៃការធ្វើកម្មសិក្សា និងសិទ្ធិអំណាចរបស់ចៅក្រមកម្មសិក្សា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ការតែងតាំងជាចៅក្រមកម្មសិក្សា មានអានុភាពដល់ការរៀបចំប្រាក់បៀវត្ស និងការគិតអំពីអតីតភាពការងារ ។

## មាត្រា ២៥.-

ចៅក្រមកម្មសិក្សាដែលបានបំពេញកម្មសិក្សាចប់ដោយជោគជ័យ ត្រូវតាំងស៊ប់ក្នុងក្របខណ្ឌចៅក្រម និងមានឋានន្តរស័ក្តិជាអនុចៅក្រមថ្នាក់ដំបូងគេ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចសម្រេចឲ្យចៅក្រមកម្មសិក្សា បន្តធ្វើកម្មសិក្សា ១ (មួយ) ឆ្នាំបន្ថែមទៀត កាលបើចៅក្រមកម្មសិក្សានោះ ពុំទទួលបានជោគជ័យក្នុងការធ្វើកម្មសិក្សា ឬមានការអាក់ខានមិនបានធ្វើកម្មសិក្សាសរុបទាំងអស់លើសពី ៣០(សាមសិប) ថ្ងៃ ។

ក្នុងករណីដែលចៅក្រមកម្មសិក្សាឈប់រហូតលើសពី ៣០ (សាមសិប) ថ្ងៃដោយគ្មានការអនុញ្ញាតច្បាប់ ឬចៅក្រមកម្មសិក្សា ដែលមិនបានទទួលជោគជ័យជាថ្មីម្តងទៀតក្នុងការធ្វើកម្មសិក្សាបន្ថែម ត្រូវលុបឈ្មោះចេញពីក្របខណ្ឌចៅក្រម ក្រោយពីមានការសម្រេចពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

## មាត្រា ២៦.-

ចៅក្រមកម្មសិក្សាដែលមិនមានសម្បទាគ្រប់គ្រាន់ ឬមានសុខភាពមិនគ្រប់គ្រាន់ ដើម្បីបំពេញមុខងាររបស់ខ្លួនតាមលក្ខខណ្ឌដែលច្បាប់បានកំណត់ ឬមានការខុសឆ្គងក្នុងការបម្រើការងារមិនបានពេញលេញ អាចត្រូវលុបឈ្មោះចេញពីក្របខណ្ឌចៅក្រមបានគ្រប់ពេលវេលា ក្រោយពីមានការសម្រេចពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ការលុបឈ្មោះចេញ ឬការតាំងស៊ប់ក្នុងក្របខណ្ឌចៅក្រម ត្រូវសម្រេចក្នុងរយៈពេល ៣ (បី) ខែ យ៉ាងយូរក្រោយពីការបញ្ចប់កម្មសិក្សា ។

## ផ្នែកទី ៧
## ការដំឡើងថ្នាក់និងឋានន្តរស័ក្តិ

### មាត្រា ២៧.-

ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ត្រូវធ្វើឡើងតាមវេនជ្រើសរើស និងតាមវេនអតីតភាព ស្របតាមតារាងនៃថ្នាក់ និងឋានន្តរស័ក្តិនីមួយៗ ។

លក្ខខណ្ឌនៃការដំឡើងថ្នាក់ ឬឋានន្តរស័ក្តិតាមវេនជ្រើសរើស និងតាមវេនអតីតភាពត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

### មាត្រា ២៨.-

ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិរបស់ចៅក្រមត្រូវផ្អែកលើមូលដ្ឋាន ជាអាទិ៍៖

- ការគោរពវិន័យការងារបានត្រឹមត្រូវ
- ការសម្រេចភារកិច្ចបានល្អ
- កិរិយាមាយាទ និងសីលធម៌ល្អ មិនធ្វើឲ្យប៉ះពាល់ដល់កិត្តិយសនៃអង្គចៅក្រម
- ការឆ្លងកាត់វគ្គបណ្តុះបណ្តាលនានា ឬបានបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

ក្នុងរយៈពេលនៃការបំពេញការងារ ចៅក្រមដែលបានខិតខំសិក្សាបន្ថែម ហើយបានទទួលសញ្ញាបត្រក្រោយឧត្តមសិក្សា ត្រូវបានលើកទឹកចិត្តដោយធ្វើការដំឡើងថ្នាក់បន្ថែម ១ (មួយ) ថ្នាក់ទៀត ។

### មាត្រា ២៩.-

សម្រាប់ថ្នាក់ និងឋានន្តរស័ក្តិនីមួយៗនៃឋានានុក្រម ចំនួនចៅក្រម ដែលគ្រោងឲ្យឡើងថ្នាក់ ឬឋានន្តរស័ក្តិសម្រាប់ឆ្នាំនីមួយៗ នឹងត្រូវកំណត់ទៅតាមតម្រូវការនៃការងារ និងទៅតាមគម្រោងថវិកាជាតិ ។

### មាត្រា ៣០.-

ចៅក្រមក្នុងឋានន្តរស័ក្តិតែមួយ អាចឡើងថ្នាក់បានម្តងមួយថ្នាក់ ។

ក្នុងករណីចាំបាច់ ចៅក្រមអាចប្តូរឋានន្តរស័ក្តិបានតាមរយៈការប្រឡង ។

### មាត្រា ៣១.-

ជារៀងរាល់ឆ្នាំ នៅសប្តាហ៍ទី ១ នៃខែ មករា ចៅក្រមម្នាក់ៗ ត្រូវបានទទួលនូវព្រឹត្តិបត្រឯកត្តជនដែលចៅក្រមនោះត្រូវបំពេញតាមចំណុចសំណួរទាំងឡាយ ។

ព្រឹត្តិបត្រឯកត្តជន ត្រូវដាក់ពិន្ទុដោយមានបញ្ជាក់យោបល់ និងមូលហេតុច្បាស់លាស់ ។

ចំពោះការដាក់ពិន្ទុត្រូវអនុវត្តដូចខាងក្រោម៖

១-ចៅក្រមនៃសាលាដំបូង និងអនុប្រធានសាលាដំបូង ត្រូវដាក់ពិន្ទុដោយប្រធានសាលាដំបូង ។

២-ចៅក្រមនៃសាលាឧទ្ធរណ៍ និងអនុប្រធានសាលាឧទ្ធរណ៍ ត្រូវដាក់ពិន្ទុដោយប្រធានសាលាឧទ្ធរណ៍ ។

៣-ប្រធានសាលាដំបូង ប្រធានសាលាឧទ្ធរណ៍ ចៅក្រមនៃតុលាការកំពូល និងអនុប្រធានតុលាការកំពូល ត្រូវដាក់ពិន្ទុដោយប្រធានតុលាការកំពូល ។

៤-ចៅក្រមដែលបានផ្លាស់ឲ្យទៅបំពេញភារកិច្ចនៅស្ថាប័នផ្សេងៗ ត្រូវដាក់ពិន្ទុដោយប្រធានស្ថាប័ននោះ ។

## មាត្រា ៣២.–

អាចឲ្យចុះឈ្មោះក្នុងតារាងដំឡើងថ្នាក់បាន ចំពោះតែចៅក្រមណាដែលបានបម្រើការងារក្រោយពីបានតាំងស៊ប់ក្នុងក្របខណ្ឌ ហើយស្ថិតក្នុងឋានន្តរស័ក្តិ ឬថ្នាក់របស់ខ្លួនយ៉ាងតិច ២ (ពីរ) ឆ្នាំ គិតមកទល់ថ្ងៃទី ១៣ ខែ មេសា នៃឆ្នាំនីមួយៗ ។

## មាត្រា ៣៣.–

សមាសភាពនៃគណៈកម្មការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ រួមមាន៖

| | |
|---|---|
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ០១ (មួយ) រូប | ប្រធាន |
| - អនុប្រធានតុលាការកំពូល ០១ (មួយ) រូប | អនុប្រធាន |
| - អគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល ០១ (មួយ) រូប | អនុប្រធាន |
| - ប្រធានសាលាឧទ្ធរណ៍ភ្នំពេញ | សមាជិក |
| - អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ | សមាជិក |
| - ប្រធានសាលាដំបូងរាជធានីភ្នំពេញ | សមាជិក |
| - ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ | សមាជិក |
| - អគ្គលេខាធិការនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម | លេខាធិការ។ |

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចតែងតាំងសមាសភាពមួយចំនួនទៀតតាមការចាំបាច់ ដើម្បីជាជំនួយការឲ្យគណៈកម្មការនេះ ។

## មាត្រា ៣៤.–

តារាងបេក្ខជនដែលបានស្នើដំឡើងថ្នាក់សម្រាប់ឋានន្តរស័ក្តិនីមួយៗ ត្រូវរៀបចំតាមលំដាប់អតីតភាពស្របតាមតារាងនៃថ្នាក់នីមួយៗ ។

តារាងនេះត្រូវបិទផ្សាយឲ្យសាមីជនដឹងនៅតាមសាលាជម្រះក្តី ។

## មាត្រា ៣៥.–

ចៅក្រមណាមួយដែលមានអតីតភាពគ្រប់កំណត់ត្រូវស្នើដំឡើងថ្នាក់ ឬឋានន្តរស័ក្តិ ហើយគ្មានឈ្មោះក្នុងតារាងខាងលើនេះ ចៅក្រមនោះអាចប្ដឹងតវ៉ាសុំចុះឈ្មោះរបស់ខ្លួនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ ចាប់ពីថ្ងៃទទួលដំណឹងអំពីតារាងស្នើ ដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ។ ផុតរយៈពេលនេះបណ្ដឹងតវ៉ាត្រូវទុកជាអសារបង់ ។

## មាត្រា ៣៦.–

ព្រឹត្តិបត្រឯកត្តជនរបស់ចៅក្រមដែលត្រូវបានចុះក្នុងបញ្ជីនៃថ្នាក់នីមួយៗ និងព្រឹត្តិបត្រឯកត្តជនរបស់ចៅក្រមដែលបានប្ដឹងតវ៉ា ត្រូវបញ្ជូនទៅគណៈកម្មការដំឡើងថ្នាក់ និងឋានន្តរស័ក្តិដែលមានចែងក្នុងមាត្រា ៣៣ នៃច្បាប់នេះ ឲ្យបានក្នុងសប្តាហ៍ទី ២ ខែ កុម្ភៈ នៃឆ្នាំនីមួយៗ ។

## មាត្រា ៣៧.–

ប្រធានគណៈកម្មការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ជាអ្នកកោះអញ្ជើញគណៈកម្មការខាងលើប្រជុំ ។ គណៈកម្មការនេះ ត្រូវរួមប្រជុំឲ្យបានមុនថ្ងៃចូលឆ្នាំថ្មីប្រពៃណីខ្មែរ ។

## មាត្រា ៣៨.–

ក្រោយពីបានពិនិត្យព្រឹត្តិបត្រឯកត្តជន និងសម្រេចលើបណ្ដឹងតវ៉ា និងក្រោយពីបានស្ដាប់សេចក្ដីពន្យល់សព្វគ្រប់របស់ប្រធាន សមាជិកម្នាក់ៗត្រូវដាក់ពិន្ទុពី ០ (សូន្យ) ដល់២០ (ម្ភៃ) ដល់ចៅក្រមបេក្ខជនម្នាក់ៗ ។ ការចុះឈ្មោះក្នុងតារាងបេក្ខជន ត្រូវធ្វើតាមលំដាប់គុណសម្បត្តិនៃលទ្ធផលពិន្ទុសរុប ។ ប្រសិនបើមានបេក្ខជនពីរនាក់ទទួលពិន្ទុស្មើគ្នា នោះបេក្ខជនដែលមានអាយុច្រើនជាងត្រូវចុះឈ្មោះមុនគេក្នុងបញ្ជី ។

## មាត្រា ៣៩.–

គណៈកម្មការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ត្រូវរៀបចំតារាងទៅតាមជំនាន់ចៅក្រមដែលដំឡើងថ្នាក់ និងឋានន្តរស័ក្តិ និងតាមលំដាប់ថ្នាក់ក្នុងតារាងចុះឈ្មោះ ដើម្បីដាក់ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមពិនិត្យ និងផ្ដល់យោបល់ ។ អគ្គលេខាធិការនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវរៀបចំតារាងឈ្មោះចៅក្រមដែលទទួលបានយោបល់យល់ព្រមរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចំពោះការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រ ។

**មាត្រា ៤០.-**

ចៅក្រមណាដែលកំពុងជាប់ក្នុងការអង្កេតជាបទវិន័យ ឬបទល្មើសព្រហ្មទណ្ឌ ត្រូវផ្អាកមិនទាន់ឲ្យមានសិទ្ធិចុះឈ្មោះក្នុងតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិទេ ។

**មាត្រា ៤១.-**

ក្នុងករណីដែលបេក្ខជនមិនត្រូវបានដំឡើងថ្នាក់ ឬឋានន្តរស័ក្តិ បេក្ខជននោះ មានអាទិភាពត្រូវបានចុះឈ្មោះមុនគេក្នុងតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិនៅឆ្នាំបន្ទាប់ ។

**មាត្រា ៤២.-**

ការដំឡើងថ្នាក់ ឬឋានន្តរស័ក្តិ និងការដំឡើងប្រាក់បៀវត្ស និងអតីតភាព ត្រូវគិតចាប់ពីថ្ងៃទី ១៣ ខែ មេសា នៃឆ្នាំនីមួយៗ ។

## ផ្នែកទី ៨
## ការតែងតាំង ការផ្លាស់ប្តូរ ការផ្អាច់ពីមុខងារ ការដាក់ឲ្យក្រៅក្របខណ្ឌការដាក់ឲ្យនៅទំនេរ និងការលុបឈ្មោះចៅក្រម

**មាត្រា ៤៣.-**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសម្រេច និងលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំង ការផ្លាស់ប្តូរការផ្អាច់ពីមុខងារ ការដាក់ឲ្យនៅក្រៅក្របខណ្ឌ ការដាក់ឲ្យនៅទំនេរ និងការលុបឈ្មោះចៅក្រមទាំងអស់ ។

**មាត្រា ៤៤.-**

ចៅក្រមអាចត្រូវបានអនុញ្ញាតឲ្យផ្អាច់ពីមុខងារ ឬឲ្យដាក់ក្រៅក្របខណ្ឌចៅក្រមបាន តាមការស្នើសុំរបស់សាមីខ្លួន ឬស្ថាប័នផ្សេងដោយមានការយល់ព្រមពីសាមីខ្លួន ។

ក្នុងករណីចាំបាច់ដែលត្រូវទៅបំពេញការងារជាបណ្តោះអាសន្ន នៅក្នុងតំណែងមុខងារសាធារណៈ តំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា សមាជិករាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការ មុខងារទទួលអាណត្តិដោយការបោះឆ្នោតដទៃទៀត ឬតំណែងទីប្រឹក្សាគ្រប់ឋានានុក្រម ចៅក្រមអាចសុំផ្អាច់ពីមុខងារ ។ ការអនុញ្ញាតឲ្យផ្អាច់ពីមុខងារនេះ ត្រូវធ្វើឡើងតាមសំណើរបស់សាមីខ្លួន ឬស្ថាប័នផ្សេងដោយមានការយល់ព្រមរបស់សាមីខ្លួន ។ ក្នុងរយៈពេលនៃការអនុញ្ញាតឲ្យផ្អាច់ពីមុខងារ ចៅក្រមនោះ ត្រូវបានបន្តទទួលប្រាក់បៀវត្សព្រម

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ទាំងសិទ្ធិក្នុងការឡើងថ្នាក់ ឬឋានន្តរស័ក្តិ និងសិទ្ធិក្នុងការចូលនិវត្តន៍របស់ខ្លួន ប៉ុន្តែពុំមានប្រាក់បំណាច់មុខងារ និងប្រាក់រង្វាន់ផ្សេងៗទៀតនៃមុខងារដើមរបស់ខ្លួនទេ ។

ក្នុងករណីចាំបាច់ដែលត្រូវទៅបំពេញការងារជាបណ្តោះអាសន្ននៅក្នុងសហគ្រាសសាធារណៈ ឬនៅតាមអង្គការអន្តរជាតិ ចៅក្រមអាចសុំនៅក្រៅក្របខណ្ឌ ។ ការអនុញ្ញាតឲ្យនៅក្រៅក្របខណ្ឌនេះ ត្រូវធ្វើឡើងតាមសំណើរបស់សាមីខ្លួន ឬស្ថាប័នផ្សេងដោយមានការយល់ព្រមរបស់សាមីខ្លួន ។ ចៅក្រមដែលត្រូវបានដាក់ឲ្យនៅក្រៅក្របខណ្ឌ ពុំមានសិទ្ធិទទួលប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារ និងប្រាក់បំណាច់ផ្សេងៗទៀត ដូចបានកំណត់ក្នុងមាត្រា ១៥ នៃច្បាប់នេះ ។

ចៅក្រមអាចត្រូវលុបឈ្មោះចេញពីក្របខណ្ឌចៅក្រម ក្នុងករណីដែលចៅក្រមនោះបានបោះបង់ការងារ ឬអវត្តមានលើសពី ៣០ (សាមសិប) ថ្ងៃ ដោយអនុវត្តតាមមាត្រា ៥២ នៃច្បាប់នេះ ឬដោយសាមីខ្លួនសុំលាឈប់ជាស្ថាពរ ។

ការលាឈប់របស់ចៅក្រម ត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយសាមីខ្លួន ។ ពាក្យសុំនេះត្រូវដាក់ជូនទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីពិនិត្យ និងសម្រេច ។

## មាត្រា ៤៥.-

ក្នុងករណីចាំបាច់ ដោយមូលហេតុផ្ទាល់ខ្លួន គ្រួសារ ឬវិសមិតភាព ចៅក្រមអាចស្នើសុំនៅទំនេរគ្មានប្រាក់បៀវត្សសម្រាប់រយៈពេលកំណត់ណាមួយ តាមពាក្យសុំរបស់សាមីខ្លួន ។ ការអនុញ្ញាតឲ្យនៅទំនេរគ្មានបៀវត្សអាចធ្វើឡើងសម្រាប់រយៈពេលម្តង ១ (មួយ) ឆ្នាំ ឬម្តង ២ (ពីរ) ឆ្នាំ ។ ការអនុញ្ញាតឲ្យនៅទំនេរនេះ អាចធ្វើបានតែពីរដងគត់ ហើយរយៈពេលសរុបនៃការអនុញ្ញាតនេះ មិនត្រូវឲ្យលើសពី ៤(បួន) ឆ្នាំឡើយ ។

លក្ខខណ្ឌដែលអាចអនុញ្ញាតឲ្យនៅទំនេរគ្មានបៀវត្ស តាមការស្នើសុំរបស់សាមីខ្លួនបានលុះត្រាតែចៅក្រមនោះបានបំពេញមុខងារក្នុងក្របខណ្ឌចៅក្រមយ៉ាងតិចបាន ៤ (បួន) ឆ្នាំ សិន ដោយមិនគិតពីចៅក្រមដែលត្រូវទទួលទណ្ឌកម្មវិន័យថ្នាក់ទី ២ (ពីរ) ចំណុច ខ មាត្រា ៥៥ នៃច្បាប់នេះឡើយ ។

ពាក្យសុំនេះត្រូវដាក់ជូនទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដើម្បីពិនិត្យនិងសម្រេច ។

## មាត្រា ៤៦.-

ចៅក្រមដែលកំពុងស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សលើកទី ១ (មួយ) បើមានបំណងសុំបន្ត ឬសុំចូលបម្រើការងារវិញត្រូវ ដាក់ពាក្យសុំឲ្យបាន ២ (ពីរ) ខែ មុនពេលផុតកំណត់នៃរយៈពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ។ ចៅក្រមណាដែលពុំបានដាក់ពាក្យសុំបន្តភាពទំនេរគ្មានបៀវត្ស ឬពុំបានចូលបំពេញមុខងាររបស់ខ្លួនវិញយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ ចាប់ពីផុតរយៈពេលនៃភាពទំនេរគ្មានបៀវត្ស

ទេនោះ ត្រូវចាត់ទុកថា បានបោះបង់ការងារ ហើយត្រូវលុបឈ្មោះចេញពីក្របខណ្ឌចៅក្រមចាប់ពីថ្ងៃនោះតទៅ ។

**មាត្រា ៤៧.-**

ចៅក្រមដែលត្រូវបានបញ្ជូនទៅធ្វើកម្មសិក្សា ដើម្បីឲ្យមានសុក្រឹតភាពក្នុងវិជ្ជាជីវៈ ត្រូវចាត់ទុកដូចជាចៅក្រមដែលកំពុងបំពេញមុខងារ ។

**មាត្រា ៤៨.-**

ក្នុងករណីមានការលុបឈ្មោះចេញពីក្របខណ្ឌចៅក្រម ដោយអនុវត្តតាមបញ្ញត្តិនៃច្បាប់នេះ សាមីខ្លួនមានសិទ្ធិទទួលយកប្រាក់ទាំងអស់ ដែលបេឡាសោធននិវត្តន៍បានកាត់លើប្រាក់បៀវត្សរបស់ខ្លួនរួចមកហើយតាមច្បាប់ ឬបទបញ្ជានៃបេឡាសោធននិវត្តន៍ ។

**មាត្រា ៤៩.-**

ប្រធានតុលាការកំពូលមានឋានន្តរស័ក្តិជាឧត្តមចៅក្រមថ្នាក់ខ្ពស់បំផុត ។ អនុប្រធាន និងចៅក្រមទាំងអស់នៃតុលាការកំពូលមានឋានន្តរស័ក្តិជាឧត្តមចៅក្រម និងមានចំនួនមិនលើសពី ២៥ (ម្ភៃប្រាំ) រូប ដោយរួមទាំងប្រធានតុលាការកំពូលផង ។ ប៉ុន្តែយោងតាមតម្រូវការចាំបាច់ ចំនួនចៅក្រមនៃតុលាការកំពូលអាចត្រូវកំណត់លើសពីនេះ ដោយព្រះរាជក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ប្រធានសាលាឧទ្ធរណ៍មានឋានន្តរស័ក្តិជាឧត្តមចៅក្រម ។ អនុប្រធាន និងចៅក្រមទាំងអស់នៃសាលាឧទ្ធរណ៍មានឋានន្តរស័ក្តិជាឧត្តមចៅក្រម ឬវរៈចៅក្រម ។

ប្រធានសាលាដំបូងមានឋានន្តរស័ក្តិជាវរៈចៅក្រម ។ អនុប្រធាន និងចៅក្រមសាលាដំបូងមានឋានន្តរស័ក្តិជាវរៈចៅក្រម ឬអនុចៅក្រម ។

## ផ្នែកទី ៩
## ភារកិច្ចចៅក្រម

**មាត្រា ៥០.-**

ចៅក្រមត្រូវមានភារកិច្ចទទួលខុសត្រូវចំពោះកិច្ចការដែលបានប្រគល់ឲ្យ និងត្រូវគោរពឲ្យបានម៉ឺងម៉ាត់នូវក្រមសីលធម៌របស់ខ្លួន ។

ក្នុងជីវភាពរស់នៅផ្ទាល់ខ្លួន ចៅក្រមមិនត្រូវប្រព្រឹត្តអំពើណាមួយដែលនាំឲ្យអាប់ឱនដល់កិត្តិយសនិងសេចក្តីថ្លៃថ្នូររបស់ខ្លួន និងដល់កិត្យានុភាពនៃអង្គចៅក្រមឡើយ ។

ក្នុងវិស័យនយោបាយ ចៅក្រមត្រូវប្រកាន់ជាច់ខាតនូវឥរិយាបថអព្យាក្រឹត ។

**មាត្រា ៥១.-**

ចៅក្រមទាំងអស់ មិនត្រូវបោះបង់ការងាររបស់ខ្លួន ឬអវត្តមានដោយគ្មានការអនុញ្ញាតពីថ្នាក់លើផ្ទាល់របស់ខ្លួនជាមុនឡើយ ។

**មាត្រា ៥២.-**

ការបោះបង់ការងារ ឬអវត្តមានឥតច្បាប់ដោយពុំមានមូលហេតុចាប់ពី ១៥ (ដប់ប្រាំ) ថ្ងៃ ឡើងទៅត្រូវទទួលវិន័យផ្អាកមិនឲ្យបើកប្រាក់បៀវត្ស ឬដាក់ឲ្យនៅទំនេរគ្មានបៀវត្ស ដោយគិតពីថ្ងៃបោះបង់ការងារ ឬថ្ងៃអវត្តមានគ្មានការអនុញ្ញាតនោះ ។ បើការបោះបង់ការងារ ឬអវត្តមានឥតច្បាប់ដោយពុំមានមូលហេតុលើសពី ៣០ (សាមសិប) ថ្ងៃ ហើយចៅក្រមនោះនៅតែមិនត្រឡប់មកបំពេញការងារវិញក្រោយការដាក់កំហិតចំនួនពីរដងនោះ ត្រូវលុបឈ្មោះចេញពីក្របខណ្ឌ ។

**មាត្រា ៥៣.-**

ចៅក្រមដែលកំពុងបំពេញមុខងារនៅតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ត្រូវសុំការអនុញ្ញាតជាមុនពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មុននឹងផ្សាយ ឬសុំឲ្យផ្សាយតាមគ្រប់មធ្យោបាយទាំងអស់នូវអត្ថបទ ឬការសរសេរសំណៅព្រមទាំងមតិផ្សេងៗ ដែលទាក់ទងនឹងមុខងាររបស់ខ្លួន ។

ការរំលោភលើបញ្ញត្តិនៃមាត្រានេះ ត្រូវទទួលទោសវិន័យ ដោយមិនទាន់គិតដល់ការចោទប្រកាន់ជាបទព្រហ្មទណ្ឌប្រសិនបើមាន ។

បទប្បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តចំពោះការផ្តល់ព័ត៌មានធម្មតាទាក់ទងនឹងដំណើរការនៃរឿងក្តីនៅតាមសាលាជម្រះក្តីក្នុងលក្ខខណ្ឌមិនបំពានដល់ការសម្ងាត់វិជ្ជាជីវៈដែលកំណត់ដោយច្បាប់ ។ ការផ្តល់ព័ត៌មាននេះ ត្រូវធ្វើឡើងតាមរយៈមន្ត្រីនៃអង្គភាពរដ្ឋបាលនៃសាលាជម្រះក្តី ។

## ជំពូកទី ១០
## ទណ្ឌកម្មវិន័យ

**មាត្រា ៥៤.-**

កំហុសរបស់ចៅក្រមក្នុងការបំពេញកាតព្វកិច្ចវិជ្ជាជីវៈ និងការធ្វើឲ្យប៉ះពាល់ដល់កិត្តិយស សីលធម៌ ស្អាតស្អំ និងសេចក្តីថ្លៃថ្នូរប្រាសចាកពីក្រមសីលធម៌របស់ចៅក្រម និងព្រះរាជអាជ្ញា នាំឲ្យមានទណ្ឌកម្មខាងវិន័យតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។ ប៉ុន្តែ ការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ចៅក្រម និងព្រះរាជអាជ្ញាក្នុងការអនុវត្តច្បាប់ មិនត្រូវចាត់ទុកថាជាកំហុសខាងវិន័យឡើយ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

ទណ្ឌកម្មខាងវិន័យមិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសណាមួយត្រូវបានប្រព្រឹត្ត ។

ចៅក្រមអាចត្រូវបានផ្អាកពីមុខងារជាបណ្តោះអាសន្ន ដោយប្រធានក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងករណីដែលចៅក្រមនោះកំពុងជាប់នៅក្នុងនីតិវិធីវិន័យរបស់ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

## មាត្រា ៥៥.-

ទណ្ឌកម្មខាងវិន័យមាន ២ (ពីរ) ថ្នាក់គឺ ៖

១-ទណ្ឌកម្មថ្នាក់ទី ១ (មួយ)

ក- ការស្តីបន្ទោសដោយផ្ទាល់មាត់

ខ- ការស្តីបន្ទោសដោយចុះក្នុងសំណុំលិខិតផ្ទាល់ខ្លួន

គ- ការផ្អាកមិនឲ្យចុះឈ្មោះក្នុងតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិមួយរយៈតែមិនត្រូវឲ្យលើសពី ២ (ពីរ) ឆ្នាំទេ ឬលុបឈ្មោះចេញពីតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិវិញក្នុងករណីដែលមានចុះឈ្មោះរួចហើយ ។

២-ទណ្ឌកម្មថ្នាក់ទី ២ (ពីរ)

ក- ការផ្លាស់ដោយបង្ខំ អាចតម្រូវឲ្យទទួលការបណ្តុះបណ្តាលបន្ថែម

ខ- ការព្យួរពីការងារមិនឲ្យមានបៀវត្ស ក្នុងរយៈពេលមិនឲ្យលើសពី ១ (មួយ) ឆ្នាំ

គ- ការបន្ថយមួយថ្នាក់ ឬច្រើនថ្នាក់ ឬបន្ថយឋានន្តរស័ក្តិ

ឃ- ការដាក់ឲ្យចូលនិវត្តន៍ដោយបង្ខំ

ង-ការបញ្ឈប់ពីមុខងារដោយបង្ខំ

ច- ការបណ្តេញចេញពីក្របខណ្ឌ ។

ទណ្ឌកម្មថ្នាក់ទី ២ (ពីរ) ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ បន្ទាប់ពីមានការសម្រេចពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

## មាត្រា ៥៦.-

ក្នុងករណីមានការបញ្ឈប់ពីមុខងារដោយបង្ខំ ឬការបណ្តេញចេញពីក្របខណ្ឌដោយអនុលោមតាមបញ្ញត្តិនៃច្បាប់នេះ សាមីខ្លួនមានសិទ្ធិទទួលយកប្រាក់ទាំងអស់ ដែលបេឡាសោធននិវត្តន៍បានកាត់លើប្រាក់បៀវត្សរបស់ខ្លួនរួចមកហើយ តាមច្បាប់ ឬបទបញ្ញានៃបេឡាសោធននិវត្តន៍ ។

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL

## ផ្នែកទី ១១
## ការចោទប្រកាន់តាមផ្លូវតុលាការ

### មាត្រា ៥៧.-

ចៅក្រមដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ អាចត្រូវទទួលការចោទប្រកាន់តាមផ្លូវតុលាការ ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចសម្រេចផ្ទេរសមត្ថកិច្ចទៅសាលាដំបូងផ្សេង ក្រៅពីសាលាដំបូងដែលចៅក្រមនោះបំពេញមុខងារ ។

ក្នុងករណីដែលចៅក្រមណាម្នាក់បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ហើយត្រូវបានព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់ ព្រះរាជអាជ្ញាត្រូវជូនដំណឹងអំពីការចោទប្រកាន់នោះ ទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក្នុងរយៈពេល ៧២ ម៉ោង យ៉ាងយូរ ។

បើមានការចាប់ ឬឃាត់ខ្លួនចៅក្រមណាម្នាក់ អាជ្ញាធរដែលមានសមត្ថកិច្ច ត្រូវជូនដំណឹងទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌អំពីការចាប់ ឬការឃាត់ខ្លួននោះ ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវជូនព័ត៌មានខាងលើនេះជាបន្ទាន់ទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

### មាត្រា ៥៨.-

ចៅក្រមដែលទទួលការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្អាកដោយស្វ័យប្រវត្តិមិនឲ្យបំពេញមុខងារជាបណ្ដោះអាសន្ន រហូតដល់មានសេចក្ដីសម្រេចរបស់តុលាការអំពីទោសជាស្ថាពរ ។ ចៅក្រមនេះត្រូវទទួលប្រាក់បៀវត្សជាធម្មតារហូតដល់មានសាលក្រមសម្រេចរបស់តុលាការថាមានទោស ។ ប្រាក់បៀវត្សនេះ ត្រូវផ្អាកជាបណ្ដោះអាសន្ន តាមសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចាប់ពីថ្ងៃដែលសាលក្រមតុលាការសម្រេចថាមានទោស ទោះបីមានបណ្ដឹងឧទ្ធរណ៍ពីសាលក្រមនេះក៏ដោយ ។

### មាត្រា ៥៩.-

ក្នុងករណីដែលចៅក្រមជាប់ចោទតាមផ្លូវតុលាការ ទទួលបានការលើកលែងចោទប្រកាន់ ឬត្រូវបានសម្រេចឲ្យរួចផុតពីបទចោទប្រកាន់ជាស្ថាពរ ចៅក្រមនោះត្រូវបានទទួលឲ្យចូលធ្វើការវិញភ្លាមដោយគិតពីអតីតភាពថ្នាក់ និងឋានន្តរស័ក្តិ សោធននិវត្តន៍ និងទទួលប្រាក់បៀវត្សដែលត្រូវផ្អាកជាបណ្ដោះអាសន្នពីមុនមកវិញទាំងអស់ ។

បញ្ញត្តិនេះ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្នុងករណីដែលចៅក្រមនោះពុំត្រូវបានលុបឈ្មោះចេញពីក្រមខណ្ឌចៅក្រមដោយអនុវត្តតាមបញ្ញត្តិនៃមាត្រា ៦១ នៃច្បាប់នេះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



ហ

## មាត្រា ៦០.-

ទោះបីមានសេចក្តីសម្រេចពីតុលាការ លើកលែងចោទប្រកាន់ ឬសម្រេចឲ្យរួចផុតពីបទចោទប្រកាន់ ឬផ្តន្ទាទោសក្តី បើសាមីខ្លួនបានប្រព្រឹត្តខុស នឹងក្រមសីលធម៌របស់ចៅក្រម និងព្រះរាជអាជ្ញា សាមីខ្លួនអាចដាក់ឲ្យចោទប្រកាន់ជាប់វិន័យថែមទៀត ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

## មាត្រា ៦១.-

ការផ្តន្ទាទោសជាបទឧក្រិដ្ឋ ឬជាបទមជ្ឈិមប្រព្រឹត្តដោយចេតនា ដោយគ្មានការព្យួរទោសបណ្តាលឲ្យមានការលុបឈ្មោះចេញពីក្របខណ្ឌចៅក្រម គិតពីថ្ងៃសាលក្រម ឬសាលដីកាចូលជាស្ថាពរ ។

## ផ្នែកទី ១២
## ការចូលនិវត្តន៍

## មាត្រា ៦២.-

ចៅក្រមទាំងពីរភេទត្រូវចូលនិវត្តន៍នៅពេលគ្រប់អាយុ ៦០ (ហុកសិប) ឆ្នាំ ។

ចៅក្រមទាំងអស់នៃតុលាការកំពូលដែលមានអាយុចាប់ពី ៦០ (ហុកសិប) ឆ្នាំ ឡើងទៅត្រូវចូលនិវត្តន៍តាមការស្នើសុំរបស់សាមីខ្លួន ។ ប៉ុន្តែ នៅពេលដល់អាយុ ៦៥ (ហុកសិបប្រាំ) ឆ្នាំ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវសម្រេចពីការបន្តការងាររបស់ចៅក្រមទាំងអស់នៃតុលាការកំពូល តាមការស្នើសុំរបស់សាមីខ្លួន ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លើកសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រអំពីកិច្ចការខាងលើនេះ ។

## មាត្រា ៦៣.-

ចៅក្រមដែលបានបម្រើការងារគ្រប់ ៣០ (សាមសិប) ឆ្នាំ ហើយអាចសុំចូលនិវត្តន៍បានមុនអាយុ ៦០ (ហុកសិប) ឆ្នាំ ។

ចៅក្រមដែលបានបម្រើការងារចាប់ពី ៣០ (សាមសិប) ឆ្នាំ ឡើងទៅ មានសិទ្ធទទួលប្រាក់សោធននិវត្តន៍អតីតភាពនៃប្រាក់បៀវត្សចុងក្រោយ ។

ចៅក្រមដែលបានបម្រើការងារចាប់ពី ២០ (ម្ភៃ) ឆ្នាំ ឡើងទៅ ដល់ក្រោម ៣០ (សាមសិប) ឆ្នាំ មានសិទ្ធិទទួលប្រាក់សោធននិវត្តន៍សមាមាត្រ នៃប្រាក់បៀវត្សចុងក្រោយ ។

ចៅក្រមដែលបានបម្រើការងារក្រោម ២០ (ម្ភៃ) ឆ្នាំ ត្រូវទទួលត្រឹមប្រាក់សោធននិវត្តន៍ដែលបានកាត់ទុក និងប្រាក់ឧបត្ថម្ភផ្សេងៗតែមួយលើក ។

ROYAUME DU CAMBODGE · LE MINISTRE du PALAIS ROYAL

រយៈពេលនៃការបម្រើការងារខាងលើ ត្រូវរាប់បញ្ចូលផងដែរនូវរយៈពេលបម្រើការងារជាអ្នករាជការសាធារណៈមុនការតែងតាំងជាចៅក្រម ។

ប្រាក់សោធននិវត្តន៍របស់ចៅក្រម បើកនៅអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ប្រាក់សោធននិវត្តន៍ បើកបានតែមួយកន្លែងគត់ ។

ការអនុវត្តរបបសោធននិវត្តន៍ ត្រូវកំណត់លំអិតដោយអនុក្រឹត្យ ។

## មាត្រា ៦៤.-

ចៅក្រមដែលមានអតីតភាពគ្រប់ ៣០ (សាមសិប) ឆ្នាំ មិនត្រូវបានកាត់ប្រាក់សោធននិវត្តន៍ទុកទៀតឡើយ ។ ប៉ុន្តែ បើចៅក្រមមានអតីតភាពមិនគ្រប់ ៣០ (សាមសិប) ឆ្នាំ នោះត្រូវកាត់ប្រាក់សោធននិវត្តន៍រហូតដល់មានអតីតភាពគ្រប់ចំនួន ៣០ (សាមសិប) ឆ្នាំ ដើម្បីបានទទួលប្រាក់សោធននិវត្តន៍អតីតភាព ។

## មាត្រា ៦៥.-

អតីតភាពការងាររបស់ចៅក្រម ត្រូវគិតតាំងពីថ្ងៃដែលសាមីខ្លួន បានចូលបម្រើការងាររដ្ឋទោះក្នុងសម័យណាក៏ដោយ ។

## មាត្រា ៦៦.-

ចៅក្រមទាំងឡាយដែលមិនអាចបំពេញការងារបានក្នុងវិជ្ជាជីវៈរបស់ខ្លួន ដោយមូលហេតុមកពីការបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវដាក់ឲ្យចូលនិវត្តន៍ ។ ការសម្រេចអំពីការបាត់បង់សម្បទាវិជ្ជាជីវៈត្រូវធ្វើដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយសំអាងលើលិខិតកោសលវិច័យរបស់ពេទ្យជំនាញ ដែលចាត់តាំងដោយក្រសួងសុខាភិបាល ។

ក្នុងករណីការបាត់បង់សម្បទាវិជ្ជាជីវៈនេះ បណ្តាលច្បាស់លាស់មកពីការបំពេញមុខងាររបស់ខ្លួន ឬបណ្តាលមកពីមនសិការខិតខំខ្លាំង ទៅលើកិច្ចការដែលជាប្រយោជន៍សាធារណៈ ចៅក្រមនោះត្រូវដាក់ឲ្យចូលនិវត្តន៍ដោយមានសិទ្ធិពិសេសទទួលបានប្រាក់សោធននិវត្តន៍ សម្រាប់ទុព្វលភាពដែលមានចំនួនស្មើនឹងសោធននិវត្តន៍អតីតភាព ដោយមិនគិតពីរយៈពេលបម្រើការងារ ។ ចៅក្រមនឹងអាចទទួលប្រាក់សោធននិវត្តន៍នេះបាន លុះត្រាតែជំងឺ ឬពិការភាពនោះ ជាមូលហេតុផ្ទាល់ ហើយច្បាស់លាស់នៃទុព្វលភាព ឬអសមត្ថភាពបំពេញការងារ ។

មូលហេតុ ប្រភព ប្រភេទ និងស្លាកស្នាមនៃរបួស ឬជំងឺ ត្រូវតែមានបញ្ជាក់ ដោយលិខិតកោសល្យវិច័យរបស់ពេទ្យជំនាញ ដែលចាត់តាំងដោយក្រសួងសុខាភិបាល ។

បើចៅក្រមទទួលមរណភាពមកពីការបម្រើការងារស្ថិតស្ថាញខាងលើ សហព័ទ្ធ និងកូនដែលស្ថិតនៅក្នុងភាពជាអនីតិជននៅឡើយ អាចទទួលប្រាក់បំណាច់ស្មើនឹងប្រាក់បៀវត្សរបស់អ្នកស្លាប់ចំនួន ១២ (ដប់ពីរ) ខែ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

ក្រៅពីនេះ រដ្ឋត្រូវឧបត្ថម្ភកូនដែលស្ថិតនៅក្នុងភាពជាអនីតិជន និងសហព័ទ្ធ លើកលែងតែសហព័ទ្ធនោះរៀបអាពាហ៍ពិពាហ៍ជាថ្មី ។

## មាត្រា ៦៧.-

ក្នុងករណីដែលមានការបាត់បង់សម្បទាវិជ្ជាជីវៈដូចមានកំណត់ក្នុងមាត្រា ៦៦ ខាងលើនេះ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវធ្វើរបាយការណ៍ ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីពិនិត្យ និងសម្រេចអំពីការដាក់ឲ្យចូលនិវត្តន៍ ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លើកសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រអំពីកិច្ចការខាងលើនេះ បន្ទាប់ពីបានការសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

# ផ្នែកទី ១៣
# ងារជាកិត្តិយស

## មាត្រា ៦៨.-

លើកលែងតែករណីដែលត្រូវដាក់ឲ្យចូលនិវត្តន៍ដោយបង្ខំ នៅពេលចូលនិវត្តន៍ ចៅក្រមទទួលងារជាចៅក្រមកិត្តិយស ហើយត្រូវទទួលបានឋានន្តរស័ក្តិមួយថ្នាក់ខ្ពស់ជាងឋានន្តរស័ក្តិនៅពេលបំពេញការងារ កាលបើចៅក្រមនោះ បានបំពេញការងារក្នុងឋានន្តរស័ក្តិនេះបានយ៉ាងតិច ១ (មួយ) ឆ្នាំ មុនពេលចូលវត្តន៍ ។ ងារជាកិត្តិយសនេះ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីកិច្ចការខាងលើនេះ ។

## មាត្រា ៦៩.-

ចៅក្រមចូលនិវត្តន៍ មានសិទ្ធិពេញលេញក្នុងការរក្សាទុករហូតនូវងារជាកិត្តិយសនេះ ។

ងារជាកិត្តិយសនេះ អាចដកហូតវិញបាន ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ កាលបើមានហេតុធ្វើឲ្យប៉ះពាល់ដល់កិត្តិយស ឬសេចក្តីថ្លៃថ្នូររបស់អង្គចៅក្រម ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## ផ្នែកទី ១៤
## កិច្ចសច្ចាប្រណិធាន

**មាត្រា ៧០.–**

មុននឹងចូលបម្រើការងារ ចៅក្រមត្រូវធ្វើសច្ចាប្រណិធាននៅព្រះបរមរាជវាំង ។

ខ្លឹមសារនៃសច្ចាប្រណិធានមានភ្ជាប់ជាឧបសម្ព័ន្ធនៃច្បាប់នេះ ។

**មាត្រា ៧១.–**

ការធ្វើសច្ចាប្រណិធានខាងលើ ត្រូវមានកំណត់ហេតុធ្វើដោយមន្ត្រីក្រសួងព្រះបរមរាជវាំងហើយត្រូវបញ្ជូនទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីតម្កល់ទុកក្នុងសំណុំលិខិតរបស់សាមីខ្លួន ។

**មាត្រា ៧២.–**

ចៅក្រមណាដែលគេចវេះមិនព្រមធ្វើសច្ចាប្រណិធាន មិនអាចបំពេញមុខងារជាចៅក្រមបានឡើយ ហើយអាចត្រូវលុបឈ្មោះចេញពីក្របខណ្ឌចៅក្រមបាន ។

ចៅក្រមដែលមើលងាយ ឬពោលពាក្យតិះដៀលលើពាក្យសច្ចាប្រណិធាន ដែលខ្លួនបានធ្វើសច្ចាប្រណិធានរួចហើយនោះ ត្រូវមានទោសជាវិន័យ ។

**មាត្រា ៧៣.–**

កាលបើត្រូវធ្វើជាសាក្សីនៅចំពោះមុខតុលាការ ចៅក្រមត្រូវធ្វើសម្បថតាមទំនៀមទម្លាប់នៃសាសនារបស់ខ្លួន និងតាមបែបបទរបស់តុលាការថែមទៀត ។

## ជំពូកទី ៣
## ព្រះរាជអាជ្ញា
## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ៧៤.–**

មហាអយ្យការអមតុលាការកំពូល ត្រូវដឹកនាំដោយអគ្គព្រះរាជអាជ្ញា ០១ (មួយ) រូប និងអមដោយអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាមួយចំនួនតាមការចាំបាច់ ។ អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ជាតំណាងមហាអយ្យការអមតុលាការកំពូល ។

មហាអយ្យការអមសាលាឧទ្ធរណ៍ ត្រូវដឹកនាំដោយអគ្គព្រះរាជអាជ្ញា ០១ (មួយ) រូប និងអមដោយអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាមួយចំនួនតាមការចាំបាច់ ។ អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ ជាតំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ដែលខ្លួនបំពេញការងារ ។

អយ្យការអមសាលាដំបូងត្រូវដឹកនាំដោយព្រះរាជអាជ្ញា ០១ (មួយ) រូប និងអមដោយព្រះរាជអាជ្ញារងមួយចំនួនតាមការចាំបាច់ ។ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូង ជាតំណាងអយ្យការអមសាលាដំបូង ដែលខ្លួនបំពេញការងារ ។

មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ។ ព្រះរាជអាជ្ញា ជាអ្នកទទួលបន្ទុកស្វែងរកបទល្មើសព្រហ្មទណ្ឌ ធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ។

ក្នុងរឿងរដ្ឋប្បវេណី និងរឿងក្តីផ្សេងទៀត តំណាងអង្គការអយ្យការអាចចូលរួមក្នុងនីតិវិធីតុលាការ និងបញ្ចេញយោបល់បាន ប្រសិនបើខ្លួនយល់ឃើញថាចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ ។

## មាត្រា ៧៥.-

គោលការណ៍សំខាន់ៗរបស់អង្គការអយ្យការរួមមាន ជាអាទិ៍ ដូចខាងក្រោម៖

១ -អង្គការអយ្យការជាអង្គឯកភាពដែលព្រះរាជអាជ្ញាទាំងអស់ត្រូវស្ថិតនៅក្រោមការដឹកនាំ និងការត្រួតពិនិត្យតាមឋានានុក្រមរបស់ខ្លួន ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជានាយឋានានុក្រមនៃអង្គការអយ្យការ ហើយអាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅអង្គការអយ្យការគ្រប់ជាន់ថ្នាក់ ។ អគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ ជាសេនាធិការឲ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌លើកិច្ចការនេះ ។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល គឺជានាយឋានានុក្រមនៃមហាអយ្យការ អមតុលាការកំពូល ។ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមតុលាការកំពូល ត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញា ដែលជានាយឋានានុក្រមរបស់ខ្លួន ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គឺជានាយឋានានុក្រមនៃមហាអយ្យការអមសាលាឧទ្ធរណ៍ ។ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមសាលាឧទ្ធរណ៍ ត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន ។ ព្រះរាជអាជ្ញាអមសាលាដំបូង គឺជានាយឋានានុក្រមនៃអយ្យការអមសាលាដំបូង ។ ព្រះរាជអាជ្ញារងទាំងអស់នៃអយ្យការអមសាលាដំបូង ត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន ។

២ -អង្គការអយ្យការគឺជាអង្គអវិភាគ ដែលតម្រូវឲ្យព្រះរាជអាជ្ញា ត្រូវបំពេញមុខងារនៅអង្គការអយ្យការអមសាលាជម្រះក្តីណាមួយមានកាតព្វកិច្ចរួមក្នុងមុខងារដូចគ្នា និងអាចជំនួសគ្នាទៅវិញទៅមកបាន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

តាមគោលការណ៍នេះ តំណាងអង្គការអយ្យការច្រើនរូប អាចបន្តការងារពីគ្នាបាននៅក្នុងសំណុំរឿងតែមួយ តាមការចាត់តាំងរបស់នាយឋានានុក្រម ។

៣- អង្គការអយ្យការគឺជាអង្គឯករាជ្យ ដែលមិនស្ថិតនៅក្រោមអំណាចនៃសាលាជម្រះក្តីដែលខ្លួននៅអមនោះទេ ។ សាលាជម្រះក្តីនេះ គ្មានអំណាចត្រួតពិនិត្យកិច្ចការរបស់ព្រះរាជអាជ្ញាឡើយ ។ ទោះបីក្នុងករណីដែលព្រះរាជអាជ្ញាមានកំហុសឆ្គងក្នុងការបំពេញមុខងារក៏ដោយ ក៏សាលាជម្រះក្តីមិនត្រូវចុះក្នុងសេចក្តីសម្រេចរបស់ខ្លួន យកការស្តីបន្ទោសអ្វីចំពោះព្រះរាជអាជ្ញាឡើយ ។ ការហាមឃាត់នេះត្រូវអនុវត្តទាំងក្នុងរឿងព្រហ្មទណ្ឌ ទាំងក្នុងរឿងក្តីផ្សេងទៀត ។ ប៉ុន្តែ សាលាជម្រះក្តីអាចលើកសំណើទៅនាយឋានានុក្រមរបស់ព្រះរាជអាជ្ញា អំពីកំហុសឆ្គងរបស់ព្រះរាជអាជ្ញាបាន ។

**មាត្រា ៧៦.-**

ជារៀងរាល់ឆ្នាំ៖

- ព្រះរាជអាជ្ញាអមសាលាដំបូង ត្រូវធ្វើរបាយការណ៍អំពីបទល្មើស និងសកម្មភាពការងាររបស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងចម្លងជូនអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដែលមានសមត្ថកិច្ចដែនដី ។
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវធ្វើរបាយការណ៍អំពីបទល្មើស សកម្មភាពការងាររបស់ខ្លួន និងសកម្មភាពការងាររបស់អយ្យការអមសាលាដំបូងទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួនជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងចម្លងជូនអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ។
- អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ត្រូវធ្វើរបាយការណ៍អំពីសកម្មភាពការងាររបស់មហាអយ្យការអមតុលាការកំពូល ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៧៧.-**

ព្រះរាជអាជ្ញាទាំងឡាយត្រូវអនុវត្តមុខងារ និងតួនាទីរបស់ខ្លួន ដោយឈរលើគោលការណ៍គោរពច្បាប់ដោយមិនទទួល ការគាបសង្កត់ ការគំរាមកំហែង ឬការបំភិតបំភ័យ ការបង្គាប់បញ្ជាដោយផ្ទាល់ ឬដោយប្រយោល ពីភាគីណាមួយក្នុងរឿងក្តី ឬពីបុគ្គលណាមួយឡើយ លើកលែងតែបញ្ញត្តិនៃមាត្រា ៧៥ នៃច្បាប់នេះ ។

## ផ្នែកទី ២
## ឋានន្តរស័ក្តិ និងថ្នាក់

**មាត្រា ៧៨.-**

ក្របខណ្ឌព្រះរាជអាជ្ញារួមមាន ៣ (បី) ឋានន្តរស័ក្តិ ៖

- ឧត្តមព្រះរាជអាជ្ញា
- វរៈព្រះរាជអាជ្ញា
- អនុព្រះរាជអាជ្ញា ។

**មាត្រា ៧៩.–**

ថ្នាក់សម្រាប់ឋានន្តរស័ក្តិឧត្តមព្រះរាជអាជ្ញា ឋានន្តរស័ក្តិវរៈព្រះរាជអាជ្ញា និងឋានន្តរស័ក្តិអនុព្រះរាជអាជ្ញា ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

## ផ្នែកទី ៣
## ឯកសណ្ឋាន

**មាត្រា ៨០.–**

បញ្ញត្តិនៃជំពូកទី ២ (ចៅក្រម) ផ្នែកទី ៣ (ឯកសណ្ឋាន) នៃច្បាប់នេះ ដែលអនុវត្តចំពោះចៅក្រម ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះព្រះរាជអាជ្ញា ។

## ផ្នែកទី ៤
## ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ ប្រាក់រង្វាន់ និងការសម្រាកប្រចាំឆ្នាំ

**មាត្រា ៨១.–**

បញ្ញត្តិនៃជំពូកទី ២ (ចៅក្រម) ផ្នែកទី ៤ (ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ ប្រាក់រង្វាន់ និងការសម្រាកប្រចាំឆ្នាំ) នៃច្បាប់នេះ ដែលអនុវត្តចំពោះចៅក្រម ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះព្រះរាជអាជ្ញា ។

## ផ្នែកទី ៥
## ការជ្រើសរើសព្រះរាជអាជ្ញា

**មាត្រា ៨២.–**

ការជ្រើសរើស និងការបណ្តុះបណ្តាលព្រះរាជអាជ្ញា ត្រូវអនុវត្តរួមគ្នាជាមួយការជ្រើសរើស និងការបណ្តុះបណ្តាលចៅក្រមតាមបញ្ញត្តិនៃជំពូកទី ២ (ចៅក្រម) ផ្នែកទី ៥ (ការជ្រើសរើសចៅក្រម) នៃច្បាប់នេះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

## ផ្នែកទី ៦
## ការធ្វើកម្មសិក្សា និងការតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា

### មាត្រា ៨៣.-

សិស្សព្រះរាជអាជ្ញាដែលបានបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈដោយជោគជ័យ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ជាព្រះរាជអាជ្ញាកម្មសិក្សា ក្នុងឋានន្តរស័ក្តិជាអនុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ ។ ព្រះរាជអាជ្ញាកម្មសិក្សា ត្រូវធ្វើកម្មសិក្សារយៈពេល ១ (មួយ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការតែងតាំង ។

ការធ្វើកម្មសិក្សារបស់ព្រះរាជអាជ្ញាកម្មសិក្សា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ការតែងតាំងជាព្រះរាជអាជ្ញាកម្មសិក្សា មានអានុភាពដល់ការរៀបចំប្រាក់បៀវត្ស និងការគិតអំពីអតីតភាពការងារ ។

### មាត្រា ៨៤.-

ព្រះរាជអាជ្ញាកម្មសិក្សាដែលបានបំពេញកម្មសិក្សាចប់ដោយជោគជ័យ ត្រូវតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា និងមានឋានន្តរស័ក្តិជាអនុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីការតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញានេះ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចសម្រេចឲ្យព្រះរាជអាជ្ញាកម្មសិក្សាបន្តធ្វើកម្មសិក្សា ១ (មួយ) ឆ្នាំ បន្ថែមទៀតកាលបើព្រះរាជអាជ្ញាកម្មសិក្សានោះ ពុំទទួលបានជោគជ័យក្នុងការធ្វើកម្មសិក្សា ឬមានការអាក់ខានមិនបានធ្វើកម្មសិក្សាសរុបទាំងអស់លើសពី ៣០ (សាមសិប) ថ្ងៃ ។

ក្នុងករណីដែលព្រះរាជអាជ្ញាកម្មសិក្សាឈប់រហូតលើសពី ៣០ (សាមសិប) ថ្ងៃ ដោយគ្មានការអនុញ្ញាតច្បាប់ ឬព្រះរាជអាជ្ញាកម្មសិក្សា ដែលមិនបានទទួលជោគជ័យជាថ្មីម្តងទៀតក្នុងការធ្វើកម្មសិក្សាបន្ថែម ត្រូវលុបឈ្មោះចេញពីក្របខណ្ឌព្រះរាជអាជ្ញា ដោយអនុវត្តតាមបញ្ញត្តិនៃមាត្រា ៨៩ នៃច្បាប់នេះ ។

### មាត្រា ៨៥.-

ព្រះរាជអាជ្ញាកម្មសិក្សាដែលមិនមានសម្បទាគ្រប់គ្រាន់ ឬមានសុខភាពមិនគ្រប់គ្រាន់ដើម្បីបំពេញមុខងាររបស់ខ្លួនតាមលក្ខខណ្ឌដែលច្បាប់បានកំណត់ ឬមានការខុសឆ្គងក្នុងការបម្រើការងារមិនបានពេញលេញ អាចត្រូវលុបឈ្មោះចេញពីក្របខណ្ឌព្រះរាជអាជ្ញាបានគ្រប់ពេលវេលា ដោយអនុវត្តតាមបញ្ញត្តិនៃមាត្រា ៨៩ នៃច្បាប់នេះ ។

ការលុបឈ្មោះចេញ ឬការតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា ត្រូវធ្វើក្នុងរយៈពេល ៣ (បី) ខែ យ៉ាងយូរក្រោយពីការបញ្ចប់កម្មសិក្សា ។

## ផ្នែកទី ៧
## ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ

### មាត្រា ៨៦.-

បញ្ញត្តិចាប់ពីមាត្រា ២៧ ដល់មាត្រា ៣០ មាត្រា ៣២ ដល់មាត្រា ៣៨ និងមាត្រា ៤០ ដល់មាត្រា ៤២ នៃជំពូកទី ២ (ចៅក្រម) ផ្នែកទី ៧ (ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ) នៃច្បាប់នេះ ដែលអនុវត្តចំពោះចៅក្រម ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះព្រះរាជអាជ្ញា ។

### មាត្រា ៨៧.-

ជារៀងរាល់ឆ្នាំនៅសប្តាហ៍ទី ១ នៃខែ មករា ព្រះរាជអាជ្ញាម្នាក់ៗត្រូវបានទទួលនូវព្រឹត្តិបត្រឯកត្តជន ដែលព្រះរាជអាជ្ញានោះ ត្រូវបំពេញតាមចំណុចសំណួរទាំងឡាយ ។

ព្រឹត្តិបត្រឯកត្តជន ត្រូវដាក់ពិន្ទុដោយមានបញ្ជាក់យោបល់ និងមូលហេតុច្បាស់លាស់ ។

ចំពោះការដាក់ពិន្ទុត្រូវអនុវត្តដូចខាងក្រោម ៖

១-ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូង ត្រូវដាក់ពិន្ទុដោយព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង ។

២-ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ ត្រូវដាក់ពិន្ទុដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

៣-ព្រះរាជអាជ្ញាអមសាលាដំបូង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល ត្រូវដាក់ពិន្ទុដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ។

៤-ព្រះរាជអាជ្ញាដែលបានផ្លាស់ឲ្យទៅបំពេញភារកិច្ចនៅស្ថាប័នផ្សេងៗ ត្រូវដាក់ពិន្ទុដោយប្រធានស្ថាប័ននោះ ។

### មាត្រា ៨៨.-

គណៈកម្មការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ត្រូវរៀបចំតារាងទៅតាមជំនាន់ព្រះរាជអាជ្ញាដែលដំឡើងថ្នាក់ និងឋានន្តរស័ក្តិ និងតាមលំដាប់ថ្នាក់ក្នុងតារាងចុះឈ្មោះ ដើម្បីដាក់ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមពិនិត្យ និងផ្តល់យោបល់ ។ អគ្គលេខាធិការនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវរៀបចំតារាងឈ្មោះព្រះរាជអាជ្ញាដែលត្រូវដំឡើងថ្នាក់ និងឋានន្តរស័ក្តិទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

## ផ្នែកទី ៨
## ការតែងតាំង ការផ្លាស់ប្តូរ ការផ្អាកពីមុខងារ ការដាក់ឲ្យនៅក្រៅក្របខណ្ឌ ការដាក់ឲ្យនៅទំនេរ និងការលុបឈ្មោះព្រះរាជអាជ្ញា

### មាត្រា ៨៩.-

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រពីការតែងតាំង ការផ្លាស់ប្តូរការផ្អាកពីមុខងារ ការដាក់ឲ្យនៅក្រៅក្របខណ្ឌ ការដាក់ឲ្យនៅទំនេរ និងការលុបឈ្មោះព្រះរាជអាជ្ញាទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវបានពិគ្រោះយោបល់ជាចាំបាច់ចំពោះសំណើខាងលើ ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌លើកសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រ អំពីកិច្ចការខាងលើនេះ ។

### មាត្រា ៩០.-

ព្រះរាជអាជ្ញាអាចត្រូវបានអនុញ្ញាតឲ្យផ្អាកពីមុខងារ ឬឲ្យដាក់ក្រៅក្របខណ្ឌព្រះរាជអាជ្ញាបានតាមការស្នើសុំរបស់សាមីខ្លួន ឬរបស់ស្ថាប័នផ្សេងដោយមានការយល់ព្រមពីសាមីខ្លួន ។

ក្នុងករណីចាំបាច់ ដែលត្រូវទៅបំពេញការងារជាបណ្តោះអាសន្ន នៅក្នុងតំណែងមុខងារសាធារណៈ តំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា សមាជិករាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការ មុខងារទទួលអាណត្តិដោយការបោះឆ្នោតដទៃទៀត ឬតំណែងទីប្រឹក្សាគ្រប់ឋានានុក្រម ព្រះរាជអាជ្ញាអាចសុំផ្អាកពីមុខងារ ។ ការអនុញ្ញាតឲ្យផ្អាកពីមុខងារនេះ ត្រូវធ្វើឡើងតាមសំណើរបស់សាមីខ្លួន ឬរបស់ស្ថាប័នផ្សេងដោយមានការយល់ព្រមរបស់សាមីខ្លួន ។ ក្នុងរយៈពេលនៃការអនុញ្ញាតឲ្យផ្អាកពីមុខងារព្រះរាជអាជ្ញានោះត្រូវបានបន្តទទួលប្រាក់បៀវត្ស ព្រមទាំងសិទ្ធិក្នុងការឡើងថ្នាក់ ឬឋានន្តរស័ក្តិ និងសិទ្ធិក្នុងការចូលនិវត្តន៍របស់ខ្លួន ប៉ុន្តែពុំមានប្រាក់បំណាច់មុខងារនិងប្រាក់រង្វាន់ផ្សេងៗទៀតនៃមុខងារដើមរបស់ខ្លួនទេ ។

ក្នុងករណីចាំបាច់ដែលត្រូវទៅ បំពេញការងារជាបណ្តោះអាសន្ននៅក្នុងសហគ្រាសសាធារណៈ ឬនៅតាមអង្គការអន្តរជាតិព្រះរាជអាជ្ញា អាចសុំនៅក្រៅក្របខណ្ឌ ។ ការអនុញ្ញាតឲ្យនៅក្រៅក្របខណ្ឌនេះត្រូវធ្វើឡើងតាមសំណើរបស់សាមីខ្លួន ឬរបស់ស្ថាប័នផ្សេងដោយមានការយល់ព្រមរបស់សាមីខ្លួន ។ ព្រះរាជអាជ្ញាដែលត្រូវបានដាក់ឲ្យនៅក្រៅក្របខណ្ឌ ពុំមានសិទ្ធិទទួលប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារ និងប្រាក់បំណាច់ផ្សេងៗ ទៀតដូចបាន កំណត់ក្នុងមាត្រា ៨១ នៃច្បាប់នេះឡើយ ។

ព្រះរាជអាជ្ញាអាចត្រូវបានផ្អាកពីមុខងារជាបណ្តោះអាសន្នដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្នុងករណីដែលព្រះរាជអាជ្ញានោះ កំពុងជាប់នៅក្នុងនីតិវិធីវិន័យរបស់ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ព្រះរាជអាជ្ញាអាចត្រូវលុបឈ្មោះចេញពីក្របខណ្ឌព្រះរាជអាជ្ញា ក្នុងករណីដែលព្រះរាជអាជ្ញានោះទទួលទណ្ឌកម្មជាវិន័យថ្នាក់ទី ២ (ពីរ) ឬនៅពេលដែលព្រះរាជអាជ្ញានោះបានបោះបង់ការងារ ឬអវត្តមាន

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

លើសពី ៣០ (សាមសិប) ថ្ងៃ ដោយអនុវត្តតាមមាត្រា ៥២ នៃច្បាប់នេះ ឬដោយសាមីខ្លួនសុំលាឈប់ជាស្ថាពរ ។

ការលាឈប់របស់ព្រះរាជអាជ្ញាត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយសាមីខ្លួន ។ ពាក្យសុំនេះត្រូវដាក់ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និងចាត់ការតាមនីតិវិធី ។

**មាត្រា ៩១.-**

ក្នុងករណីចាំបាច់ ដោយមូលហេតុផ្ទាល់ខ្លួន គ្រួសារ ឬវិសមិតភាព ព្រះរាជអាជ្ញាអាចស្នើសុំនៅទំនេរគ្មានបៀវត្សសម្រាប់រយៈពេលកំណត់ណាមួយ តាមពាក្យសុំរបស់សាមីខ្លួន ។ ការអនុញ្ញាតឲ្យនៅទំនេរគ្មានបៀវត្ស អាចធ្វើឡើងសម្រាប់រយៈពេលម្តង ១ (មួយ) ឆ្នាំ ឬម្តង ២ (ពីរ) ឆ្នាំ ។ ការអនុញ្ញាតឲ្យនៅទំនេរនេះ អាចធ្វើបានតែពីរដងគត់ ហើយរយៈពេលសរុបនៃការអនុញ្ញាតនេះ មិនត្រូវឲ្យលើសពី ៤ (បួន) ឆ្នាំ ឡើយ ។ លក្ខខណ្ឌដែលអាចអនុញ្ញាតឲ្យនៅទំនេរគ្មានបៀវត្ស តាមការស្នើសុំរបស់សាមីខ្លួនបាន លុះត្រាតែព្រះរាជអាជ្ញានោះ បានបំពេញមុខងារក្នុងក្របខណ្ឌព្រះរាជអាជ្ញាយ៉ាងតិចបាន ៤ (បួន) ឆ្នាំ សិន ដោយមិនគិតពីព្រះរាជអាជ្ញាដែលត្រូវទទួលទណ្ឌកម្មជាវិន័យថ្នាក់ទី ២ (ពីរ) ។

ពាក្យសុំដាក់ឲ្យនៅទំនេរ ត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយសាមីខ្លួន ។ ពាក្យសុំនេះត្រូវដាក់ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និងចាត់ការតាមនីតិវិធី ។

**មាត្រា ៩២.-**

ព្រះរាជអាជ្ញាដែលកំពុងស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សលើកទី ១ (មួយ) បើមានបំណងសុំបន្ត ឬសុំចូលបម្រើការងារវិញ ត្រូវដាក់ពាក្យសុំឲ្យបាន ២ (ពីរ) ខែ មុនពេលផុតកំណត់នៃរយៈពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ។ ព្រះរាជអាជ្ញាណាដែលពុំបានដាក់ពាក្យសុំបន្តភាពទំនេរគ្មានបៀវត្ស ឬពុំបានចូលបំពេញមុខងាររបស់ខ្លួនវិញយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ ចាប់ពីផុតរយៈពេលនៃភាពទំនេរគ្មានបៀវត្សទេនោះ ត្រូវចាត់ទុកថាបានបោះបង់ការងារ ហើយត្រូវលុបឈ្មោះចេញពីក្របខណ្ឌចាប់ពីថ្ងៃនោះតទៅ ។

**មាត្រា ៩៣.-**

ព្រះរាជអាជ្ញាដែលត្រូវបានបញ្ជូនទៅធ្វើកម្មសិក្សា ដើម្បីឲ្យមានសុក្រឹតភាពក្នុងវិជ្ជាជីវៈ ត្រូវចាត់ទុកដូចជាព្រះរាជអាជ្ញាដែលកំពុងបំពេញមុខងារ ។

**មាត្រា ៩៤.-**

ក្នុងករណីមានការលុបឈ្មោះចេញពីក្របខណ្ឌព្រះរាជអាជ្ញា ដោយអនុលោមតាមបញ្ញត្តិនៃច្បាប់នេះ សាមីខ្លួនមានសិទ្ធិទទួលយកប្រាក់ទាំងអស់ ដែលបេឡាសោធននិវត្តន៍បានកាត់លើប្រាក់បៀវត្សរបស់ខ្លួនរួចមកហើយ តាមច្បាប់ ឬបទបញ្ជានៃបេឡាសោធននិវត្តន៍ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង



ស.ហ.

## មាត្រា ៩៥.-

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល មានឋានន្តរស័ក្តិជាឧត្តមព្រះរាជអាជ្ញាថ្នាក់ខ្ពស់បំផុត ។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូលទាំងអស់មានឋានន្តរស័ក្តិជាឧត្តមព្រះរាជអាជ្ញា ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានឋានន្តរស័ក្តិជាឧត្តមព្រះរាជអាជ្ញា ។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទាំងអស់មានឋានន្តរស័ក្តិជាឧត្តមព្រះរាជអាជ្ញា ឬវរៈព្រះរាជអាជ្ញា ។

ព្រះរាជអាជ្ញាអមសាលាដំបូងមានឋានន្តរស័ក្តិជាវរៈព្រះរាជអាជ្ញា ។ ព្រះរាជអាជ្ញារងអមសាលាដំបូងទាំងអស់មានឋានន្តរស័ក្តិជាវរៈព្រះរាជអាជ្ញា ឬអនុព្រះរាជអាជ្ញាឡើងទៅ ។

# ផ្នែកទី ៩
# ភារកិច្ចព្រះរាជអាជ្ញា

## មាត្រា ៩៦.-

ព្រះរាជអាជ្ញាត្រូវមានភារកិច្ចទទួលខុសត្រូវចំពោះកិច្ចការដែលបានប្រគល់ឲ្យ និងគោរពឲ្យបានម៉ឺងម៉ាត់នូវក្រមសីលធម៌របស់ខ្លួន ។

ក្នុងជីវភាពរស់នៅផ្ទាល់ខ្លួន ព្រះរាជអាជ្ញាមិនត្រូវប្រព្រឹត្តអំពើណាមួយ ដែលនាំឲ្យអាប់ឱនដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្លួន និងដល់កិត្យានុភាពនៃអង្គអយ្យការឡើយ ។

ព្រះរាជអាជ្ញាដែលកំពុងបំពេញមុខងារនៅតាមអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ត្រូវសុំការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រីក្រសួង យុត្តិធម៌មុននឹងផ្សាយ ឬសុំឲ្យផ្សាយតាមគ្រប់មធ្យោបាយទាំងអស់នូវអត្ថបទ ឬការសរសេរសំណៅព្រមទាំងមតិផ្សេងៗ ដែលអាចប៉ះពាល់ដល់កិត្យានុភាពនៃស្ថាប័នអយ្យការ ឬស្ថាប័នតុលាការ ។ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ព្រះរាជអាជ្ញាដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។

ក្នុងវិស័យនយោបាយព្រះរាជអាជ្ញាត្រូវប្រកាន់ដាច់ខាតនូវឥរិយាបថអព្យាក្រឹត ។

ការរំលោភលើបញ្ញត្តិនៃកថាខណ្ឌទី ២ និងទី ៣ នៃ មាត្រានេះ ត្រូវទទួលទោសវិន័យ ដោយមិនទាន់គិតដល់ការចោទប្រកាន់ជាបទព្រហ្មទណ្ឌ ប្រសិនបើមាន ។

## មាត្រា ៩៧.-

ព្រះរាជអាជ្ញាទាំងអស់ មិនត្រូវបោះបង់ការងាររបស់ខ្លួន ឬអវត្តមានដោយគ្មានការអនុញ្ញាតពីថ្នាក់លើផ្ទាល់របស់ខ្លួនជាមុនឡើយ ។

សំណើសុំអនុញ្ញាតអវត្តមានរបស់ព្រះរាជអាជ្ញាអមសាលាដំបូង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៩៨.-**

ការបោះបង់ការងារ ឬអវត្តមានឥតច្បាប់ ដោយពុំមានមូលហេតុចាប់ពី ១៥ (ដប់ប្រាំ) ថ្ងៃ ឡើងទៅ ត្រូវទទួលវិន័យផ្អាកមិនឲ្យបើកប្រាក់បៀវត្ស ឬដាក់ឲ្យទំនេរគ្មានបៀវត្ស ដោយគិតពីថ្ងៃបោះបង់ការងារ ឬថ្ងៃអវត្តមានគ្មានការអនុញ្ញាតនោះ ។ បើបោះបង់ការងារ ឬអវត្តមានឥតច្បាប់ដោយពុំមានមូលហេតុលើស ពី ៣០ (សាមសិប) ថ្ងៃ ហើយព្រះរាជអាជ្ញានោះ នៅតែមិនត្រឡប់មកបំពេញការងារវិញ ក្រោយការដាក់ កំហិតចំនួនពីរដងនោះ ត្រូវលុបឈ្មោះចេញពីក្របខណ្ឌ ។

## ផ្នែកទី ១០
## ទណ្ឌកម្មវិន័យ

**មាត្រា ៩៩.-**

បញ្ញត្តិនៃជំពូកទី ២ (ចៅក្រម) ផ្នែកទី ១០ (ទណ្ឌកម្មវិន័យ) នៃច្បាប់នេះ ដែលអនុវត្តចំពោះចៅ ក្រម ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះព្រះរាជអាជ្ញា ។

## ផ្នែកទី ១១
## ការចោទប្រកាន់តាមផ្លូវតុលាការ

**មាត្រា ១០០.-**

បញ្ញត្តិនៃជំពូកទី ២ (ចៅក្រម) ផ្នែកទី ១១ (ការចោទប្រកាន់តាមផ្លូវតុលាការ) នៃច្បាប់នេះ ដែលអនុវត្តចំពោះចៅក្រម ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះព្រះរាជអាជ្ញា ។

## ផ្នែកទី ១២
## ការចូលនិវត្តន៍

**មាត្រា ១០១.-**

ព្រះរាជអាជ្ញាទាំងពីរភេទត្រូវចូលនិវត្តន៍នៅពេលគ្រប់អាយុ ៦០ (ហុកសិប) ឆ្នាំ ។

ដោយឡែកព្រះរាជអាជ្ញាទាំងអស់នៃមហាអយ្យការអមតុលាការកំពូល ដែលមានអាយុចាប់ពី ៦០ (ហុកសិប) ឆ្នាំឡើងទៅ ត្រូវចូលនិវត្តន៍តាមការស្នើសុំរបស់សាមីខ្លួន ។ ប៉ុន្តែ នៅពេលដល់អាយុ ៦៥ (ហុកសិបប្រាំ) ឆ្នាំ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវសម្រេចពីការបន្តការងាររបស់ព្រះរាជអាជ្ញាទាំង អស់នៃមហាអយ្យការអមតុលាការកំពូល តាមការស្នើសុំរបស់សាមីខ្លួន ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លើកសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រអំពីកិច្ចការខាងលើនេះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ១០២.-**

បញ្ញត្តិចាប់ពីមាត្រា ៦៣ ដល់មាត្រា ៦៧ នៃជំពូកទី ២ (ចៅក្រម) ផ្នែកទី ១២ (ការចូលនិវត្តន៍) នៃច្បាប់នេះ ដែលអនុវត្តចំពោះចៅក្រម ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះព្រះរាជអាជ្ញា ។

## ផ្នែកទី ១៣
## ងារជាកិត្តិយស

**មាត្រា ១០៣.-**

លើកលែងតែករណីដែលត្រូវដាក់ឲ្យចូលនិវត្តន៍ដោយបង្ខំ នៅពេលចូលនិវត្តន៍ព្រះរាជអាជ្ញាទទួលងារជាព្រះរាជអាជ្ញាកិត្តិយស ហើយត្រូវទទួលបានឋានន្តរស័ក្តិមួយថ្នាក់ខ្ពស់ជាងឋានន្តរស័ក្តិនៅពេលបំពេញការងារ កាលបើព្រះរាជអាជ្ញានោះបានបំពេញការងារក្នុងឋានន្តរស័ក្តិនេះ បានយ៉ាងតិច ១ (មួយ) ឆ្នាំមុនពេលចូលនិវត្តន៍ ។ ងារជាកិត្តិយសនេះ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្ដីស្នើថ្វាយព្រះមហាក្សត្រអំពីកិច្ចការខាងលើនេះ ។

**មាត្រា ១០៤.-**

ព្រះរាជអាជ្ញាចូលនិវត្តន៍ មានសិទ្ធិពេញលេញក្នុងការរក្សាទុករហូតនូវងារជាកិត្តិយសនេះ ។

ងារជាកិត្តិយសនេះ អាចដកហូតវិញបាន ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ កាលបើមានហេតុធ្វើឲ្យប៉ះពាល់ដល់កិត្តិយស ឬសេចក្ដីថ្លៃថ្នូររបស់អង្គចៅក្រម ។

## ផ្នែកទី ១៤
## កិច្ចសច្ចាប្រណិធាន

**មាត្រា ១០៥.-**

បញ្ញត្តិនៃជំពូកទី ២ (ចៅក្រម) ផ្នែកទី ១៤ (កិច្ចសច្ចាប្រណិធាន) នៃច្បាប់នេះ ដែលអនុវត្តចំពោះចៅក្រម ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះព្រះរាជអាជ្ញា ។

## ជំពូកទី ៤
## វិសមិតភាព

**មាត្រា ១០៦.-**

ការបំពេញមុខងារជាចៅក្រម ឬព្រះរាជអាជ្ញា នៅគ្រប់សាលាជម្រះក្ដី ឬអង្គការអយ្យការអមសាលាជម្រះក្ដី មានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈ មុខងារជាតំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

សមាជិករាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការ មុខងារទទួលអាណត្តិដោយការបោះឆ្នោតដទៃទៀត ឬមុខងារជាទីប្រឹក្សាគ្រប់ឋានានុក្រម លើកលែងតែមានបទប្បញ្ញត្តិផ្ទុយពីនេះ ។

ចៅក្រម ឬព្រះរាជអាជ្ញាដែលកំពុងបំពេញមុខងារនៅគ្រប់សាលាជម្រះក្តី ឬអង្គការអយ្យការអមសាលាជម្រះក្តី មិនអាចបំពេញមុខងារជាមេធាវី មុខរបរពាណិជ្ជកម្ម ឬធ្វើសកម្មភាពណាមួយផ្សេងទៀត ដែលនាំឲ្យមានទំនាស់ផលប្រយោជន៍ ឬដែលប៉ះពាល់ដល់កិត្តិយសនៃអង្គចៅក្រម ។ ប៉ុន្តែ ចៅក្រម និងព្រះរាជអាជ្ញា អាចបំពេញមុខងារជាគ្រូឧទ្ទេសនាមតាមគ្រឹះស្ថានសិក្សាបាន ។

**មាត្រា ១០៧.-**

ចៅក្រម ឬព្រះរាជអាជ្ញាដែលបានអនុញ្ញាតឲ្យនៅទំនេរ ប្រសិនបើមានបំណងប្រកបការងារឯកជន ត្រូវជូនដំណឹងដល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចជំទាស់មិនឲ្យប្រកបការងារនោះបាន ប្រសិនបើយល់ឃើញថា សកម្មភាពទាំងនោះផ្ទុយនឹងកិត្តិយស ឬសេចក្តីទៀងត្រង់ ឬខូចកិត្យានុភាពនៃមុខងារចៅក្រម ឬព្រះរាជអាជ្ញា ។

ក្នុងករណីដែលមានការរំលោភលើមាត្រានេះ ចៅក្រម ឬព្រះរាជអាជ្ញាដែលដាក់ឲ្យនៅទំនេរត្រូវទទួលទោសជាវិន័យដូចមានចែងក្នុងមាត្រា ៥៥ នៃច្បាប់នេះ ។

## ជំពូកទី ៥
## អន្តរប្បញ្ញត្តិ

**មាត្រា ១០៨.-**

ចៅក្រម និងព្រះរាជអាជ្ញា ដែលទទួលបានការតែងតាំងមុនច្បាប់នេះចូលជាធរមាន ហើយស្ថិតក្នុងក្របខណ្ឌគ្រប់គ្រងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវទទួលបានដោយពេញច្បាប់ នូវក្របខណ្ឌចៅក្រម និងព្រះរាជអាជ្ញា តាមបញ្ញត្តិនៃច្បាប់នេះ លើកលែងតែចៅក្រមនៃតុលាការយោធា និងព្រះរាជអាជ្ញាអមតុលាការយោធា ។

គណៈកម្មការដើម្បីពិនិត្យលក្ខណវិនិច្ឆ័យសម្រាប់ការធ្វើសមាហរណកម្មទៅក្នុងថ្នាក់ និងឋានន្តរស័ក្តិនៃចៅក្រម និងព្រះរាជអាជ្ញា ត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ការធ្វើសមាហរណកម្មខាងលើនេះ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ១០៩.-**

បញ្ញត្តិនៃជំពូកទី ២ (ចៅក្រម) ផ្នែកទី ១២ (ការចូលនិវត្តន៍) និងជំពូកទី ៣ (ព្រះរាជអាជ្ញា)

ផ្នែកទី ១២ (ការចូលនិវត្តន៍) នៃច្បាប់នេះ ត្រូវយកមកអនុវត្ត បន្ទាប់ពីការធ្វើសមាហរណកម្មចូលទៅក្នុងក្របខណ្ឌចៅក្រម និងព្រះរាជអាជ្ញា។

ក្នុងពេលរង់ចាំការធ្វើសមាហរណកម្មខាងលើ ការចូលនិវត្តន៍របស់ចៅក្រម និងព្រះរាជអាជ្ញា ត្រូវអនុវត្តដោយអនុលោមតាមបទដ្ឋានគតិយុត្តដែលមានមុនពេលច្បាប់នេះត្រូវបានអនុវត្ត។

**មាត្រា ១១០.-**

ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំដំបូង បន្ទាប់ពីច្បាប់នេះចូលជាធរមាន បទប្បញ្ញត្តិនៃមាត្រា ៤៩ និងមាត្រា ៩៥ នៃច្បាប់នេះ មិនត្រូវយកមកអនុវត្តឡើយ លើកលែងតែការកំណត់ចំនួនចៅក្រមនៅតុលាការកំពូល ។

ក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំដំបូង បន្ទាប់ពីច្បាប់នេះចូលជាធរមាន ចៅក្រមនៃសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ដែលដល់អាយុចូលនិវត្តន៍ អាចអនុញ្ញាតឲ្យបន្តការងារ តាមការស្នើសុំរបស់សាមីខ្លួន។ ការបន្តការងារនេះមានរយៈពេល ០១ (មួយ) ឆ្នាំ ម្តង ប៉ុន្តែមិនឲ្យលើសពី០៣ (បី) ដង ឡើយ។ ការអនុញ្ញាតឲ្យបន្តការងារនេះ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ១១១.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទុកជានិរាករណ៍។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស/រកម.០៧១៤/០១៦ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ហត្ថលេខា**

**អង្គ វង្សវឌ្ឍានា**

លេខៈ៩០៤ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

ឧបសម្ព័ន្ធ

# សច្ចាប្រណិធាន
# ទូលព្រះបង្គំ
# យើងខ្ញុំ
# ជាចៅក្រម និងជាព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា
# សូមធ្វើសច្ចាប្រណិធាន
# នៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ ព្រះភ័ក្ត្រសម្តេចព្រះសង្ឃរាជ
# និងទេវតារក្សាស្វេតច្ឆត្រ
# ដូចតទៅ ៖

ក្នុងពេលបំពេញវិជ្ជាជីវៈជាចៅក្រម និងជាព្រះរាជអាជ្ញា ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាថានឹងប្រតិបត្តិតួនាទី ភារកិច្ច និងប្រើសិទ្ធិអំណាចរបស់ទូលព្រះបង្គំយើងខ្ញុំ ក្នុងឋានៈជាចៅក្រម និងជាព្រះរាជអាជ្ញា ដោយគោរពឲ្យបានត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ និងច្បាប់ទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងប្រតិបត្តិឲ្យបានខ្ជាប់ខ្ជួនតាមក្រមសីលធម៌របស់ចៅក្រម និងព្រះរាជអាជ្ញា ។ ទូលព្រះបង្គំយើងខ្ញុំ សូមសច្ចាថា នឹងស្មោះត្រង់ចំពោះវិជ្ជាជីវៈ ប្រកាន់ខ្ជាប់នូវឧត្តមគតិជាតិ ព្រមទាំងបំពេញវិជ្ជាជីវៈប្រកបដោយសេចក្តីថ្លៃថ្នូរ វីរិយភាព និង សុចរិតយុត្តិធម៌ ។

ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាប្រើប្រាស់សតិសម្បជញ្ញៈ និងឧត្តមគតិជាតិ ក្នុងការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងការអនុវត្តច្បាប់ទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ដោយត្រូវវៀរចាកពីអគតិធម៌ទាំងបួនប្រការ គឺ "**ឆន្ទាគតិ ទោសាគតិ ភយាគតិ និងមោហាគតិ**" និងប្រកាន់យកនូវសុគតិធម៌ប្រកបដោយ "**វីរិយាសម្បយុត្ត សុចរិតយុត្តិធម៌ បញ្ញាត្តិគារវោ សមទណ្ឌោ និងបញ្ញាវុធ វិនិច្ឆ័យ**" ។

បើទូលព្រះបង្គំយើងខ្ញុំ មិនបានប្រតិបត្តិតាមតួនាទី ភារកិច្ច និងអំណាចដូចដែលបានសច្ចាខាងលើទេនោះ សូមព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ អស់ទេព្រក្ស អារុក្ខអារក្ស អ្នកតាយាយទេព និងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក ដាក់ទោសទណ្ឌកម្មដល់ទូលព្រះបង្គំយើងខ្ញុំទាំងក្នុងឥធលោក និងបរលោក ។

ប៉ុន្តែ បើទូលព្រះបង្គំយើងខ្ញុំ បានប្រតិបត្តិតាមតួនាទី និងភារកិច្ចត្រឹមត្រូវ ដូចបានសច្ចាខាងលើវិញនោះ សូមព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ អស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក ជួយឲ្យទូលព្រះបង្គំយើងខ្ញុំទទួលបានសេចក្តីសុខក្នុងឥធលោក និងបរលោក កុំបីអាក់ខានឡើយ ។

ROYAUME DU CAMBODGE
LE MINISTÈRE DU PALAIS ROYAL